សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការត្រួតពិនិត្យជាសកលតាមកាលកំណត់

## Universal Periodic Reviwe ( UPR )

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ក. **គឹម កញ្ញា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឃឹម គីរី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ


នាងខ្ញុំឈ្មោះ **គឹម ភញ្ញា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្រ្ត បង់ថ្លៃ ជំនាន់ទី២០ ថ្នាក់$L_4C_3$ នៃឆ្នាំសិក្សា២០១៦-២០២០ នាំសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមសម្តែងការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

អ្នកម្តាយ **គឹម ឡេង** និងលោកឪពុក **សំ ភារៈ** លោកឪពុក **សឹត ចណ្ណាឌីភារុន** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ និងផ្តល់សេចក្តីស្រលាញ់ មេត្តា ករុណា អប់រំ ទូន្មាន ប្រៀនប្រដៅ ឲ្យមានសេចក្តីអំណត់ ព្យាយាម តស៊ូ ជំនះគ្រប់ឧបសគ្គ ក្លាហាន ជាពិសេសបានផ្តល់ពេលវេលា និងឱកាសដល់នាងខ្ញុំដ៏ថ្លៃថ្លាបំផុត សម្រាប់ឲ្យបានសិក្សារៀនសូត្រ មានចំណេះដឹង ជំនាញប្រសើរតាំងពីថ្នាក់មតេយ្យរហូតដល់ថ្នាក់បរិញ្ញាបត្រនេះ ទោះបីជាជួបនូវឧបសគ្គ និងភាពខ្វះខាតអ្វីក៏មិនគិត។

ជាមួយគ្នាដែរ នាងខ្ញុំក៏សូមថ្លែងអំណរអរគុណយ៉ាងខ្ពង់ខ្ពស់ ចំពោះ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លុយ ចណ្ណា** និងសាកលវិទ្យាធិការរង ព្រមទាំងសាស្រ្តាចារ្យគ្រប់មុខវិជ្ជា បុគ្គលិកគ្រប់ជាន់ថ្នាក់ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំបង្រៀនឲ្យនាងខ្ញុំទទួលបាននូវចំណេះដឹង ព្រមទាំងបង្កជាបរិយាកាសងាយស្រួលនានា ដើម្បីឲ្យនាងខ្ញុំសម្ងំរៀនសូត្រដោយក្តីសុខសប្បាយ រហូតអាចបញ្ចប់ការសិក្សាដោយជោគជ័យ។

ជាពិសេសបំផុត នាងខ្ញុំសូមគោរពថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកសាស្រ្តាចារ្យ **ឃឹម គិរី** ដែលជាសាស្រ្តចារ្យណែនាំ ដោយលោកមានក្តីមេត្តា ករុណា ទទួលយកនាងខ្ញុំជានិស្សិតស្ថិតក្រោមការណែនាំ និងបានចំណាយពេលវេលាដ៏មានតម្លៃ លះបង់អស់កម្លាំងកាយ និងកម្លាំងចិត្ត មិនខ្លាចនឿយហត់ ដើម្បីជួយដឹកនាំ និងជំរុញក្នុងការសរសេរស្នាដៃនេះ តាំងពីដើមហូតដល់ចប់។

នាងខ្ញុំក៏សូមអរគុណដល់សាស្រ្តាចារ្យ បងប្អូន មិត្តភក្តិ សិស្សច្បង សិស្សប្អូន ដែលបានខិតខំប្រឹងប្រែងបង្រៀន ផ្តល់បទពិសោធន៍ចំណេះដឹងផ្នែកស្រាវជ្រាវ ឈឺឆ្អើលក្នុងគ្រាដែលខ្ញុំត្រូវការ និងលើកទឹកចិត្តដល់រូបនាងខ្ញុំរហូតមក។

ជាចុងបញ្ចប់នាងខ្ញុំ សូមជូនពរ និងបួងសួងដល់វត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ ជូនដល់អ្នកមានគុណទាំងឡាយ និងសូមជួយបីបាច់ថែរក្សាលោកអ្នកមានគុណទាំងអស់ឲ្យមានសុខភាពល្អ ឈ្នះអស់អ្នកប៉ងអាក្រក់ សត្រូវមកពីឆ្វាយឲ្យរំលង សត្រូវមកពីខ្នងឲ្យរលាយ ព្រមទាំងសូមឲ្យអ្នកទាំងអស់គ្នាជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ កុំបីឃ្លាតឃ្លាឡើយ៕

# អារម្ភកថា

ការសិក្សានៅសាកលវិទ្យាល័យទាមទាមមាននូវស្វ័យសិក្សាដោយខ្លួនឯងច្រើន ជាជាងចាំតែទទួលពីសំណាក់ លោកគ្រូ អ្នកគ្រូ ដោយហេតុថាមកដល់ត្រង់ចំណុចនេះ ទាំងនាងខ្ញុំ ទាំងនិស្សិតផ្សេងទៀត ជាទូទៅគឺជានីតិជនអស់ទៅហើយ ចាំបាច់ណាស់ត្រូវតែរៀនធ្វើជាម្ចាស់លើខ្លួនឯង ដើម្បីមានចំណេះជំនាញពិតប្រាកដ។ ដូចនេះ ទើបនាងខ្ញុំបានជ្រើសរើសយក ប្រធានបទស្តីពី "**ការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR)**" មកធ្វើជាសារណា ដើម្បីបញ្ចប់ការសិក្សាផង និងជាការវាស់ស្ទង់នូវចំណេះដឹងថា ខ្លួនឯងមានចំណេះដឹងកម្រិតណា ព្រមទាំងពង្រីកនូវជំនាញស្រាវជ្រាវស្វែងរកចំណេះដឹងថ្មីៗអំពីប្រធានបទខាងលើបន្ថែមទៀតផង។

គោលបំណងក្នុងការស្រាវជ្រាវ គឺបង្ហាញពីការចូលរួមឃ្លាំមើលការគោរពសិទ្ធិរបស់មនុស្ស និងសេរីភាពជាមូលដ្ឋាន មិនមែនតែជាភារកិច្ចរបស់រាជរដ្ឋាភិបាលរបស់យើងតែមួយនោះទេ ពោលគឺសកលលោកទាំងមូលក៏បានចូលរួមចំណែកក្នុងការណ៍ដែលឲ្យមនុស្សគ្រប់រូបទទួលបាននូវអ្វីដែលជាសិទ្ធិ សេរីភាពរបស់ខ្លួនគ្រប់ៗគ្នា មិនឲ្យគេរំលោភបំពានបានដោយងាយៗ និងដោយមិនសមហេតុផលឡើយ តាមរយៈការប្រើយន្តការនៃការត្រួតពិនិត្យជាសកលតាមកាលបរិច្ឆេទកំណត់។ ប្រធានបទនេះ ក៏នឹងនាំអ្នកអានទាំងអស់ឲ្យបានស្គាល់កាន់តែច្បាស់នូវយន្តការត្រួតពិនិត្យការគោរពសិទ្ធិ សេរីភាព មនុស្ស ដោយមិនប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ដើមកំណើត គំនិតនយោបាយ ជាអាទិ៍ របស់អង្គការសហប្រជាជាតិ តាមរយៈក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលស្ថិតក្រោមឆ័ត្រអង្គការសហប្រជាជាតិ។ មិនត្រឹមតែប៉ុណ្ណោះ ក៏ស្តែងឡើងជាទំនាក់ទំនងអន្តរជាតិជាសហគមន៍ប្រកបដោយសាមគ្គីភាព ក្នុងន័យត្រួតពិនិត្យ កែលម្អគ្នាទៅវិញទៅមក តាមការផ្តល់អនុសាសន៍ដែលរដ្ឋនីមួយៗមាន បន្ទាប់មករដ្ឋសមីទទួលយកអនុសាសន៍ទាំងនេះ ដើម្បីកែតម្រូវចំណុចខ្វះខាតរបស់ខ្លួន ព្រមទាំងជម្រុញឲ្យការគោរពសិទ្ធិ សេរីភាពរបស់មនុស្សក្នុងរដ្ឋរបស់ខ្លួនបានប្រសើរឡើងទៀតផង។

ជាទីបញ្ចប់ ទោះបីជាសារណាជាស្នាដៃមួយនេះ ព្រមទាំងត្រូវបានស្រាវជ្រាវយ៉ាងខិតខំប្រឹងប្រែង និងប្រើអស់ពីសមត្ថភាព ដែលបានស្រាវជ្រាវ និងសិក្សាកន្លងមកយ៉ាងណាក៏ដោយ ក៏នៅតែមាននូវចំណុចខ្វះខាតផងដែរ។ នេះក៏ពីព្រោះតែបទពិសោធន៍ និងចំណេះដឹងក្នុងការស្រាវជ្រាវនៅមានកម្រិត រួមផ្សំទាំងឯកសារក្នុងការស្រាវជ្រាវជាភាសាជាតិមិនមានច្រើន និងបានបកប្រែឯកសារខ្លះពីភាសាអង់គ្លេស ជាហេតុនាំឲ្យកើតមាននូវកំហុសឆ្គងក្នុងការបកប្រែ ខ្លឹមសារ ឃ្លាប្រយោគ ភាសាបច្ចេកទេសជាដើម កើតមានជាក់ជាមិនខានឡើយ។ ហេតុដូចនេះហើយ រាល់ការផ្តល់ជាអនុសាសន៍ រាល់ការរិះគន់ក្នុងន័យស្ថាបនា ផ្តល់គំនិតថ្មីៗទាំងឡាយពីសំណាក់អ្នកអានទាំងអស់ គឺជាកម្លាំងចលករដែលមិនអាចខ្វះបាន ក្នុងការចូលរួមកែលម្អ និងអភិវឌ្ឍន៍សមត្ថភាពក្នុងវិស័យស្រាវជ្រាវឲ្យកាន់តែរីកចម្រើន ហើយនាងខ្ញុំផ្ទាល់ក៏មានក្តីសោមនស្សរីករាយនឹងទទួលយកផងដែរ។

# មាតិកា

ទំព័រ

**បញ្ជីអក្សរកាត់** .....iv

**សេចក្តីផ្តើម** ..... ១

**ជំពូកទី១ សញ្ញាណទូទៅ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់** .....៥

១.១. ការបង្កើតយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ ..... ៥

១.១.១. ការជួររលំគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ..... ៦

១.២. គោលការណ៍ និងគោលដៅក្នុងការបង្កើតការត្រួតពិនិត្យជាសាកលតាមកាលកំណត់ .. ១០

១.២.១. គោលការណ៍ .....១១

១.២.២. គោលដៅ ..... ១២

១.៣. កាលកំណត់ និងលំដាប់លំដោយ .....១២

១.៤. វដ្តនៃការត្រួតពិនិត្យ ..... ១៣

**ជំពូកទី២ ស្ថាប័នដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យជាសកលតាមកាលកំណត់** ..១៤

២.១. ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (United Nations Human Right Council).....១៤

២.១.១. សមាជិកភាព.....១៥

២.១.២. អង្គការបុត្រសម្ព័ន្ធ នៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ.....១៦

២.២. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ( United Nations Office of High Commissioner) .....១៨

២.២.១. រចនាសម្ព័ន្ធសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ.....១៨

២.២.២. ទីស្នាក់ការកណ្តាលរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ .....១៩

២.៣. អង្គការព័ត៌មានអំពីយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR Info).....២០

**ជំពូកទី៣ ដំណើរការនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់**.....២៣

៣.១. វគ្គមុនសម័យប្រជុំ .....២៣

៣.១.១. ប្រវត្តិ........................................................................................២៤
៣.១.២. គោលបំណង....................................................................................២៦
៣.១.៣. ការត្រួតពិនិត្យសិទ្ធិមនុស្សនៅវគ្គមុនសម័យប្រជុំ ....................................២៧
៣.១.៤. ការចូលរួមជាមួយវគ្គមុនសម័យប្រជុំ ......................................................២៨
៣.១.៤.១. ចំណាប់អារម្មណ៍ នៃការការចូលរួម .......................................................២៨
៣.១.៤.២. ការជ្រើសរើសអ្នកដាក់ពាក្យសុំដើម្បីធ្វើជាវាគ្មិន .............................. ២៩
៣.១.៤.៣. ភាសា ដែលត្រូវប្រើក្នុងកិច្ចពិភាក្សា នៃវគ្គមុនសម័យប្រជុំ........................ ៣២
៣.១.៤.៤. ការចូលរួមពីសំណាក់បេសកម្មអចិន្ត្រៃយ៍ .......................................៣២
៣.១.៤.៥. ការចូលរួមរបស់រដ្ឋស្ថិតក្រោមការត្រួតពិនិត្យ..................................៣២
៣.១.៤.៦. សុវត្ថិភាពក្នុងការចូលរួមនៅវគ្គមុនសម័យប្រជុំ ................................ ៣២
៣.១.៥. ហិរញ្ញវត្ថុ .......................................................................................៣៣
៣.២. សម័យប្រជុំរបស់យន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR Session)..៣៣
៣.២.១. មុនពេលត្រួតពិនិត្យ ........................................................................ ៣៤
៣.២.២. ពេលត្រួតពិនិត្យ............................................................................ ៣៥
៣.២.២.១. ក្រុមការងារត្រួតពិនិត្យជាសកលតាមការកំណត់ (Working Group)... ៣៦
៣.២.២.២. កិច្ចសន្ទនា/ពិភាក្សាជាអន្តរកម្ម ...............................................៣៧
៣.២.២.៣. ការអនុម័តជាផ្លូវការ នៃរបាយការណ៍លទ្ធផល............................៣៨
ក. ដំណាក់កាលនៃការរៀបចំរបាយការណ៍ដោយ Troika....................៣៨
ក.១. អ្វីជាTroika? ................................................................ ៣៨
ក.២. ដំណើរការនៃតួនាទី Troika................................................ ៣៨
៣.២.៣. ក្រោយការត្រួតពិនិត្យ ...................................................................... ៣៩
៣.៣. ការតាមដានការអនុវត្តអនុសាសន៍.........................................................៤០
៣.៣.១. យន្តការដើម្បីត្រួតពិនិត្យ និងធានាការអនុវត្ត.......................................៤០
៣.៣.១.១. ក្នុងកម្រិតអន្តរជាតិ...............................................................៤០
៣.៣.១.២. ក្នុងកម្រិតប្រទេស..................................................................៤១

៣.៣.២. របាយការណ៍ពាក់កណ្តាលវដ្ត (Mid-term Report) ............................ ៤១

**ជំពូកទី៤ តួអង្គដែលចូលរួមក្នុងយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់** ៤៣

៤.១. រដ្ឋ ........................................................................ ៤៣

៤.១.១. រដ្ឋក្រោមការត្រួតពិនិត្យ (State Under Review (SUR)) ........................ ៤៤

៤.១.១.១. ការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល ........................................ ៤៤

៤.១.១.២. សកម្មភាពលើអនុសាសន៍ដែលបានកត់សម្គាល់ ................................. ៤៥

៤.១.១.៣. ការសម្រេចចិត្តលើស្ថានភាពអនុសាសន៍ ....................................... ៤៥

៤.១.២. រដ្ឋផ្តល់អនុសាសន៍ (Recommending State) ........................................ ៤៨

៤.១.២.១. នៅទីក្រុងហ្សឺណែវ ......................................................... ៤៨

៤.១.២.២. នៅកម្រិតថ្នាក់ជាតិ ......................................................... ៤៩

៤.២. អង្គការសង្គមស៊ីវិល ........................................................... ៤៩

៤.៣. ស្ថាប័នសិទ្ធិមនុស្សជាតិ ........................................................ ៥០

៤.៤. សមាជិកសភា ................................................................. ៥០

៤.៥. ទីភ្នាក់ងារអង្គការសហប្រជាជាតិ (UN Agencies) ..................................... ៥១

៤.៦. អ្នកសារព័ត៌មាន ............................................................... ៥១

៤.៧. អ្នកសិក្សាស្រាវជ្រាវ ............................................................. ៥២

**សេចក្តីសន្និដ្ឋាន** ................................................................ ៥៣

**អនុសាសន៍** ..................................................................... ៥៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# តារាងអក្សរកាត់

- អង្គការសហប្រជាជាតិ : United Nations (UN)
- ការត្រួតពិនិត្យជាសកលតាមកាលកំណត់ : Universal Periodic Review (UPR)
- គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ : United Nations Commission on Human (CHR)
- ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ : United Nations Human Right Council (HRC)
- អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ : UPR Info
- ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ : Economics and Social Council of United Nations (ECOSOC)
- រដ្ឋផ្តល់អនុសាសន៍ : Recommending State (RS)
- ក្រុមការងារត្រួតពិនិត្យជាសកលតាមកាលកំណត់ : Working Group (WG)
- សម័យប្រជុំរបស់យន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ : UPR Session
- ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស : Office of High Commission on Human Right OHCHR
- រដ្ឋក្រោមការត្រួតពិនិត្យ : State Under Review (SUR)
- យន្តការជាតិសម្រាប់ការធ្វើរបាយការណ៍ និងការតាមដាន : National Mechanism for Reporting and Follow-up NMRF
- ស្ថាប័នសិទ្ធិមនុស្សជាតិ : National Human Right Institution (NHRI)
- អង្គការសង្គមស៊ីវិល : Civil Society Organization (CSOs)
- S.M.A.R.T ៖ S=Specific M=Measurable A=Achievable R=Relevant T=Time-Bond
- កិច្ចសហប្រតិបត្តិការភាគខាងត្បូង-ខាងត្បូង : South-South cooperation (SSC)
- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព : Sustainable Develop Goal (SDGs))
- ទីភ្នាក់ងារអង្គការសហប្រជាជាតិ (UN Agencies)
- ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិ : UN Develop Assistance Framework (UNDAF)

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

វិសមភាពនៃមនុស្ស គឺជាឫសគល់នៃសេចក្ដីស្អប់ខ្ពើមគ្នា ការរើសអើង ការជិះជាន់សង្កត់សង្កិន ការកេងប្រវ័ញ្ច ភាពឈឺចាប់ ភាពសាហាវយង់ឃ្នង ជាដើម។ មូលហេតុទាំងអស់នេះហើយ ដែលនាំឲ្យមានបដិវត្តន៍ទាមទារនូវអ្វីដែលជាសិទ្ធិរបស់មនុស្ស ដែលពួកគេសមនឹងទទួលបាន ក្នុងឋានៈនៃភាពដែលកើតជាមនុស្សដូចគ្នា ដោយគ្មានប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា គំនិតនយោបាយ ជាតិពន្ធុ ជាតិសាសន៍ ទ្រព្យសម្បត្តិ ឋានៈសង្គម រូបសម្បត្តិ ជាអាទិ៍ ហើយការណ៍ដែលសិទ្ធិ សេរីភាពរបស់មនុស្សអាចមានទៅបាន និងមានសមភាពបានកម្រិតដូចសព្វថ្ងៃនេះ ក៏ព្រោះតែ ការតស៊ូ ដែលលេចចេញជាការបដិវត្តន៍នោះ ត្រូវចាត់ទុកជាប្រវត្តិសាស្ត្រ ព្រមទាំងមានការវិវត្តអត់ឈប់ឈរ។ ការវិវត្តនៃសិទ្ធិមនុស្សនេះ មានលទ្ធផលដំបូងជា "សេចក្ដីប្រកាសស្ដីពីសិទ្ធិជាមូលដ្ឋាន (Bill of Right) ឆ្នាំ១៦៨៩" នៅឯប្រទេសអង់គ្លេស។ បន្ទាប់មក នៅឆ្នាំ១៧៧៦ នៅសហរដ្ឋអាមេរិក សេចក្ដីប្រកាសឯករាជ្យ (Declaration of Independence) បន្ទាប់មកទៀតនៅឆ្នាំ១៧៨៩ នៅបារាំង មានសេចក្ដីប្រកាសស្ដីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ(Declaration of the Right of Man and of the Citizen)។ រហូតមកដល់ឆ្នាំ ១៩១០-១៩១៧ សន្និសីទស្ត្រីសង្គមនិយមអន្តរជាតិ (អាមេរិក និងសូវៀត) (International Socialist Woman's Conference) ត្រូវបានប្រារព្ធឡើង។ ក្រោយពីមានការផ្ទុះនូវសង្គ្រាមលោកលើកទី២ នៅក្នុងឆ្នាំ ១៩៣៥-១៩៤៥ សោជនាដកម្មអំពើអមនុស្សធម៌ ដែលត្រូវបានកើតឡើង ព្រមទាំងត្រូវបានចងក្រងឡើង ដោយហេតុនៃការសម្លាប់រង្គាលក្នុងរបបផ្ដាច់ការណាស៊ីលើជនជាតិជ្វីប និងរបបផ្ដាច់ការរបស់ជប៉ុន។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៤៥ អង្គការសហប្រជាតិត្រូវបានបង្កើតឡើង ដោយសោជនាថកម្មនៃសង្គ្រាមលោកលើកទី១ និងសង្គ្រាមលោកលើកទី២ ព្រមទាំងបញ្ហាវិសមភាពអធិបតេយ្យភាពរវាងរដ្ឋ និងរដ្ឋ បញ្ហារំលោភសិទ្ធិមនុស្សជាអាទិ៍។ ហេតុនេះហើយ ទើបយើងឃើញបុព្វកថា នៃអង្គការសហប្រជាជាតិបានលើកឡើងនូវជំនឿលើសិទ្ធិជាមូលដ្ឋានរបស់មនុស្ស សេចក្ដីថ្លៃថ្នូរ និងតម្លៃរបស់មនុស្សម្នាក់ៗ ព្រមទាំងប្រជាជាតិទាំងមូល មិនតែប៉ុណ្ណោះក៏មាន សមភាពរវាងបុរស និងនារី បូករួមទាំងសមភាពរវាងរដ្ឋ និងរដ្ឋ មិនថា រដ្ឋនោះជារដ្ឋតូច ឬ រដ្ឋធំនោះទេ។

ដោយហេតុនេះ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ដែលជាមែកធាង (Organ) នៃអង្គការសហប្រជាជាតិបានសម្រេចបង្កើតគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (United Nations Commission on Human Right ហៅកាត់ថា CHR) ដែលជាគណៈកម្មការស្នូលនៃរចនាសម្ព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិផ្ដោតយ៉ាងចម្បងលើការការពារសិទ្ធិសេរីភាពរបស់មនុស្សគ្រប់ៗគ្នា។ ប៉ុន្តែ គណៈកម្មការនេះ ត្រូវបានជំនួសដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (United Nations Human Right Council ហៅកាត់ថា HRC) វិញ នៅឆ្នាំ២០០៦។ ក្រុមប្រឹក្សាសិទ្ធមនុស្ស នេះក៏ជាបុព្វហេតុមួយដែលធ្វើឲ្យគេបង្កើតមកជាមួយផងដែរ

នូវយន្តការការពារសិទ្ធិមនុស្សថ្មីស្រឡាងមួយទៀត គឺ "យន្តការនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ (Universal Periodic Review ហៅកាត់ថា UPR)"។ ថ្វីត្បិតតែ ការត្រួតពិនិត្យជាសកលតាមកាលកំណត់ ជាយន្តការថ្មីក៏ពិតមែន ក៏ប៉ុន្តែយន្តការនេះ គឺជាធាតុផ្សំយ៉ាងសំខាន់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សម្រាប់ដំណើរការត្រួតពិនិត្យការគោរពសិទ្ធិមនុស្សទូទាំងពិភពលោក។ ការត្រួតពិនិត្យជាសកលតាមកាលកំណត់ដើរតួនាទីក្នុងការការពារសិទ្ធិមនុស្ស ដែលបានកើតឡើងក្នុងប្រទេសដែលជាសមាជិករបស់អង្គការសហប្រជាជាតិ ព្រមទាំងដាស់តឿនដល់រដ្ឋទាំងឡាយអំពីទំនួលខុសត្រូវ ការគោរព អនុវត្ត និងបំពេញនូវសិទ្ធិមនុស្ស សេរីភាពជាមូលដ្ឋានក្នុងរដ្ឋរបស់ខ្លួនឲ្យបានខ្ជាប់ខ្ជួន។ នេះ ជាលក្ខណៈពិសេស នៃយន្តការត្រួតពិនិត្យសិទ្ធិមនុស្សថ្មី ដូច្នេះហើយ គឺនៅមានចំណុចជាច្រើនទៀតដែលត្រូវសិក្សាស្រាវជ្រាវ ស្វែងយល់ឲ្យកាន់តែស៊ីជម្រៅ។

ដើម្បីសម្រេចបំណងក្នុងការស្វែងយល់ និងទទួលបានចំណេះដឹងពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR) ឯកសារដែលបានត្រៀមរួចជាស្រេច ដោយរួមមានជាដំបូង គឺសិក្សាពីឯកសារដែលសម្រេចបង្កើតយន្តការនេះឡើង ឯកសារដែលនិយាយអំពីដំណើរការ បែបបទនៃការប្រព្រឹត្តទៅ ឯកសារពាក់ព័ន្ធដទៃផ្សេងទៀត ព្រមទាំងគេហទំព័រមួយចំនួន ដូចជា គេហទំព័ររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ( United Nation Human Right Council) គេហទំព័រអង្គការមិនមែនរដ្ឋាភិបាល (អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ "UPR Info") ជាដើម ដែលជាគេហទំព័រគាំទ្រដល់ប្រធានបទនៃការស្រាវជ្រាវនេះ។

ដូចដែលធ្លាប់បានបញ្ជាក់កន្លងមកជាមុន ពោលគឺភាពចាំបាច់ នៃការបង្កើតយន្តការ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ឡើង ក៏ព្រោះតែយន្តការការពារសិទ្ធិមនុស្សរបស់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ មានភាពខ្វះខាត ដោយរងនូវការនិន្ទាផ្សេងៗ។ ដូច្នេះ ចម្ងល់ គឺបានកើតមានឡើងដោយបានសួរថា តើមូលហេតុអ្វីបានជាគេជ្រើសយកការបង្កើតយន្តការណ៍ថ្មី ជាជាងកែលម្អយន្តការដែលមានស្រាប់? តើមានអ្វីពិសេសនៅក្នុងយន្តការការត្រួតពិនិត្យជាសកលតាមកាលកំណត់? តើយន្តការនេះ មានរចនាសម្ព័ន្ធយ៉ាងដូចម្ដេច ឬ ពាក់ព័ន្ធជាមួយនឹងស្ថាប័នណាខ្លះ? ពាក់ព័ន្ធជានៃមួយអ្នកណាខ្លះ? តើមានដំណើរការបែបបទនៃការប្រព្រឹត្តទៅយ៉ាងដូចម្ដេច ទាំងការចាប់ផ្ដើម ទាំងចន្លោះពេល ទាំងការបញ្ចប់?

ត្រឡប់មកវិញ ការបកស្រាយប្រធានបទស្ដីពី "ការត្រួតពិនិត្យជាសកលតាមកាលកំណត់" ខាងលើ គឺមានគោលបំណងស្រាយនូវចម្ងល់តបនឹងសំណួរដែលបានលើកខាងលើ ឲ្យកាន់តែលម្អិត ងាយស្រួលយល់អំពីប្រធានបទខាងលើនេះ។ មិនតែប៉ុណ្ណោះ ក៏សម្រេចនូវគោលបំណង ដែលចង់ណែនាំទៅកាន់អ្នកដែលបានអានសារណានេះ ឲ្យបានយល់ថា មិនមែនរដ្ឋអាងលើដែនដី ប្រជាជន និងរដ្ឋាភិបាល ដែលជាធាតុផ្សំរបស់រដ្ឋ ឬ អាង

លើអធិបតេយ្យភាពរបស់ខ្លួនភ្លេចនូវកាតព្វកិច្ចសិទ្ធិមនុស្ស ដែលរដ្ឋទាំងអស់ត្រូវគោរពនោះទេ។ ប្រសិនបើប្រទេស ឬ រដ្ឋណាមិនព្យាយាមគោរពសិទ្ធិមនុស្ស សហគមន៍អន្តរជាតិតាមរយៈយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់នឹងណែនាំក៏ដូចជាដាក់សម្ពាធឲ្យប្រទេស ឬ រដ្ឋនោះកែលម្អឲ្យកាន់តែប្រសើរនូវការគោរពសិទ្ធិមនុស្ស ក្នុងន័យដែលជាសហគមន៍អន្តរជាតិដែលសម្តែងសាមគ្គីភាពរវាងរដ្ឋ និងរដ្ឋ។

ជាធម្មតា ការសរសេរសារណាបញ្ចប់ការសិក្សាតែងតែជួបនូវចំណុចខ្វះចន្លោះ ហើយត្រូវពឹងលើសមត្ថភាពរបស់អ្នកសរសេរផងដែរ។ ដូច្នេះ ហើយក៏ទាមទារផងដែរ នូវចំណេះដឹង និងបទពិសោធន៍ស្រាវជ្រាវដែលធ្លាប់បានឆ្លងកាត់កន្លងមក។ អាស្រ័យហេតុនេះ ថ្វីត្បិតតែមានការចងចិត្តព្យាយាមស្រាវជ្រាវកុំឲ្យមានការខ្វះចន្លោះក៏ដោយ ក៏គង់តែនឹងមាននូវចំណុចខ្វះខាត។ សារណានេះ នាងខ្ញុំសុំលើកឡើងដោយផ្អែកលើសេចក្តីសម្រេចមហាសន្និបាតរបស់អង្គការសហប្រជាជាតិ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលពាក់ព័ន្ធនឹងយន្តការនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ស្នាដៃស្រាវជ្រាវផ្សេងៗ ព្រមទាំងព័ត៌មានប្រយោជន៍ផ្សេងៗទៀត ដែលអាចស្វែងរកតាមរយៈគេហទំព័ររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (United Nation Human Right Council) គេហទំព័រអង្គការមិនមែនរដ្ឋាភិបាល (UPR Info) ជាអាទិ៍ គឺផ្តោតជាសំខាន់លើ យន្តការត្រួតពនិត្យជាសកលតាមកាលកំណត់។ លើសពីនេះ សារណានេះមិនស្រាវជ្រាវផ្តោតសំខាន់ទៅលើរដ្ឋដែលទទួលការត្រួតពិនិត្យ ឬ រដ្ឋដែលត្រួតពិនិត្យចំៗនោះទេ គ្រាន់តែលើកឡើងសំខាន់ថាយន្តការនេះគេធ្វើយ៉ាងដូចម្តេចតែប៉ុណ្ណោះ។

ការលើកយកប្រធានបទនេះ មកសរសេរជាសារណាបញ្ចប់ការសិក្សា គឺដោយហេតុថា នៅឆ្នាំទី៣ ឆមាសទី២ នាងខ្ញុំ ទើបបានទទួលសញ្ញាណដំបូងទាក់ទងនឹងយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់តាមរយៈប្រធានបទកិច្ចការស្រាវជ្រាវ ចុះទំរាំអ្នកសិក្សាផ្សេងទៀត ក៏ដូចជាប្រជាជនទូទៅ តើអាចនឹងស្គាល់យន្តការនេះបានដោយងាយស្រួលបែបណា ដើម្បីដឹងច្បាស់ថា អង្គការសហប្រជាជាតិកំពុងជួយការពារសិទ្ធិមនុស្សសម្រាប់ប្រជាជាតិ។ សម្រាប់ឯកសារស្រាវជ្រាវជាភាសាខ្មែរទាក់ទងនឹងយន្តការនេះ មិនមានច្រើននោះទេ ហើយនៅពេលដែលបានស្រាវជ្រាវលើប្រធានបទនេះ ក៏មានការចាប់អារម្មណ៍ ហើយក៏គិតថាត្រឹមទំហំនៃកិច្ចការស្រាវជ្រាវពុំអាចយល់ដឹងកាន់តែច្បាស់នូវប្រធានបទនេះទេ។ ដូច្នេះ ទើបនាងខ្ញុំជ្រើសរើសយកប្រធានបទនេះមកសិក្សាស្រាវជ្រាវ និងចងក្រងក្លាយជាសារណាបញ្ចប់ការសិក្សា ដោយគិតចង់ផ្សព្វផ្សាយយន្តការនេះទៅកាន់អ្នកដែលមិនទាន់បានស្គាល់ដូចនាងខ្ញុំកាលពីមុន ឲ្យពួកគេបានស្គាល់ និងអាចស្វែងយល់ពីចំណុចផ្សេងៗដែលបានបង្ហាញក្នុងយន្តការនេះទុកជាចំណេះដឹង ព្រមទាំងនិស្សិត ឬ អ្នកស្រាវជ្រាវផ្សេងទៀតអាចងាយស្រួលក្នុងការស្វែងរកឯកសារពាក់ព័ន្ធនឹងយន្តការនេះជាភាសាខ្មែរ និងមានបណ្តុំតែមួយ។ ម្យ៉ាងទៀត ក៏សង្ឃឹមថាអ្នកអានសំណេរសារណាមួយនេះក៏អាចចូលរួមចំណែកកាត់បន្ថយនូវការរំលោភសទ្ធិមនុស្សផងដែរ ដោយហេតុ

ថាកាលណាបើដឹងថា អំពើនោះជាអំពើដែរខុស គេអាចឈប់ប្រព្រឹត្តវា ព្រោះបើប្រព្រឹត្តនឹងមានគេឃ្លាំមើលជាមួយនឹងទណ្ឌកម្មផ្សេងៗ។

ដើម្បីសម្រេចនូវគោលបំណង និងអាចសេរសេរ ព្រមទាំងចងក្រងសារណានេះឲ្យបានជោគជ័យទៅបាន ការប្រមូលឯកសារ ព័ត៌មាន និងទិន្នន័យនានា គឺជាធាតុផ្សំយ៉ាងចាំបាច់បំផុតមិនអាចខ្វះបានឡើយចំពោះសារណានីមួយៗ។ ដូចគ្នាដែរ សារណានាងខ្ញុំក៏បានប្រមូលទិន្នន័យរួចជាស្រេចនូវទិន្នន័យចម្បង និងទន្និន័យបន្ទាប់បន្សំ។ ទិន្នន័យចម្បង គឺផ្អែកលើ (ក) សេចក្តីសម្រេចរបស់មហាសន្និបាតលេខA/RES/៦០/២៥១ ស្តីពី ការបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ (ខ) សេចក្តីសម្រេចលេខ ៥/១ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ បង្កើនស្ថាប័នរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (Institution-building of the United Nations Human Rights Council) ព្រមទាំងឯកសារចម្បងពាក់ព័ន្ធដទៃទៀត។ ទិន្នន័យបន្ទាប់បន្សំត្រូវបានយកចេញពីស្នាដៃស្រាវជ្រាវផ្សេងៗ ព្រមទាំងគេហទំព័ររបស់ពាក់ព័ន្ធ។

ក្រោយពីបានឆ្លងកាត់ពីមួយចំណុចទៅមួយចំណុចនូវចំណុចទាំងអស់ខាងរួចមក ទើបនាងខ្ញុំសម្រេចកំណត់យកជំពូកនៅក្នុងសារណាស្រាវជ្រាវនេះ ដោយបានចែកជា៤ ជំពូក។ ជំពូកទី១ **សញ្ញាណទូទៅនៃការត្រួតពនិត្យជាសកលតាមកាលកំណត់** ដែលនាងខ្ញុំនឹងបកស្រាយថាអ្វីជាការត្រួតពីនិត្យជាសកលតាមកាលកំណត់ ការបង្កើត គោលការណ៍ កម្មវត្ថុ ចំនួនវដ្ត រយៈពេល និងលំដាប់លំដោយ។ ចំពោះជំពូកទី២ និយាយពី **ស្ថាប័នដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យជាសកលតាមកាលកំណត់** ដែលរៀបរាប់ពីប្រវត្តិដោយសង្ខេប និងទំនាក់ទំនងទៅនឹងការត្រួតពិនិត្យ។ ចំណែកឯ ជំពូកទី៣ សម្តៅបង្ហាញពី **ដំណើរការនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់** ថាមានការចាប់ផ្តើម ពាក់កណ្តាល និងបញ្ចប់។ ជាចុងក្រោយ ជំពូកទី៤ នឹងលើកឡើងពី **តួអង្គដែលពាក់ព័ន្ធ** ថាតើមានអ្នកណាខ្លះជាប់ពាក់ព័ន្ធ និងត្រូវចូលរួម។

# ជំពូកទី១ សញ្ញាណទូទៅ នៃការត្រួតពិនិត្យ
# ជាសកលតាមកាលកំណត់

# ជំពូកទី១ សញ្ញាណទូទៅ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់

ការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR) គឺជាយន្តការរបស់អង្គការសហប្រជាជាតិ ដើម្បីពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សក្នុងរដ្ឋនីមួយៗ នៃសមាជិកអង្គការសហប្រជាជាតិ នៅលើពិភពលោក។ ក្នុងអំឡុងពេលត្រួតពិនិត្យ រដ្ឋដែលត្រូវបានត្រួតពិនិត្យត្រូវបង្ហាញអ្វីដែលពាក់ព័ន្ធនឹងការគោរពសិទ្ធិមនុស្សខណៈពេលដែលរដ្ឋជាសមាជិកផ្តល់ជាអនុសាសន៍ដើម្បីលើកស្ទួយសិទ្ធិមនុស្ស។[1] ដូច្នេះ កុំឲ្យបង្អង់យូរ ជាកិច្ចបន្តមកទៀតក្នុងជំពូកនេះ នឹងនាំឲ្យមានភាពច្បាស់នូវសញ្ញាណទូទៅ ដែលបានបែងចែកជា **ការបង្កើតយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់** (១) **គោលការណ៍ និងកម្មវត្ថុក្នុងការបង្កើតយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់** (២) **កាលកំណត់ និងលំដាប់លំដោយ** (៣) និង **វដ្តនៃការត្រួតពិនិត្យ** (៤)។

## ១.១. ការបង្កើតយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់

ការត្រួតពិនិត្យពិភពលោកតាមកាលបរិច្ឆេទជាកំណត់ គឺអង្គការសហប្រជាជាតិមិនមែនបង្កើតយន្តការត្រួតពិនិត្យនេះ ចេញជាអង្គការដាច់ដោយឡែកនោះទេ ប៉ុន្តែ គេសម្រេចបង្កើតវាឡើងជាមួយនឹងការសម្រេចបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (HRC) ដោយផ្អែកលើគោលការណ៍ដូចតទៅ ៖

- ផ្អែកលើព័ត៌មានគោលដៅ និងអាចជឿទុកចិត្តបាននៃការបំពេញបាន ដោយរដ្ឋនីមួយៗនូវកាតព្វកិច្ច និងការប្តេជ្ញាចិត្តសិទ្ធិមនុស្សរបស់ប្រទេសខ្លួន
- ត្រូវបានអនុវត្តក្នុងលក្ខណៈមួយដែលធានាបាននូវភាពជាសកលនៃការគ្របដណ្តប់ និងការប្រព្រឹត្តស្មើគ្នាជាមួយនឹងការគោរពដល់រដ្ឋទាំងអស់
- ធ្វើជាយន្តការសហប្រតិបត្តិការដោយផ្អែកលើការសន្ទនាគ្នា ព្រមទាំងមានការចូលរួមពេញលេញពីប្រទេសដែលមានការជាប់ពាក់ព័ន្ធ និងពិចារណាលើតម្រូវការកសាងសមត្ថភាពរបស់ខ្លួន
- ព្រមទាំងបំពេញ និងមិនចម្លងការធ្វើការងាររបស់ស្ថាប័នសន្ធិសញ្ញា។

ត្រឡប់ក្រោយបន្តិច មុននឹងមានការបង្កើតយន្តការត្រួតពិនិត្យខាងលើ គឺត្រូវឆ្លងកាត់នូវដំណើរដើមទងដូចតទៅ៖ **ការដួរលំគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ** (១.១) **ការសម្រេចបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិដោយមានវត្តមានយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់** (១.២)។

[1] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (UPR) និងកម្ពុជា ជារូបភាព ឆ្នាំ២០១៨

### ១.១.១. ការដួររលំគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ[2]

បើក្រឡេកទៅមើលការបង្កើតគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលត្រូវបង្កើតឡើងនៅក្នុងឆ្នាំ១៩៤៦ ដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ" Economics and Social Council of United Nations (ECOSOC)"។ គណៈកម្មការនេះ គឺជាគណៈកម្មការស្នូលនៃស្ថាប័នទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិជាង ៦០ឆ្នាំ មកហើយ។ ក្នុងរយៈពេល ២០ឆ្នាំដំបូងនៃការបង្កើតគណៈកម្មការសិទ្ធិមនុស្ស (CHR) ការកំណត់ស្តង់ដារនៃការគោរពសិទ្ធិមនុស្ស គឺផ្តោតជាចម្បងលើសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ និងសិទ្ធិសញ្ញាសិទ្ធិមនុស្ស ដែលត្រូវបានអនុម័តឡើងនៅឆ្នាំ១៩៦០។ ការអនុវត្តពីមួយជំហានទៅមួយជំហាន នៃស្តង់ដារទាំងអស់នេះ បានក្លាយជាចំណុចប្រសព្វគ្នានៃការងាររបស់គណៈកម្មការសិទ្ធិមនុស្ស។ ដូចនេះ យន្តការសម្រាប់ការស៊ើបអង្កេតការរំលោភបំពានសិទ្ធិមនុស្ស និងនីតិវិធីនៃបណ្តឹងតវ៉ា[3] មួយ គឺត្រូវបានបង្កើតឡើង ហើយចាប់តាំងពីឆ្នាំ១៩៨០ តទៅ ប្រព័ន្ធនៃយន្តការត្រួតពិនិត្យត្រូវបានអភិវឌ្ឍន៍ ក្រោមការជំនួយឧបត្ថម្ភដោយគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ គណៈកម្មការសិទ្ធិមនុស្សក៏បានបង្កើតផងដែរនូវប្រព័ន្ធនៃនីតិវិធីពិសេស ដើម្បីតាមដានវិភាគ និងរាយការណ៍អំពីការរំលោភសិទ្ធិមនុស្សជាក់លាក់របស់ប្រទេស ក៏ដូចជាការរំលោភសិទ្ធិមនុស្សតាមប្រធានបទ ដូចជា ការរើសអើងជាតិសាសន៍ សាសនា ការមិនអត់ឱន និងការបដិសេធសេរីភាពនៃការបញ្ចេញមតិយោបល់។ បន្ថែមពីលើនេះទៀត ប្រឆាំងទៅនឹងសារតានៃការកើនឡើងការព្រួយបារម្ភចំពោះបញ្ហាសិទ្ធិ មនុស្សគណៈកម្មការ

[2] បកប្រែចេញពីសៀវភៅដែលមានអ្នកនិពន្ធឈ្មោះ Maximilian Spohr "United Nations Human Rights Council Between Institution-Building Phase and Review of Status របស់ Max Plank Yearbook of United Nations Law ទំព័រទី ១៦៩-២១៨ (ហូឡង់ ឆ្នាំ២០១០)" ទំព័រ១៧២ ដល់ ១៧៣ អាចស្វែងរកបាន https://www.mpil.de/files/pdf3/mpunyb_05_spohr_14.pdf (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

[3] នីតិវិធីនៃបណ្តឹងនេះ គឺមានឈ្មោះថា នីតិវិធី១៥០៣ (E/RES1503 (XLII) ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧០ ការជាប់ទាក់ទងព័ត៌មាននឹងការរំលោភសិទ្ធិមនុស្សអាចត្រូវបានដាក់ស្នើដោយជនរងគ្រោះខ្លួនឯង ឬ ដោយអ្នកដទៃទៀត ដែលជាអ្នកតំណាងឲ្យពួកគេ។ ដោយហេតុនេះ នីតិវិធីមិនត្រូវបានរៀបចំឡើងដើម្បីកាត់ទោសការរំលោភសិទ្ធិមនុស្សរបស់បុគ្គលទេ ប៉ុន្តែ ដើម្បីនាំយកការយកចិត្តទុកដាក់របស់គណៈកម្មការសិទ្ធិមនុស្ស (CHR) នូវ " ការដែលអះអាងអំពីការរំលោភបំពានសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានយ៉ាងទូទៅ និងអាចទុកចិត្តបាន"។ នីតិវិធីបណ្តឹងនេះអាចអនុវត្តបានចំពោះគ្រប់រដ្ឋទាំងអស់ ដោយមិនគិតថា តើរដ្ឋទាំងនោះបានការអនុម័តលើសេចក្តីសម្រេចលេខ ១៥០៣ ឬ ផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិណាមួយ ឬ អត់នោះទេ។ នីតិវិធី ១៥០៣ គឺជាការសម្ងាត់ ហើយ គណៈកម្មការសិទ្ធិមនុស្ស (CHR) បានពិចារណាអំពីស្ថានភាព ដែលបាននាំយកមកពិភាក្សានៅក្នុងពេលបិទវគ្គ។ ការតាក់តែងនូវព័ត៌មានត្រូវបានជូនដំណឹង តែក្នុងករណីបណ្តឹងតវ៉ារបស់ពួកគេត្រូវបានទទួលយកប៉ុណ្ណោះ ប៉ុន្តែប្រហែលមិនដំណើរការនោះទេ។

សិទ្ធិមនុស្ស (CHR) បានដើរតួរដូចជាអង្គការនយោបាយយ៉ាងសំខាន់បំផុតសម្រាប់ជាវេទិកាពិភាក្សាគ្នាក្នុងវិស័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។

ទោះបីយ៉ាងណាក៏ដោយ ក៏គណៈកម្មការសិទ្ធិមនុស្ស (CHR) បានក្លាយជាគោលដៅនៃការរិះគន់កាន់តែខ្លាំងឡើងនៅសម័យក្រោយសង្គ្រាមត្រជាក់ នៅពេលដែលភាពខ្វះចន្លោះផ្នែកនយោបាយបានបន្សល់ទុកដោយការបាត់នូវប្រពៃណីបែងចែកភាគខាងកើត - ខាងលិច ត្រូវបានបំពេញជាមួយនឹងការប្រឈមមុខដាក់គ្នាមុខជាថ្មីរវាងក្រុមប្រទេសក្នុងតំបន់ រវាងក្រុមប្រទេសដែលបានបែងចែកក្រុមខាងជើង និងក្រុមខាងត្បូង ឬ ក្រុមប្រទេសដែលបានបែងចែងប្រទេសខ្លួនជាពីរផ្នែក។

ការពង្រីកបន្តិចម្តងៗពី ១៨ ដល់ ៥៣ រដ្ឋនៃរដ្ឋសមាជិក ដែលសមាជិកទាំងនោះត្រូវបានបោះឆ្នោតជ្រើសរើសដោយ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម អង្គការសហប្រជាជាតិ(ECOSOC) សម្រាប់រយៈពេល ០៣ឆ្នាំដោយឈរលើមូលដ្ឋាននៃការជ្រើសរើសដូចតទៅៈ ១៥ រដ្ឋមកពីតំបន់អាហ្វ្រិក ១២ រដ្ឋមកពីក្នុងតំបន់អាស៊ី ០៥ រដ្ឋ មកពីបណ្តាលរដ្ឋក្នុងតំបន់អឺរ៉ុបខាងកើត ១១ រដ្ឋមកពីអាមេរិកឡាទីន និងការ៉ាបៀន (Caribbean) ១០ រដ្ឋមកពីអឺរ៉ុបខាងលិច និងរដ្ឋដទៃទៀត។ នៅក្នុងបរិបទនៃចំនួនកើនឡើងនៃសេចក្តីសម្រេចថ្កោលទោស និងការពង្រីករបៀបវារៈឲ្យបានកាន់តែទូលំទូលាយ ទើបគណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ (CHR) កាន់តែមានលក្ខណៈនយោបាយ។ ប៉ុន្តែ អ្វីដែលគួរឲ្យកត់សំគាល់បំផុតនោះត្រូវបានបង្ហាញដោយការកើនឡើងនូវចំនួននៃ "ចលនាគ្មានសកម្មភាព (no-action motion)[4]" ដែលត្រូវបានរាប់ចាប់ពីពាក់កណ្តាលទសវត្សទី៩០។

លើសពីនេះទៀត ដោយសារលទ្ធផលនៃនយោបាយភាវូបនីយកម្មហួសហេតុរបស់ខ្លួន ពីព្រោះមានរដ្ឋជាច្រើនចង់ក្លាយជាសមាជិកនៃគណៈកម្មការនេះ ទើបធ្វើឲ្យគណៈកម្មការសិទ្ធិមនុស្សត្រូវបានចោទប្រកាន់យ៉ាងមុតមាំថា ខណៈពេលដែលពិនិត្យមើលកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋជាសមាជិក និងរដ្ឋមិនមែនជាសមាជិកគឺជាការត្រួតពិនិត្យដោយគ្មានវិជ្ជាជីវៈ និងមានភាពលំអៀង។ របាយការណ៍ដែលរដ្ឋជាច្រើន ដែលមានកំណត់ត្រាសិទ្ធិមនុស្សមិនល្អ បានស្វែងរកភាពជាសមាជិកជាមួយគណៈកម្មការសិទ្ធិមនុស្សអន្តរជាតិនេះ ដើម្បីការពារខ្លួនពីការត្រួតពិនិត្យវិញ។

[4] ចលនាគ្មានសកម្មភាព (no-action motion) គឺជាចលនានៃនិតិវិធី ដែលមានបញ្ញត្តិក្នុងមាត្រា២ នៃវិធាន៦៥ នៃវិធាននៃនីតិវិធីរបស់មុខងារគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ ប្រសិនបើមានការយល់ព្រម រដ្ឋជាសមាជិកអាចត្រូវបានការពារពីការពិភាក្សាអំពីសេចក្តីសម្រេចទាំងអស់។ នៅក្នុងចលនាគ្មានសកម្មភាពរបស់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិនេះ ត្រូវបានប្រើប្រាស់ដើម្បីជៀសវាងការថ្កោលទោសនៃស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសមួយ។

នៅចុងទសវត្សឆ្នាំ១៩៩០ និងដើមទសវត្ស ២០០០ ភាពចម្រូងចម្រាស បានកើតឡើងលើកំណត់ត្រាសិទ្ធិមនុស្សរបស់មនុស្សមួយចំនួនដែលត្រូវបានគេយល់ឃើញជាទូទៅថា ជាអ្នករំលោភសិទ្ធិមនុស្សជាប្រព័ន្ធ។ ការកើតមានឡើងទាំងនេះ ប៉ះពាល់យ៉ាងសំខាន់ដល់ភាពគួរឲ្យជឿរបស់គណៈកម្មការសិទ្ធិមនុស្សអន្តជាតិ។ ក្រុមអ្នករិះគន់រួមទាំងសហរដ្ឋអាមេរិកបានអះអាងថា ប្រទេសនានាបានប្រើសមាជិកភាពរបស់ពួកគេ ក្នុងការបង្វែរការចាប់អារម្មណ៍អំពីការរំលោភបំពានសិទ្ធិមនុស្សរបស់ពួកគេ ដោយការសាកសួរកំណត់ត្រារបស់រដ្ឋដទៃទៅវិញ។ សមាជិកខ្លះត្រូវបានចោទប្រកាន់ពីបទបោះឆ្នោតជ្រើសរើសប្លុក និងរៀបចំនីតិវិធីហួសហេតុដើម្បីជៀសវាងការជជែកវែកញែកអំពីការរំលោភសិទ្ធិមនុស្ស។ នៅឆ្នាំ២០០១ សហរដ្ឋអាមេរិកមិនបានជាប់ឆ្នោតជាសមាជិករបស់គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិទេ ប៉ុន្តែ រដ្ឋដែលជាអ្នករំលោភសិទ្ធិមនុស្ស ដូចជាប៉ាគីស្ថាន ស៊ូដង់ និងអ៊ូហ្គង់ដា (Uganda) ត្រូវបានជាប់ឆ្នោតទៅវិញ។ នៅក្នុងឆ្នាំ២០០៥ ផលប៉ះពាល់រួម នៃភាពចម្រូងចម្រាសទាំងនេះ និងបញ្ហាផ្សេងៗទៀត គឺបានធ្វើឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វីអាណាន់ (Kofi Annan) បានស្នើគំនិតថ្មី ដោយបានស្នើឲ្យបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្សជំនួសឲ្យគណៈកម្មការសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ។ ចាប់តាំងពីឆ្នាំ២០០៦ រដ្ឋាភិបាល និងអ្នកសង្កេតការណ៍ជាច្រើនបានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំង ជាមួយនឹងការយកចិត្តទុកដាក់មិនស្មើភាពគ្នារបស់គណៈកម្មការសិទ្ធិមនុស្សចំពោះអ៊ីស្រាអែល និងកង្វះការយកចិត្តទុកដាក់ចំពោះបញ្ហាស្ថានភាពសិទ្ធិមនុស្ស ដែលកំពុងមានភាពតានតឹងផ្សេងៗគ្នាទៀត។ អ្នកខ្លះមានការព្រួយបារម្ភផងដែរថា បណ្តាប្រទេសដែលត្រូវបានគេស្គាល់ជាទូទៅថា ជាអ្នករំលោភសិទ្ធិមនុស្ស ដូចជាអារ៉ាប៊ីសាអ៊ូឌីត ចិន និងវ៉េណេស៊ុយអេឡាបានបម្រើ (ឬកំពុងបម្រើ) ជាសមាជិករបស់គណៈកម្មការសិទ្ធិមនុស្ស។ ម្យ៉ាងវិញទៀត អ្នកគាំទ្រអះអាងបានថា ក្រុមប្រឹក្សាសិទ្ធិមនុស្សមួយថ្មី គឺជាការកែលំអ ល្អជាងគណៈកម្មការមុន។ ពួកគេបានអះអាងថា ដំណើរការពិនិត្យឡើងវិញជាសកលតាមពេលវេលាកំណត់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលមានគោលបំណងវាយតម្លៃពីការបំពេញកាតព្វកិច្ចរបស់រដ្ឋជាសមាជិកនីមួយៗ គឺជាមធ្យោបាយដ៏មានប្រយោជន៍សម្រាប់ដោះស្រាយបញ្ហាសិទ្ធិមនុស្ស។ អ្នកសង្កេតការណ៍ជាច្រើនត្រូវបានលើកទឹកចិត្តឲ្យបង្កើនការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងចំពោះ ស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសដូចជាអ៊ីរ៉ង់ កូរ៉េខាងជើង និងស៊ីរី។[5] ហេតុនេះ មហាសន្និបាតអង្គការសហប្រជាជាតិបានសម្រេចបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្ស

[5] បកប្រែចេញពី Congressional Research Service សៀវភៅ The United Nations Human Rights Council: Background and Policy Issues Updated April 20 2020 ក្នុងសេចក្តីផ្តើម (Background) និងទំព័រ១-២ ព្រមទាំងអាចស្វែងរកបានតាមរយៈ https://fas.org/sgp/crs/row/RL33608.pdf (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

អង្គការសហប្រជាជាតិឡើងក្នុងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ តាមរយៈសេចក្តីសម្រេចរបស់មហាសន្និបាតលេខ A/RES/60/251ស្តីពីការបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦។

### ១.១.២. ការបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្ស ដោយមានវត្តមានការត្រួតពិនិត្យជាសកលតាមកាលកំណត់[6]

បំពេញបន្ថែមទៅលើចំណុចខាងលើ យន្តការដែលមានឈ្មោះចុងក្រោយថា "Periodic" (កាលកំណត់) ជំនួសឲ្យពាក្យ "Peer" (ចូលមកពិនិត្យ "come into view") គឺផ្អែកទៅលើគំនិតដែលថា រដ្ឋជាសមាជិកបានត្រួតពិនិត្យខ្លួនរបស់ពួកគេជំនួសឲ្យការត្រូវបានត្រួតពិនិត្យដោយអ្នកជំនាញឯករាជ្យ។ ហេតុដូចនេះ ការត្រួតពិនិត្យជាសកលតាមកាលកំណត់ខុសគ្នាជាមូលដ្ឋានពីស្ថាប័នសន្ធិសញ្ញា (Treaty Bodies)[7] ដែលការងាររបស់យន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់បំពេញបន្ថែម និងជាយន្តការពិសេសមួយគត់មិនចម្លងពីយន្តការផ្សេងទៀត ដែលមានក្នុងប្រព័ន្ធសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។[8] ដោយឡែក យន្តការដែលផ្អែកទៅលើសេចក្តីសម្រេចលេខ ១២៣៥ (XLII) របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមអង្គការសហប្រជាជាតិ (Economic and Social Council ហៅថា "ECOSOC") ធ្វើឲ្យមានភាពពិតជាធុញទ្រាន់នឹងភាពស្រដៀងគ្នាខ្លះនេះ ប៉ុន្តែយន្តការនេះត្រូវបានជ្រើសរើសជាង ប្រសិនបើប្រៀបធៀបនឹងយន្តការនៃការពិនិត្យជាសកលតាមកាលកំណត់។

---

[6] បកប្រែដោយដកស្រង់ចេញពីសៀវភៅដែលមានអ្នកនិពន្ធឈ្មោះ Maximilian Spohr "United Nations Human Rights Council Between Institution-Building Phase and Review of Status របស់ Max Plank Yearbook of United Nations Law ចាប់ពីទំព័រទី ១៦៩-២១៨ (ហូឡង់ ឆ្នាំ២០១០)" ទំព័រទី១៧៨ ដល់ ១៧៩ ហើយដែលអាចស្វែងរកបានតាមរយៈគេហទំព័រ https://www.mpil.de/files/pdf3/mpunyb_05_spohr_14.pdf (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

[7] ស្ថាប័នសន្ធិសញ្ញា ជាស្ថាប័នឃ្លាំមើលការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សស្នូល (មានសិទ្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់៩ និងពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម។ ស្ថាប័នសន្ធិសញ្ញា គឺជាគណៈកម្មការនៃអ្នកជំនាញឯករាជ្យ និងមានសមត្ថភាពឃ្លាំមើលសិទ្ធិមនុស្ស ដែលត្រូវបានគេទទួលស្គាល់ និងត្រូវបានតែងតាំង ព្រមទាំងបោះឆ្នោតជ្រើសរើសដោយរដ្ឋជាភាគីនៃសិទ្ធិសញ្ញាសម្រាប់អាណត្តិ ០៤ (បួន) ឆ្នាំ។

[8] ទោះបីជាយ៉ាងណា គំនិតនៃការឃ្លាំមើលការអនុវត្តគម្រោងសិទ្ធិមនុស្ស ដោយការពិនិត្យមើលរបាយការណ៍របស់រដ្ឋជាទៀងទាត់ ត្រូវបានគេដឹងរួចហើយអំពីការផ្តួចផ្តើមគំនិតរបស់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (CHR) ដោយសេចក្តីសម្រេចលេខ E / RES / 624 B (XXII) នៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម (ESOSOC) ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៥៦។ យោងតាមសេចក្តីសម្រេចនេះ រដ្ឋត្រូវមានកាតព្វកិច្ចបញ្ជូនរបាយការណ៍ស្តីពី វឌ្ឍនភាពក្នុងការអនុវត្តបទដ្ឋានសិទ្ធិមនុស្សនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសិទ្ធិក្នុងការសំរេចចិត្តខ្លួនឯង (អាចមើលបន្ថែមនូវ E / 2844-E / CN.4 / 731 និង E / RES / 1074 C (XXXIX) ចុះថ្ងៃទី ២៨ ខែកក្កដាឆ្នាំ ១៩៦៥ ស្តីពីការកែទម្រង់នីតិវិធី)។ ជាមួយនឹងការចូលជាធរមាននៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលបានផ្តល់សម្រាប់ការរាយការណ៍ គឺនីតិវិធីនៃការរាយការណ៍ឆ្នាំ ១៩៥៦ ក្លាយជាមានលក្ខណៈកាន់តែច្រើន ហើយត្រូវបានលុបបំបាត់ចោលជាយថាហេតុដោយសេចក្តីសម្រេចលេខ A / RES / 35/209 ចុះថ្ងៃទី ១៧ ខែធ្នូឆ្នាំ ១៩៨០។

តាមយន្តការនៃគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ មានតែរដ្ឋដែលត្រូវចោទប្រកាន់អំពីការរំលោភសិទ្ធិមនុស្ស ដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិប៉ុណ្ណោះ ដែលត្រូវបានដោះស្រាយដោយសេចក្ដីសម្រេចថ្កោលទោសពីគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (CHR) និងមហាសន្និបាតរបស់អង្គការសហប្រជាជាតិ។ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនបានមើលឃើញពីបញ្ហានេះ ថាជាអំពើអយុត្តិធម៌ ចាប់តាំងពីការតម្រូវនៃរដ្ឋជាច្រើនមិនត្រូវបានគេយកមកពិចារណាគ្រប់ជ្រុងជ្រោយ ពីព្រោះអាងតែលើការរាយការណ៍របស់អ្នករាយការណ៍ពិសេស។ ដោយសារតែមានការប្រឆាំងនឹងស្ថានភាពនេះ ការបង្កើតយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់មានគោលបំណង ពោលគឺ ក្នុងន័យដើម្បីដោះស្រាយការរិះគន់ផ្នែកនយោបាយ ដែលគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (CHR) ត្រូវបានគេរិះគន់ជាញឹកញាប់ ដោយការប្រើវិធីសាស្ត្រត្រួតពិនិត្យមើលរដ្ឋជាសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិ នៅក្នុងរយៈពេល០៤ ឆ្នាំ[9] ជៀសវាងនូវសំណួរនិន្នាខាងនយោបាយលើរបាយការណ៍ស្ដីពីសិទ្ធិមនុស្ស ដែលត្រូវបានពិនិត្យ។ លើសពីនេះទៀត មានន័យថា គ្រប់សមាជិកទាំងអស់នៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (HRC) ត្រូវបានពិនិត្យដូចៗគ្នា ដូច្នេះ ភាពសមាជិកមិនអាចត្រូវបានប្រើជាខែលប្រឆាំងនឹងការត្រួតពិនិត្យបញ្ជាក់អំពីស្ថានភាពសិទ្ធិមនុស្សនោះទេ។

## ១.២. គោលការណ៍ និងគោលដៅក្នុងការបង្កើតការត្រួតពិនិត្យជាសាកលតាមកាលកំណត់[10]

ការបង្កើតការត្រួតពិនិត្យជាសាកលតាមកាលកំណត់មាន**គោលការណ៍** (១.១) និង**គោលដៅ** (១.២) ក្នុងការបង្កើតដូចតទៅៈ

### ១.២.១. គោលការណ៍

យន្តការត្រួតពិនិត្យជាសាកលតាមកាលកំណត់នឹងត្រូវប្រើដើម្បីៈ

[9] តែពេលនេះមានរយៈពេល ៤.៥ (បួនឆ្នាំកន្លះ) ក្នុងមួយរដ្ឋ

[10] បកប្រែចេញពីសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៥/១ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ "បង្កើនស្ថាប័នរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (Institution-building of the United Nations Human Rights Council)" ចំណុចនិយាយពី (B. Principles and objectives) អាចស្វែងរកបានតាមរយៈ http://hrlibrary.umn.edu/iwraw/Inst-building-UN.pdf (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

(ក) លើកកម្ពស់ភាពជាសកលនូវការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមក ជាភាពដែលមិនអាចបំបែកចេញពីគ្នាបាន និងភាពទាក់ទងគ្នាទៅវិញទៅមករបស់សិទ្ធិមនុស្សទាំងអស់

(ខ) ធ្វើជាយន្តការសហប្រតិបត្តិការណ៍ផ្អែកលើព័ត៌មាន ដែលមិនលំអៀង និងដែលអាចទុក្ខចិត្តបាន ព្រមទាំងសហប្រត្តិបត្តិការណ៍ធ្វើកិច្ចពិភាក្សាជាអន្តរកម្ម

(គ) ធានាបាននូវការធានារ៉ាប់រងជាសកល និងការប្រព្រឹត្តដោយស្មើភាពគ្នា (Equal Treatment) នៃរដ្ឋទាំងអស់

(ឃ) ជាដំណើរការដែលមានការចូលរួមជាអន្តររដ្ឋាភិបាល ពីសំណាក់រដ្ឋជាសមាជិកស្ថិតនៅក្រោមការដឹកនាំ (United Nation Member-Driven ) ដោយអង្គការសហប្រជាជាតិ ហើយអនុវត្តនូវផែនការសកម្មភាពដោះស្រាយបញ្ហា ឬស្ថានភាពអាក្រក់ (action-oriented)

(ង) មានការចូលរួមពីប្រទេសដែលកំពុងត្រូវបានត្រួតពិនិត្យ

(ច) បំពេញ និងមិនចម្លងពីយន្តការសិទ្ធិមនុស្សដទៃទៀត ដូច្នេះ ជាការតំណាងឱ្យការបង្កើននូវតម្លៃមួយ

(ឆ) ត្រូវបានបង្កើតឡើងក្នុងគោលបំណងមួយ គឺដែលធ្វើឲ្យមានតម្លាភាព មិនមានការជ្រើសរើសមានការបកស្រាយបំភ្លឺ មិនប្រឈមមុខនឹងគ្នា និងមិនមានលក្ខណៈជាការធ្វើនយោបាយ

(ជ) មិនត្រូវដាក់បន្ទុកយ៉ាងធ្ងន់ហួសហេតុពេកដល់រដ្ឋដែលពាក់ព័ន្ធ ឬរបៀបវារៈរបស់ក្រុមប្រឹក្សា

(ឈ) មិនយូរនោះទេ យន្តការនេះគួរតែមាននូវភាពប្រាកដនិយម និងមិនស្រូបយកចំនួននៃពេលវេលាដែលវិសមាមាត្រ រួមទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ

(ញ) មិនត្រូវបន្ថយសមត្ថភាពរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សឡើយ នៅពេលដែលឆ្លើយតបទៅនឹងស្ថានភាពសិទ្ធិមនុស្សជាបន្ទាន់

(ដ) រួមបញ្ចូលទស្សនៈយេនឌ័រយ៉ាងពេញលេញ

(ឋ) ដោយគ្មានសេចក្តីលំអៀងចំពោះកាតព្វកិច្ច ដែលមាននៅក្នុងធាតុផ្សំ ដែលត្រូវបានផ្តល់ជាមូលដ្ឋាននៃការត្រួតពិនិត្យ ដែលនឹងយកមកគិតពិចារណាក្នុងកម្រិតនៃការអភិវឌ្ឍ និងភាពពិសេសនៃប្រទេស

(ឌ) ធានាឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់រួមទាំងភាគីអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នសិទ្ធិមនុស្សជាតិស្របទៅតាមសេចក្តីសម្រេចមហាសន្និបាតលេខ ៦០/២៥១ ចុះនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ និងសេចក្តីសម្រេចក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមឆ្នាំ ១៩៩៦/៣១ ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ១៩៩៦ ក៏ដូចជា សេចក្តីសម្រេចផ្សេងទៀតដែលក្រុមប្រឹក្សានេះអាចនឹងទាក់ទង។

### ១.២.២. គោលដៅ

គោលបំណងនៃការត្រួតពិនិត្យជាសាកលតាមកាលកំណត់មានគោលដៅដូចតទៅៈ

(ក) កែលំអស្ថានភាពសិទ្ធិមនុស្សនៅលើពិភពលោក

(ខ) បំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋ ការប្តេជ្ញាចិត្ត និងការវាយតំលៃអំពីការវិវត្តវិជ្ជមាន និងបញ្ហាប្រឈម ដែលរដ្ឋបានជួបប្រទះ

(គ) បង្កើនសមត្ថភាពរបស់រដ្ឋ និងជំនួយបច្ចេកទេសក្នុងការពិគ្រោះយោបល់ជាមួយរដ្ឋពាក់ព័ន្ធ ដោយមានការយល់ព្រមពីរដ្ឋនោះ

(ឃ) ចែករំលែកការអនុវត្តល្អៗ ក្នុងចំណោមរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀត

(ង) គាំទ្រដល់កិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស

(ច) លើកទឹកចិត្តលើកិច្ចសហប្រតិបត្តិការ និងការចូលរួមយ៉ាងពេញលេញជាមួយនឹងក្រុមប្រឹក្សាសិទ្ធិមនុស្សព្រមទាំងស្ថាប័នសិទ្ធិមនុស្សដទៃផ្សេងៗទៀត និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សផងដែរ។

## ១.៣. កាលកំណត់ និងលំដាប់លំដោយ

ការត្រួតពិនិត្យចាប់ផ្តើមអនុវត្តន៍ បន្ទាប់ពីការអនុម័តលើដំណើរការយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ លំដាប់នៃការត្រួតពិនិត្យឆ្លុះបញ្ចាំងអំពីគោលការណ៍ នៃសកលភាព និងការស្មើភាពគ្នា។ លំដាប់នៃការត្រួតពិនិត្យគួរតែត្រូវបានបង្កើតឡើងឱ្យបានឆាប់តាមដែលអាចធ្វើទៅបានដើម្បីអនុញ្ញាតឱ្យរដ្ឋរៀបចំខ្លួនទុកជាមុនឲ្យ បានជ្រុងជ្រោយ។ សមាជិករដ្ឋទាំងអស់នៃក្រុមប្រឹក្សាត្រូវបានត្រួតពិនិត្យ ក្នុងអាណត្តិនៃភាពជាសមាជិករបស់ខ្លួន។ សមាជិកដំបូងនៃក្រុមប្រឹក្សាជាពិសេសអ្នកដែលត្រូវបានជ្រើសតាំងសម្រាប់អាណត្តិ០១ ឬ ០២ឆ្នាំ គួរតែជារដ្ឋត្រូវបានត្រួតពិនិត្យជាមុន។ ការបញ្ចូលគ្នារវាងរដ្ឋជាសមាជិក និងរដ្ឋជាអ្នកសង្កេតការណ៍នៃក្រុមប្រឹក្សា គួរតែត្រូវបានពិនិត្យដូចគ្នា។ ការចែកចែកភូមិសាស្ត្រប្រកបដោយសមធម៌គួរតែត្រូវបានគោរព នៅក្នុងពេលជ្រើសរើសរដ្ឋសម្រាប់ពិនិត្យ។ រដ្ឋសមាជិក និងរដ្ឋជាអ្នកសង្កេតការណ៍ដំបូងដែលនឹងត្រូវបានត្រួតពិនិត្យនឹងត្រូវបានជ្រើសរើសដោយការចាប់ឆ្នោតជាចេញពីក្រុមប្រចាំតំបន់តាមមធ្យោបាយនីមួយៗ ដើម្បីជាវិធីធានាឱ្យមានការគោរពពេញលេញចំពោះការបែងចែកភូមិសាស្ត្រប្រកបដោយសមធម៌។ លំដាប់នៃអក្សរក្រមនឹងត្រូវបានចាប់ផ្តើមអនុវត្តជាមួយគ្រប់ប្រទេសដែលបានជ្រើសរើស លើកលែងតែប្រទេសផ្សេងទៀត ស្ម័គ្រចិត្តធ្វើជាអ្នកត្រូវបានគេត្រួតពិនិត្យមុន។

រយៈពេលរវាងវដ្តនៃការត្រួតពិនិត្យ គួរតែយកមកគិតពិចារណាអំពីភាពសមស្របហេតុផលនូវសមត្ថភាពរបស់រដ្ឋ ដើម្បីឲ្យរដ្ឋមានពេលគ្រប់គ្រាន់សម្រាប់ត្រៀមរៀបចំខ្លួន និងកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធដទៃទៀត ក្នុងការឆ្លើយតបនឹងសំណូមពរដែលបានមកក្នុងការត្រួតពិនិត្យ។ រយៈពេល នៃការត្រួតពិនិត្យសម្រាប់វដ្តទីមួយនឹងមានរយៈពេល ០៤(បួន)ឆ្នាំ កន្លះ[11]។

### ១.៤. វដ្តនៃការត្រួតពិនិត្យ

មកដល់ត្រឹមឆ្នាំ២០២០នេះ ការត្រួតពិនិត្យជាសាកលតាមកាលកំណត់បានធ្វើមកចំនួន ០៣ ជុំមកហើយ ពោលគឺជុំទី១ គិតពីឆ្នាំ (២០០៨-២០១១)[12] ជុំទី២ ចាប់ពីឆ្នាំ (២០១២-២០១៦) និងជុំទី៣ ផ្តើមធ្វើនៅឆ្នាំ២០១៧ ដល់ឆ្នាំ២០២២។ ក្រុមការងារត្រួតពិនិត្យប្រជុំគ្នាម្តងក្នុង០១វគ្គ មានរយៈពេល០២ សប្តាហ៍ ហើយមាន០៣ វគ្គក្នុង១ឆ្នាំ ដោយសរុបមក១ជុំ មាន១៤វគ្គ សម្រាប់ត្រួតពិនិត្យកំណត់ត្រាសិទ្ធិមនុស្សនៃសមាជិកអង្គការសហប្រជាជាតិ។[13] អាចមានវគ្គពិសេស នៅពេលដែលត្រូវការប្រជុំ តាមរយៈការស្នើសុំពីសមាជិកក្រុមប្រឹក្សាដោយមានការគាំទ្រពីសមាជិកម្នាក់១/៣ នៃសមាជិកក្រុមប្រឹក្សា។[14]

---

[11] បកប្រែចេញពីសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥/១ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ "បង្កើនស្ថាប័នរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (Institution-building of the United Nations Human Rights Council)" ចំណុចនិយាយពី (C. Periodicity and Order of the review) អាចស្វែងរកបានតាមរយៈ http://hrlibrary.umn.edu/iwraw/Inst-building-UN.pdf (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

[12] ជុំទី១មានរយៈពេល០៤ (បួន) ឆ្នាំ តាមអ្វីដែលបានចង្អុលបង្ហាញរបស់សេចក្តីសម្រេចលេខ ៥/១ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ ប៉ុន្តែនៅក្នុងគេហទំព័រនេះ https://www.ohchr.org/EN/HRBodies/UPR/Pages/CyclesUPR.aspx (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០) គេបានបញ្ជាក់ថាមានរយៈពេល ៤.៥ (បួនឆ្នាំកន្លះ)

[13] បកប្រែចេញពីគេហទំព័រ https://www.ohchr.org/EN/HRBodies/UPR/Pages/CyclesUPR.aspx (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)ស្តីពីវដ្តនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់

[14] បកប្រែចេញពីសេចក្តីសម្រេចរបស់មហាសន្និបាតលេខA/RES/60/251 ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ "ស្តីពីការបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (Human Rights Council)" ចំណុចទី១០ និងអាចស្វែងរកសេចក្តីសម្រេចនេះបានតាមរយៈគេហទំព័រ https://www2.ohchr.org/english/bodies/hrcouncil/docs/A.RES.60.251_En.pdf (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

# ជំពូកទី២ ស្ថាប័នដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យជាសកលតាមកាលកំណត់

## ជំពូកទី២ ស្ថាប័នដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យជាសកលតាមកាលកំណត់

ដើម្បីធ្វើឲ្យយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់កាន់តែជាយន្តការពិសេស ដែលអាចការពារព្រមទាំងកែលម្អសិទ្ធិមនុស្សបានទាន់ពេលវេលាទៀតនោះ ដោយសារកិច្ចសហប្រតិបត្តិការទាំងផ្នែកការអនុវត្ត និងទាំងជំនួយបច្ចេកទេស។ ហេតុដូចនេះ សូមលើកយកនូវស្ថាប័នជំនាញចំនួន ០៣ (បី) គឺ **ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ** (១) **ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ** (២) និង អង្គការមិនមែនរដ្ឋាភិបាល "**អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់** (UPR Info) (៣)"។

### ២.១. ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ( United Nations Human Right Council )[15]

ក្រុមប្រឹក្សាសិទ្ធិមនុស្ស ជាស្ថាប័នអន្តររដ្ឋាភិបាលចម្បងរបស់អង្គការសហប្រជាជាតិ ដែលទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស ជំនួសឲ្យគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (CHR) ចាប់តាំងពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ តែគណៈកម្មការសិទ្ធិមនុស្សត្រូវបានក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមអង្គការសហប្រជាជាតិស្នើសុំឲ្យលុបបំបាត់គណៈកម្មការនេះ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦ ពោលគឺដើម្បីឲ្យគណៈកម្មការនេះ បញ្ចប់ការងាររបស់ខ្លួននៅឯសម័យប្រជុំទី៦០។ ការបោះឆ្នោតជ្រើសរើសសមាជិកនៃក្រុមប្រឹក្សាសិទ្ធិមនុស្សដំបូង នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៦ ហើយកិច្ចប្រជុំជាលើកដំបូងរបស់ក្រុមប្រឹក្សានឹងត្រូវកោះប្រជុំនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៦។ មហាសន្និបាតនឹងត្រួតពិនិត្យស្ថានភាពក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងរយៈពេល ០៥ឆ្នាំម្តង។[16]

ក្រុមប្រឹក្សាសិទ្ធិមនុស្សមានទំនួលខុសត្រូវ ក្នុងការលើកកម្ពស់ការគោរពសិទ្ធិមនុស្សលើសកលលោក សម្រាប់ជាការការពារសិទ្ធិមនុស្សទាំងអស់ និងសេរីភាពជាមូលដ្ឋានសម្រាប់ប្រជាជាតិទាំងមូល។ មិនត្រឹមតែប៉ុណ្ណោះទេ ក្រុមប្រឹក្សាមួយនេះ គឺត្រូវតែប្រឈមមុខជាមួយនឹងស្ថានភាពនៃការរំលោភបំពានសិទ្ធិមនុស្ស រួមទាំងការរំលោភបំពានទ្រង់ទ្រាយធំ និងជាប្រព័ន្ធ ដោយបង្កើតនូវអនុសាសន៍តបទៅនឹងការរំលោភបំពានដែលកើតមានឡើងទាំងនោះ។ ហើយក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ក៏ត្រូវតែលើកកម្ពស់កិច្ចសហប្រតិបត្តិការណ៍យ៉ាងមានប្រសិទ្ធភាព និងបញ្ជ្រាបសិទ្ធិមនុស្សទាំងអស់ទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ។

---

[15] បកប្រែចេញពីសេចក្តីសម្រេចរបស់មហាសន្និបាត លេខA/RES/60/251 ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ "ស្តីពីការបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (Human Rights Council)" ចំណុចទី១ ២ ៣ ៤ ទំព័រទី២ អាចស្វែងរកបានតាមរយៈគេហទំព័រ https://www2.ohchr.org/english/bodies/hrcouncil/docs/A.RES.60.251_En.pdf (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

[16] https://www.refworld.org/publisher,UNCHR,,,50ffbce59d,,0.html ស្តីអំពី គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (UN Commission on Human Rights) (ចូលមើលថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០)

បន្ថែមពីលើនេះទៀត ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក៏ត្រូវដឹកនាំដោយយកនូវគោលការណ៍នៃភាពជាសកល ភាពមិនលំអៀង វត្ថុវិស័យភាព និងគ្មានការជ្រើសរើសសម្រិតសម្រាំង ព្រមទាំងកសាងការពិភាក្សាជាអន្តរជាតិ និងសហប្រត្តិបត្តិការជាមួយនឹងការពិនិត្យមួយដើម្បីធ្វើឲ្យប្រសើរឡើងនូវការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សទាំងអស់ រួមមានសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ចសិទ្ធិសង្គម និងសិទ្ធិវប្បធម៌ ព្រមជាមួយនឹងសិទ្ធិដើម្បីអភិវឌ្ឍផងដែរ។

ក្រុមប្រឹក្សាសិទ្ធិមនុស្សត្រូវអនុវត្តវិធាននៃនីតិវិធី ដែលបានបង្កើតឡើងសម្រាប់គណៈកម្មាធិការនានា នៃមហាសន្និបាត និងដែលអាចអនុវត្តទៅបាន លុះត្រាតែមានសេចក្តីសម្រេចផ្សេងពីនេះ ដោយមហាសន្និបាត ឬក្រុមប្រឹក្សា។ លើសពីនេះទៀត ការចូលរួម និងពិគ្រោះយោបល់ជាមួយអ្នកសង្កេតការណ៍ រួមទាំងរដ្ឋដែលមិនមែនជាសមាជិក ភ្នាក់ងារឯកទេស អង្គការអន្តររដ្ឋាភិបាល និងស្ថាប័នសិទ្ធិមនុស្សជាតិ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលត្រូវផ្អែកលើការរៀបចំ ដែលមានក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមឆ្នាំ ១៩៩៦/៣១ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ១៩៩៦ និងការអនុវត្តដែលធ្លាប់សង្កេតឃើញដោយគណៈកម្មការសិទ្ធិមនុស្ស។ ទន្ទឹមនឹងការធានាការចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពបំផុតរបស់ស្ថាប័នទាំងនេះ។ ក្រុមប្រឹក្សាត្រូវមាននូវតម្លាភាព យុត្តិធម៌ និងមិនលំអៀង ព្រមទាំងបើកឱ្យមានការសន្ទនាត្រង់ទៅត្រង់មក គឺជាលទ្ធផលតម្រង់ទិសដែលអនុញ្ញាតឲ្យមាននូវការតាមដានការពិភាក្សាជាបន្តបន្ទាប់ ដើម្បីផ្តល់ជាអនុសាសន៍ និងពិនិត្យមើលការអនុវត្តរបស់ពួកគេ ព្រមទាំងអនុញ្ញាតឱ្យមានការធ្វើការងារជួយគ្នាទៅវិញទៅមកយ៉ាងទៀងទាត់ជាមួយនីតិវិធីពិសេស និងយន្តការផ្សេងៗទៀត។ ជាមួយគ្នានេះដែរនឹង ដើម្បីបានស្គាល់កាន់តែច្បាស់អំពី ក្រុមប្រឹក្សាសិទ្ធិមនុស្សនោះ សូមលើកឡើងដោយសង្ខេបនូវភាពជា**សមាជិក** (១.១) ដែលត្រូវបានជ្រើសរើស និង**រចនាសម្ព័ន្ធដែលគាំទ្រដល់ដំណើរនៃការប្រព្រឹត្តទៅ** (១.២) ដូចតទៅនេះ ៖

### ២.១.១. សមាជិកភាព[17]

ក្រុមប្រឹក្សាសិទ្ធិមនុស្សមានរដ្ឋជាសមាជិក ៤៧ ប្រទេសដែលជួបប្រជុំយ៉ាងតិច ០៣ ដង/ឆ្នាំ ក្នុងទីក្រុងហ្សឺណែវ ប្រទេសស្វីស។ ក្រុមប្រឹក្សាសិទ្ធិមនុស្សបំពេញមុខងារតាមរយៈការបោះឆ្នោតជ្រើសរើសរៀងរាល់ ០៣ឆ្នាំម្តង រដ្ឋជាសមាជិករបស់ក្រុមប្រឹក្សាគឺ ពិភាក្សា ចាត់វិធានការ ព្រមទាំងអនុម័តសេចក្តីសម្រេចដែលមាននៅក្នុង

[17] បកប្រែចេញពីសេចក្តីសម្រេចរបស់មហាសន្និបាត លេខA/RES/60/251 ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ "ស្តីពីការបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (Human Rights Council)" ចំណុចទី៧-១៤ ទំព័រទី២ អាចស្វែងរកបានតាមរយៈគេហទំព័រ https://www2.ohchr.org/english/bodies/hrcouncil/docs/A.RES.60.251_En.pdf (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

របៀបវារៈជាធរមាន (ចំនួនដប់របៀបវារៈ)។ នៅពេលដែលបញ្ចប់អាណត្តិនៅក្នុងរយៈពេល០៣ ឆ្នាំ សមាជិកទាំងនោះ មានសិទ្ធិបោះឆ្នោតភ្លាមៗម្តងទៀតវិញបាន ក្រោយពេល ០២អាណត្តិតជាប់គ្នាបានបញ្ចប់។ សមាជិកទាំងនេះត្រូវបានជ្រើសរើសដោយការបោះឆ្នោះដោយផ្ទាល់ និងម្តងម្នាក់ៗដោយប្រើសន្លឹកឆ្នោតសម្ងាត់ និងជ្រើសរើសដោយសម្លេងភាគច្រើនរបស់រដ្ឋជាសមាជិកនៃមហាសន្និបាតអង្គការសហប្រជាជាតិ។ សមាជិកទាំងនោះ ត្រូវបានជ្រើសរើសដោយបែងចែកទៅតាមភូមិសាស្ត្រប្រកបដោយសមភាព។ កៅអី នៃភាពជាសមជិកទាំងនោះត្រូវបានបែងចែកដូចតទៅ ក្រុមប្រទេសបែកអាហ្វ្រិក មានកៅអីចំនួន១៣ កៅអី ក្រុមប្រទេសប៉ែកអាស៊ី មាន ១៣ កៅអី ក្រុមប្រទេសប៉ែកអឺរ៉ុបខាងកើត មាន០៦ កៅអី ក្រុមប្រទេសខាងអាមេរិកឡាទិន មាន ០៨ និងក្រុមប្រទេសប៉ែកអឺរ៉ុប និងប្រទេសដទៃទៀតមានចំនួន ០៧ កៅអី។

ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបើកចំហទៅកាន់រដ្ឋទាំងអស់ ដែលជាសមាជិកនៃអង្គការសហប្រជាជាតិ។ នៅពេលបោះឆ្នោតរើសសមាជិកក្រុមប្រឹក្សាសមាជិក សមាជិកទាំងអស់នឹងត្រូវគិតពិចារណានូវការរួមចំណែករបស់បេក្ខជនចំពោះការផ្សព្វផ្សាយ ការការពារសិទ្ធិមនុស្ស និងការសន្យាដោយស្ម័គ្រចិត្ត ព្រមទាំងការប្តេជ្ញាចិត្ត ដែលបានសន្យានៅពេលបោះឆ្នោត។ ដោយមានសំឡេងចាប់ពីភាគច្រើន ២/៣ នៃសមាជិកដែលមានវត្តមាន មហាសន្និបាតនឹងធ្វើការបោះឆ្នោត តែអាចពន្យារសិទ្ធិនៃសមាជិកភាពនៅក្នុងក្រុមប្រឹក្សាបាន នៅពេលដែលសមាជិកនៃក្រុមប្រឹក្សាបានប្រព្រឹត្តនូវការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងជាលក្ខណៈប្រព័ន្ធ។ សមាជិកដែលត្រូវបានជ្រើសរើសជាសមាជិកក្រុមប្រឹក្សាសិទ្ធិមនុស្សនឹងត្រូវគាំទ្រ ក្នុងកម្រិតស្តង់ដារខ្ពស់បំផុតក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ដែលត្រូវមានលក្ខណៈពេញលេញនូវសហការជាមួយក្រុមប្រឹក្សា ព្រមទាំងត្រូវបានត្រួតពិនិត្យក្រោមការត្រួតពិនិត្យតាមកាលជាសកលកំណត់ផងដែរ បើទោះបីជារដ្ឋទាំងនោះជាសមាជិកនៃក្រុមប្រឹក្សាក្នុងអាណត្តិរបស់ខ្លួនក៏ដោយ។

### ២.១.២. អង្គការបុត្រសម្ព័ន្ធ នៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ[18]

ក. **អង្គការបុត្រសម្ព័ន្ធ**របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ មានយន្តការ ០៣ (បី) ដូចតទៅ៖

- ការត្រួតពិនិត្យជាសាកលតាមកាលកំណត់
- គណៈកម្មាធិការសម្រាប់ពិគ្រោះយោបល់

[18] បកប្រែចេញពីគេហទំព័រ https://www.ohchr.org/EN/HRBodies/HRC/Pages/OtherSubBodies.aspx ស្តីពីរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

- នីតិវិធីបណ្តឹង

យន្តការទាំងអស់នៃអង្គការបុត្រសម្ព័ន្ធ គឺជាអ្នករាយការណ៍ដោយផ្ទាល់ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សអន្តរជាតិ។

**ខ. យន្តការជំនាញបុត្រសម្ព័ន្ធ**

- យន្តការជំនាញស្តីពីសិទ្ធិជនជាតិដើម
- វេទិកាស្តីពីបញ្ហាជនជាតិភាគតិច
- វេទិកាសង្គម
- វេទិកាស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស
- វេទិកាស្តីពីសិទ្ធិមនុស្សប្រជាធិបតេយ្យនិងនីតិរដ្ឋ

ក្រុមប្រឹក្សានេះក៏បានបង្កើតនូវយន្តការជំនាញខាងផ្នែកបុត្រសម្ព័ន្ធ ដើម្បីផ្តល់ជូនក្រុមប្រឹក្សាជាមួយនឹងអ្នកជំនាញខាងវិស័យ និងវេទិកាដែលផ្តល់នូវកម្មវិធីសម្រាប់ការសន្ទនា និងកិច្ចសហប្រតិបត្តិការ។ ស្ថាប័នទាំងនេះផ្តោតចម្បងទៅលើការសិក្សាដំបូន្មានផ្អែកលើការស្រាវជ្រាវ ឬ ការអនុវត្តល្អបំផុត។ ពួកគេជួបប្រជុំ និងរាយការណ៍ជារៀងរាល់ឆ្នាំទៅក្រុមប្រឹក្សា។

**គ. ក្រុមការងារអន្តររដ្ឋាភិបាលដែលមិនមានដែនកំណត់**

- ក្រុមការងារស្តីពីសិទ្ធិអភិវឌ្ឍន៍
- ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីសេចក្តីប្រកាសឌុរប៊ែន និងកម្មវិធីសកម្មភាព
- ក្រុមការងារស្តីពីពិធីសារជម្រើសនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ
- គណៈកម្មាធិការអាដហុកស្តីពីការធ្វើឱ្យប្រសើរឡើងនៃស្តង់ដារបំពេញបន្ថែម
- ក្រុមការងារអន្តររដ្ឋាភិបាលគ្មានដែនកំណត់ ដែលធ្វើការលើសេចក្តីព្រាងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការអប់រំ និងបណ្តុះបណ្តាលសិទ្ធិមនុស្ស
- ក្រុមការងារអន្តររដ្ឋាភិបាលគ្មានដែនកំណត់ធ្វើការលើពីក្របខណ្ឌបទប្បញ្ញត្តិនៃសកម្មភាពរបស់ក្រុមហ៊ុនយោធាឯកជន និងសន្តិសុខ
- ក្រុមការងារអន្តររដ្ឋាភិបាលគ្មានដែនកំណត់ ធ្វើការលើសេចក្តីព្រាងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិសន្តិភាព
- ក្រុមការងារអន្តររដ្ឋាភិបាលគ្មានដែនកំណត់ ធ្វើការលើស្តីពីសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់កសិករ និងប្រជាជនដទៃទៀតដែលធ្វើការនៅតំបន់ជនបទ

- ក្រុមការងារអន្តររដ្ឋាភិបាលគ្មានដែនកំណត់ធ្វើការលើស្តីពីសាជីវកម្មឆ្លងដែន និងសហគ្រាសធុរកិច្ចដទៃទៀតដោយគោរពសិទ្ធិមនុស្ស។

ក្រុមប្រឹក្សាបានបង្កើតក្រុមការងារអន្តររដ្ឋាភិបាលដែលអត់ដែនកំណត់ដូចខាងលើ ដើម្បីបរិយាយ និង / ឬ ជជែករកខុសរកត្រូវ និងបញ្ចប់សេចក្តីព្រាងច្បាប់ថ្មី ឬ ដើម្បីផ្តល់អនុសាសន៍ស្តីពីការអនុវត្តឧបករណ៍ដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព។

## ២.២. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

( United Nations Office of High Commissioner )

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (UN Human Right) គឺជាអង្គភាពឈានមុខគេរបស់អង្គការសហប្រជាជាតិផ្នែកសិទ្ធិមនុស្ស ដែលទទួលខុសត្រូវក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ។ មហាសន្និបាតបានប្រគល់អំណាចឲ្យទាំងឧត្តមស្នងការ (អ្នកដឹកនាំក្នុងការិយាល័យនេះ) និងការិយាល័យ ដោយមានអាណត្តិពិសេសមួយ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សសម្រាប់ប្រជាជនក្នុងតំបន់ទាំងអស់ ដែលការិយាល័យនេះតាំងនៅ។ កម្មវិធីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិមានគោលបំណងធានាថាការការពារ និងការទទួលបានសិទ្ធិមនុស្សគឺជាការពិតនៅក្នុងជីវិតរបស់ប្រជាជនទាំងអស់។ សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរ ក្នុងការការពារសេចក្តីទៀងត្រង់នៃចំណងទាក់ទងគ្នាទាំងបីរបស់អង្គការសហប្រជាជាតិពោលគឺ សន្តិភាព សន្តិសុខ និងសិទ្ធិមនុស្ស និងការអភិវឌ្ឍ។

សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិផ្តល់ជំនួយបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាព ដើម្បីគាំទ្រដល់ការអនុវត្តស្តង់ដារសិទ្ធិមនុស្សអន្តរជាតិនៅលើពិភពលោក។ ការិយាល័យនេះក៏ជួយរដ្ឋាភិបាលដែរ តាមរយៈការទទួលខុសត្រូវចម្បងក្នុងការការពារសិទ្ធិមនុស្សសម្រាប់បំពេញកាតព្វកិច្ច និងគាំទ្របុគ្គលម្នាក់ៗដើម្បីទាមទារសិទ្ធិរបស់ពួកគេ។ លើសពីនេះទៅទៀត ការិយាល័យនេះក៏ហ៊ាននិយាយប្រឆាំងដោយក្លាហានអំពីការរំលោភសិទ្ធិមនុស្សទៀតផង។

### ២.២.១. រចនាសម្ព័ន្ធ សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ

ចំពោះរចនាសម្ព័ន្ធ សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ គឺជាផ្នែកមួយនៃលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិដែលមានបុគ្គលិកប្រហែល ១៣០០ (មួយពាន់បីរយ)នាក់ និងទីស្នាក់ការកណ្តាលរបស់

ខ្លួននៅទីក្រុងហ្សឺណែវ ក៏ដូចជាការិយាល័យនៅញូវយ៉ក។[19] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) នេះ ក៏ជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិផងដែរ។ [20] បន្ថែមពីលើនេះ ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សផ្ញើរបាយការណ៍របស់ខ្លួនទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សដើម្បីអនុម័តសម្រេច។ ការិយាល័យនេះក៏មានវត្តមាននៅប្រចាំតំបន់ និងប្រទេស / ការិយាល័យដាច់ដោយឡែក។ លើសពីនេះទៀត ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិគាំទ្រសមាសសភាពសិទ្ធិមនុស្ស នៃបេសកកម្មសន្តិភាពរបស់អង្គការសហប្រជាជាតិ ឬ ការិយាល័យនយោបាយ និងពង្រាយទីប្រឹក្សាសិទ្ធិមនុស្សផ្សេងៗ ដើម្បីធ្វើការជាមួយក្រុមប្រទេសរបស់អង្គការសហប្រជាជាតិ។

### ២.២.២. ទីស្នាក់ការកណ្ដាលរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ

ទីស្នាក់ការកណ្ដាលទីក្រុងហ្សឺណែវមានការបែងចែកចំនួនផ្នែកទទួលបន្ទុក ០៣ (បី) សំខាន់ៗគឺៈ

- ការចូលរួមតាមវិស័យនៃនិតិវិធីពិសេស និងសិទ្ធិទទួលបានផ្នែកអភិវឌ្ឍន៍ (Thematic Engagement Special Procedures and Right to Development Division ហៅកាត់ថា TESPRDD) ដែលបង្កើតគោលនយោបាយ និងផ្ដល់ការណែនាំនូវមធ្យោបាយនៃការផ្ដល់យោបល់ ព្រមទាំងការគាំទ្រការពង្រឹងសមត្ថភាពលើបញ្ហាសិទ្ធិមនុស្សតាមប្រធានបទរួម សម្រាប់គោលបំណងបញ្ជ្រាបសិទ្ធិមនុស្ស និងផ្ដល់ការគាំទ្រដល់នីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។
- ផ្នែកសិទ្ធិមនុស្ស និងផ្នែកយន្តការនៃសន្ធិសញ្ញា (Council and Treaty Mechanism Division ហៅកាត់ថា CTMD) ដែលផ្ដល់ការគាំទ្រផ្នែកដែលវិជ្ជមាន និងបច្ចេកទេសទៅដល់ក្រុមប្រឹក្សាសិទ្ធិ និងយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់របស់ក្រុមប្រឹក្សា និងគាំទ្រអង្គភាពសន្ធិសញ្ញាសិទ្ធិមនុស្ស។
- ការបែងចែកផ្នែកប្រតិបត្តិការ និងសហប្រតិបត្តិការផ្នែកបច្ចេកទេស (Field Operations and Technical Cooperation Division ហៅកាត់ថា FOTCD) ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងអនុវត្តការងាររបស់ការិយាល័យនៅក្នុងវិស័យនេះ។

---

[19] បកប្រែចេញពីគេហទំព័រ https://www.ohchr.org/EN/AboutUs/Pages/WhoWeAre.aspx ស្ដីពីយើងជាអ្នកណារបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

[20] ដកស្រង់ចេញពីគេហទំព័រ https://cambodia.ohchr.org/kh/about-us/who-we-are "យើងជាអ្នកណា" របស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិប្រចាំកម្ពុជា (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

សេវាកម្ម និងផ្នែកនានា ដែលរាយការណ៍ដោយផ្ទាល់ទៅអគ្គស្នងការរងទទួលបន្ទុកគ្រប់គ្រងស្នូលផែនការការសម្របសម្រួល និងមុខងារផ្សព្វផ្សាយ។[21]

## ៣. អង្គការព័ត៌មានអំពីយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR Info)

អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR Info) គឺជាអង្គការមិនរកប្រាក់ចំណេញ និងជាអង្គការមិនមែនរដ្ឋាភិបាល មានការិយាល័យកណ្ដាល នៅប្រទេសស្វីស នៅទីក្រុងហ្សឺណែវ និងមានការិយាល័យប្រចាំតំបន់នៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា។ អង្គការនេះ បានបង្កើតឡើងដោយលក្ខន្តិកៈនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលត្រូវកែប្រែនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧។ អង្គការនេះកំពុងធ្វើការងារដើម្បីលើកកម្ពស់និងពង្រឹងការពិនិត្យជាសកលតាមកាលកំណត់តាមគ្រប់មធ្យោបាយ នៅពេលក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិយល់ថាចាំបាច់។[22] អង្គការនេះមានគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងអំពីការត្រួតពិនិត្យជាសកល និងផ្ដល់នូវយន្តការមួយសម្រាប់ពង្រឹងសមត្ថភាពដល់អ្នកដែលពាក់ព័ន្ធទាំងអស់ដូចជា រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ស្ថាប័នសិទ្ធិមនុស្សជាតិ (National Human Right Institutiion) សមាជិកសភា សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសិក្សា។

អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR Info) មានចំណុចផ្ដោតសំខាន់០៥ (ប្រាំ)យ៉ាង៖

- **ការកសាងសមត្ថភាព** អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ គឺជាមជ្ឈមណ្ឌលនៃឧត្តមភាពសម្រាប់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងស្វែងរកការចែករំលែកជំនាញរបស់ខ្លួនជាមួយនឹងភាគីពាក់ព័ន្ធទាំងអស់របស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់។ បន្ថែមទៅលើសិក្ខាសាលាបណ្ដុះបណ្ដាល និងការបោះពុម្ពផ្សាយ អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ផ្ដល់ជូននូវពិភពលោកនូវការចូលទៅកាន់យន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ តាមរយៈគេហទំព័ររបស់ខ្លួន។

---

[21] បកប្រែចេញពីគេហទំព័រ https://www.ohchr.org/EN/AboutUs/Pages/WhoWeAre.aspx ស្ដីពីយើងជាអ្នកណារបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

[22] បកប្រែចេញពីគេហទំព័រ https://www.upr-info.org/sites/default/files/uprinfo-geneva_statutes_en.pdf របស់អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ "ស្ដីពីលក្ខន្តិកៈUPR info" ឆ្នាំ២០១៧ មាត្រា៣ (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០

- **ការលើកកម្ពស់ការយល់ដឹង** អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ធ្វើការ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងចូលរួមតាមរយៈគោលនយោបាយនៃការពិភាក្សា ដើម្បីពង្រឹងយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់។
- **វគ្គមុនសម័យប្រជុំ** វគ្គមុនសម័យប្រជុំរបស់អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ផ្ដល់ជូនអង្គការសង្គមស៊ីវិលនូវវេទិការតស៊ូមតិជាយុទ្ធសាស្ត្រ ដើម្បីដោះស្រាយបញ្ហាសិទ្ធិមនុស្សដែលបានប៉ះពាល់ដល់ប្រទេសរបស់ពួកគេ។ កម្មវិធីនេះធានានូវរាល់បញ្ហាសិទ្ធិមនុស្ស និងសំលេងរបស់ក្រុមដែលបាត់ឱកាស គឺត្រូវបានពិភាក្សាមុនពេលធ្វើការត្រួតពិនិត្យនៅទីក្រុងហ្សឺណែវ។ វគ្គមុនសម័យប្រជុំនាំអង្គការសង្គមស៊ីវិល ស្ថាប័នសិទ្ធិមនុស្សជាតិ និងរដ្ឋដែលផ្ដល់អនុសាសន៍ទាំងអស់នូវឥទ្ធិពលរបស់អនុសាសន៍ នៅពេលដែលអនុសាសន៍ទាំងអស់នោះត្រូវបានលើកឡើងជាលំដាប់នាពេលប្រជុំក្រុមការងារត្រួតពិនិត្យ (Woking Group Session)។
- **ទិន្នន័យ នៃអនុសាសន៍របស់អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR Info)** ផ្ទុកនូវរាល់អនុសាសន៍របស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងផ្ដល់នូវមធ្យោបាយវិភាគ ព្រមទាំងស្ថិតិដើម្បីលើកកម្ពស់ការដឹកនាំការអនុវត្ត។
- **កម្មវិធីនៅក្នុងប្រទេស** អង្គការព័ត៌មានអំពីការត្រួតពិនិត្យធ្វើការនៅថ្នាក់ជាតិនៅក្នុងប្រទេសជាដៃគូដែលត្រូវបានជ្រើសរើសជាគូគ្នា ដើម្បីគាំទ្រដល់ការចូលរួមរបស់តួអង្គនៃរដ្ឋនៅក្នុងយន្តការនៃការត្រួតពិនិត្យ។ កម្មវិធីនេះ ចូលរួមចំណែកក្នុងការបង្កើត និងការជួយឲ្យទៅមុខនូវក្របខ័ណ្ឌការត្រួតពិនិត្យជាសកលតាមកាលកំណត់ដែលរួមមាន៖ ប្រព័ន្ធតាមដានសិទ្ធិមនុស្សជាតិរឹងមាំ សម្ព័ន្ធភាពសង្គមស៊ីវិលទូទាំងប្រទេសដែលចូលរួមជាមួយការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងភាពជាដៃគូប្រកបដោយអត្ថន័យរវាងអង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាល។ ជាពិសេសកម្មវិធីនេះរួមមានជំហានទាំង ០៥ ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក បានផ្ដល់នូវឱកាសពិសេស សម្រាប់អ្នកចូលរួមក្នុងការលើកកម្ពស់នូវចំណេះដឹងរបស់ពួកគេ អំពីការត្រួតពិនិត្យជា សកលតាមកាលកំណត់ និងបង្កើតយុទ្ធសាស្ត្រស្ដីពីការអនុវត្ត អនុសាសន៍ដែលបានកំណត់ដោយយន្តការត្រួតពិនិត្យមួយនេះ។ ជំហាននីមួយៗត្រូវបានរៀបចំឡើងយ៉ាងយកចិត្តទុកដាក់ ក្នុងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយដៃគូជាតិដើម្បីដោះស្រាយតម្រូវការជាក់ស្ដែង នៅក្នុងប្រទេស។ អង្គការនេះក៏ជម្រុញនូវវិធីសាស្ត្រសហការ និងរួមបញ្ចូលគ្នារវាងអ្នកពាក់ព័ន្ធរបស់ការត្រួតពនិត្យជាសកលតាមកាលកំណត់។[23]

---

[23] បកប្រែចេញពីគេហទំព័រ https://www.upr-info.org/en ស្ដីពី យើងជាអ្នកណា "Who we are" របស់អង្គភាពព័ត៌មាន នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

សូមបញ្ជាក់ថា អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR Info) ស្ថិតនៅក្នុងស្ថានភាពពិគ្រោះយោបល់ពិសេសជាមួយនឹងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម របស់អង្គការសហប្រជាជាតិ (ECOSOC)ផងដែរ។[24]

[24] បកប្រែចេញពីគេហទំព័រ https://www.upr-info.org/en/about/activities ស្តីអំពីសកម្មភាព "Activities" របស់អង្គភាពព័ត៌មាន នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់

# ជំពូកទី៣ ដំណើរការនៃការត្រួតពិនិត្យ ជាសកលតាមកាលកំណត់

## ជំពូកទី៣ ដំណើរការនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់

ដូចដែលបានបញ្ជាក់រួចមកផងដែរថា ការត្រួតពិនិត្យជាសកលតាមកាលកំណត់ជាយន្តការមួយសម្រាប់ការត្រួតពិនិត្យស្ថានភាពសិទ្ធិមនុស្សនៅលើពិភពលោក។ ដូច្នេះ ដើម្បីបានដឹងពីដំណើរនៃយន្តការនេះឲ្យកាន់តែច្បាស់ សូមធ្វើការបែងចែងដំណាក់កាលនៃការត្រួតពិនិត្យជា ០៣ ដំណាក់កាលធំៗ ដែលមានដូចជា៖ **វគ្គមុនសម័យប្រជុំ** (Pre-session) (១) **សម័យប្រជុំ** (២) និង**ការតាមដានការអនុវត្តអនុសាសន៍** (Implementation) (៣)។

### ៣.១. វគ្គមុនសម័យប្រជុំ

វគ្គមុនសម័យប្រជុំ គឺជាសន្និសីទសិទ្ធិមនុស្ស ដែលបង្កើតឡើងជាពិសេសសម្រាប់ប្រទេសមួយ។ វគ្គមុនសម័យប្រជុំត្រូវបានរៀបចំឡើងដោយអង្គភាពព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងប្រព្រឹត្តទៅនៅទីក្រុងហ្សឺណែវ។ វគ្គមុនសម័យប្រជុំមានរយៈមួយម៉ោង។[25]

សង្គមស៊ីវិលដើរតួយ៉ាងសំខាន់ក្នុងយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដូចដែលត្រូវបានទទួលស្គាល់យ៉ាងច្បាស់នៅក្នុងសេចក្ដីសម្រេច ៥/១។ តាមរយៈវដ្តទី ២ នេះអង្គការសង្គមស៊ីវិលបានរិះរកវិធីជាច្រើនដើម្បីចូលរួមក្នុងដំណើរការនេះ និងមានឥទ្ធិពលលើលទ្ធផលរបស់យន្តការនេះ។ ដោយមានការរៀបចំចំនួន ០៣ដងក្នុងមួយឆ្នាំនៅទីក្រុងហ្សឺណែវសន្និសីទអន្តរជាតិមួយនេះបានក្លាយជាផ្នែកសំខាន់មួយនៃដំណើរការរបស់យន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ ពីព្រោះតែយន្តការនេះបានផ្តល់នូវឱកាសពិសេសមួយសម្រាប់អង្គការសង្គមស៊ីវិលក្នុងការសង្ខេបស្តីពី ស្ថានភាពសិទ្ធិមនុស្សនៅក្នុងរដ្ឋដែលកំពុងត្រូវបានត្រួតពិនិត្យ។ វគ្គមុនសម័យប្រជុំអាចត្រូវបានគេចាត់ទុកថា ជាវេទិកាសង្គមស៊ីវិលធំបំផុតសម្រាប់ការតស៊ូមតិផ្នែកសិទ្ធិមនុស្សនៅក្នុងពិភពលោក។[26]

---

[25] ដកស្រង់ចេញពី https://www.upr-info.org/en/upr-process/pre-sessions/frequently-asked-questions ស្តីពីសំណួរដែលមានគេសួរជាញឹកញាប់អំពីវគ្គមុនសម័យប្រជុំ (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០២០)

[26] បកប្រែដោយដកស្រង់ចេញពីសេចក្តីផ្តើម នៃសៀវភៅដែលមានគេហទំព័រ https://www.upr-info.org/sites/default/files/general-document/pdf/2016_pre-sessions_empowering_human_rights_voices_from_the_ground.pdf ស្តីពី ការឲ្យអំណាចសំឡេងសិទ្ធិមនុស្សតាំងពីថ្នាក់ក្រោម "Empowering human rights voice from the ground" របស់ UPR Info (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០២០)

### ៣.១.១. ប្រវត្តិ

វគ្គមុនសម័យប្រជុំត្រូវបានដាក់ចេញបង្ហាញទៅកាន់ពិភពលោកនៅឆ្នាំ ២០១២ នៅដើមនៃវដ្តទី ២ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់។ អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ដឹងយ៉ាងច្បាស់ថា រចនាសម្ព័ន្ធផ្លូវការរបស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់បានកំណត់វិសាលភាព ដែលសង្គមស៊ីវិលអាចចូលរួមចំណែកយ៉ាងស្វាហាប់ជាមួយនឹងយន្តការត្រួតពិនិត្យសិទ្ធិមនុស្សតែមួយគត់មួយនេះ។ មធ្យោបាយចម្បងរបស់អង្គការសង្គមស៊ីវិលក្នុងចូលរួមប្រមូលព័ត៌មានសម្រាប់ការត្រួតពិនិត្យជាសកលតាមកាលកំណត់គឺ ដោយការរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរដាក់ជូនភាគីពាក់ព័ន្ធ ដែលនឹងត្រូវដាក់ឲ្យពិនិត្យសម្រេចពី ៦ ទៅ ៧ខែមុនការពិនិត្យកាលបរិច្ឆេទត្រួតពិនិត្យរបស់រដ្ឋ។ នេះមានន័យថា មានព័ត៌មានដែលទុកចោលអស់រយៈពេលជាច្រើនខែរវាងកាលបរិច្ឆេទនៃការដាក់ឲ្យពិនិត្យសម្រេច និងកាលបរិច្ឆេទនៃការត្រួតពិនិត្យ ដែលការអភិវឌ្ឍសិទ្ធិមនុស្សសំខាន់ៗមិនអាចត្រូវបានលើកឡើងនោះទេ។ បើនិយាយអំពីខ្លឹមសារនៃការដាក់ពិនិត្យសម្រេចវិញការកម្រិតពាក្យតឹងរឹង (ត្រូវសរសេរចំនួន ២ ៨១៥ ពាក្យ ទៅ៥ ៦៣០ ពាក្យ ទាំងសម្រាប់ការដាក់ឲ្យពិនិត្យសម្រេចជាលក្ខណៈបុគ្គល និងរួមគ្នា) ព្រមទាំងកំណត់កំរិត នៃការលម្អិត ដែលអង្គការសង្គមស៊ីវិលអាចផ្តល់ផងដែរ។ លើសពីនេះទៀតបរិមាណដ៏ធំនៃព័ត៌មានដែលទទួលបានពីការដាក់ឲ្យពិនិត្យ សម្រេចរបស់អង្គការសង្គមស៊ីវិលទាំងអស់ត្រូវបានសង្ខេបទៅជាឯកសារតែមួយ ដែលមានចំនួន ១០ទំព័រ ដោយការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំប្រទេស ឬតំបន់នីមួយៗ។ មិនត្រឹមតែប៉ុណ្ណោះ ឯកសារទាំងនេះត្រូវបានផ្សព្វផ្សាយតាមកាលបរិច្ឆេទដែលជិតនឹងពេលត្រួតពិនិត្យជាក់ស្តែងមែនទែន ដោយរារាំងអ្នកការទូតមិនឱ្យស្គាល់ ឬ ដឹងឮច្បាស់ពីបញ្ហារបស់ប្រទេសពួកគេខ្លួនឯងជាមួយនឹងបញ្ហាដែលត្រូវលើកឡើងដោយអង្គការសង្គមស៊ីវិលឡើយ។ ទីបំផុតសង្គមស៊ីវិលមិនត្រូវបានអនុញ្ញាតឱ្យចូលរួមពិភាក្សាដេញដោលនៅឯការត្រួតពិនិត្យ ដោយរារាំងអង្គការសង្គមស៊ីវិលមិនឱ្យទាក់ទងដោយផ្ទាល់ជាមួយនឹងក្រុមការងារត្រួតពិនិត្យជាសកលតាមកាលកំណត់បាននោះទេ។ ទោះយ៉ាងណាក៏ដោយ សង្គមស៊ីវិលមួយចំនួនបានព្យាយាមទៅទីក្រុងហ្សឺណែវដើម្បីធ្វើការតស៊ូមតិនៅក្នុងថ្ងៃត្រួតពិនិត្យនោះ ដោយមិនបានដឹងច្បាស់ថា នៅដំណាក់កាលចុងក្រោយនេះអនុសាសន៍ត្រូវបានព្រាងរួចហើយទេ។ ដូច្នេះ កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេគឺមានទំហំធំណាស់។ ជារួម ខណៈពេលតួនាទីរបស់អង្គការសង្គមស៊ីវិលត្រូវបានទទួលស្គាល់យ៉ាងត្រឹមត្រូវលើមូលដ្ឋានគ្រឹះស្របច្បាប់នៃការត្រួតពិនិត្យពិនិត្យជាសកលតាមកាលកំណត់ តែអង្គការសង្គមស៊ីវិលមិនបានធ្វើឱ្យប្រសើរឡើងនូវឱកាសថ្មីដែលនាំមកដោយយន្តការឡើយ ពោលគឺមិនធ្លាប់មានពេលវេលា និងមានឥទ្ធិពលលើសកម្មភាពតស៊ូមតិជាក់លាក់នោះទេ។

អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR info) បានមើលឃើញថា រចនាសម្ព័ន្ធផ្លូវការរបស់យន្តការត្រួតពិនិត្យជាសាកលតាមកាលកំណត់បានកំណត់វិសាលភាព ដែលសង្គមស៊ីវិលអាចចូលរួមយ៉ាងស្វាហាប់ជាមួយនឹងដំណើរការនេះ និងដោយចងចាំពីមធ្យោបាយ នៃការចូលរួមមានកំណត់ដូចដែលបានបញ្ជាក់ខាងលើ វគ្គមុនសម័យប្រជុំត្រូវបានណែនាំ។ ដូច្នេះហើយ អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់បានសម្រេចចិត្តដាក់ចេញវគ្គមុនសម័យប្រជុំ ដោយមាននូវគោលបំណង ០៣ ៖

- **ទី១** វគ្គមុនសម័យប្រជុំផ្តល់ជូនសង្គមស៊ីវិលនូវវេទិកាអន្តរជាតិមួយដើម្បីតស៊ូមតិដោយផ្ទាល់ដល់ប្រតិភូរដ្ឋមុនសម័យប្រជុំនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់។
- ទី២ សម្របសម្រួលគណៈប្រតិភូការទូតដើម្បីដឹងព័ត៌មានអំពីទេសភាពសិទ្ធិមនុស្សរបស់ប្រទេស។
- គោលបំណងចុងក្រោយនៃវគ្គមុន គឺដើម្បីធានាថាអនុសាសន៍ដែលនឹងត្រូវបានធ្វើឡើងនៅក្នុងពេលត្រួតពិនិត្យជាសកលតាមកាលកំណត់មានលក្ខណៈជាក់លាក់ និងមានទិសដៅត្រឹមត្រូវ។

នៅពេលចាប់ផ្តើមកម្មវិធីវគ្គមុនសម័យប្រជុំនៅសម័យប្រជុំវគ្គទី ១៣ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ភាគដ៏ច្រើន នៃវាគ្មិនគឺមកពីអង្គការសង្គមស៊ីវិលអន្តរជាតិ ដែលមានវត្តមាននៅទីក្រុងហ្សឺណែវ។ ទោះបីជាយ៉ាងណា នៅពេលកម្មវិធីវគ្គមុនសម័យប្រជុំត្រូវបានអភិវឌ្ឍពេញមួយវគ្គទី១៣ នោះ សក្តានុពលរបស់វគ្គមុនសម័យប្រជុំនេះ ត្រូវបានគេស្គាល់ពាសពេញពីសហគមន៍នៃសង្គមស៊ីវិល ពីអង្គការសង្គមស៊ីវិលជាតិ និងស្ថាប័នសិទ្ធិមនុស្សជាតិបានក្លាយជាវេទិកាមានការចូលរួមច្រើនទៅច្រើនទៅ។ វគ្គមុនសម័យប្រជុំបានវិវត្តន៍ក្លាយជាវេទិកាសង្គមស៊ីវិលដ៏ធំបំផុតសម្រាប់ការតស៊ូមតិផ្នែកសិទ្ធិមនុស្សនៅក្នុងពិភពលោក ដែលគ្រប់គ្រងដោយអង្គការមិនស្វែងរកប្រាក់ចំណេញ។ រហូតមកដល់បច្ចុប្បន្ននេះ អង្គការព័ត៌មានអំពីការត្រួតពនិត្យជាសកលតាមកាលកំណត់ តាមរយៈកម្មវិធីវគ្គមុនសម័យប្រជុំបានផ្តល់ឱ្យអ្នកការពារសិទ្ធិមនុស្សនូវឱកាសដើម្បីនិយាយ ទៅកាន់ប្រទេស ១៤៩ នៅទូទាំងពិភពលោក។ អង្គការសង្គមស៊ីវិលជាតិនៅក្នុងភាគច្រើន នៃរដ្ឋទាំងនេះមានធនធានហិរញ្ញវត្ថុមានកំណត់និង / ឬមានលក្ខណៈភូមិសាស្ត្រដាច់ឆ្ងាយដែលធ្វើឱ្យមានការលំបាកក្នុងការរៀបចំដំណើរទៅកាន់ទីក្រុងហ្សឺណែវ។ ក្នុងស្ថានភាពបែបនេះ អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់បានទាក់ទងទៅអង្គការសង្គមស៊ីវិលអន្តរជាតិដើម្បីដឹងថា តើពួកគេអាចនិយាយក្នុងនាមដៃគូជាតិបានដែរឬទេ? ទោះបីវាមិនតែងតែដែលលើកយកមកបង្ហាញបានក៏ដោយ។ គេសង្ឃឹមថា នៅក្នុង វដ្តទី ៣ នឹងមានការបង្កើនការគាំទ្រដល់ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ដែលអាចប្រើបានសម្រាប់អង្គការសង្គមស៊ីវិលក្នុងការចូលទៅសម័យប្រជុំរបស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ រួមទាំង វគ្គមុនសម័យប្រជុំផង។

នៅពេលដែលវគ្គមុនសម័យប្រជុំទាំងអស់កាន់តែមានច្រើនឡើង នៅក្នុងដំណើរការរបស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ ផលប៉ះពាល់របស់ពួកគេកំពុងត្រូវបានទទួលស្គាល់នៅក្នុងកម្រិតខ្ពស់មួយ។[27]

### ៣.១.២. គោលបំណង

វគ្គមុនសម័យប្រជុំ នៃអង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ មានគោលបំណង ០២ យ៉ាង មានប្រយោជន៍ដល់បេសកម្មអចិន្ត្រៃយ៍ និងសង្គមស៊ីវិល ដូចជា៖

- **គាំទ្រដល់ការតស៊ូមតិចាប់ពីថ្នាក់ក្រោម នៅពេលការត្រួតពិនិត្យជាសកលតាមកាលកំណត់**

សំរាប់អង្គការសង្គមស៊ីវិលដែលធ្វើការនៅមូលដ្ឋាននៅថ្នាក់ក្រោមៗ យន្តការសិទ្ធិមនុស្សអន្តរជាតិហាក់ដូចជាមិនអាចដំណើរការបាន និងឃ្លាតឆ្ងាយពីការងារប្រចាំថ្ងៃរបស់ពួកគេ។ ប៉ុន្តែ យន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់មានសមត្ថភាពនាំមកនូវការផ្លាស់ប្តូរពិតប្រាកដនៅក្នុងតំបន់ដាច់ស្រយាលបំផុត។ អ្វីដែលជាភាពត្រូវការ គឺព័ត៌មានដែលអាចជឿជាក់បាន និងលម្អិតពីមូលដ្ឋាននៃថ្នាក់ក្រោម អំពីបញ្ហាសិទ្ធិមនុស្សដែលប្រជាជនប្រឈមមុខ និងថាតើអនុសាសន៍គួរតែត្រូវបានរៀបចំឡើងយ៉ាងដូចម្តេច ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះឱ្យបានគ្រប់គ្រាន់។ ដូចនេះ វគ្គមុនសម័យប្រជុំមានតួនាទីជាក្រុមប្រឹក្សាសម្លេងដ៏ពិសេសទូលំទូលាយមួយសម្រាប់ថ្នាក់ក្រោម និងសំឡេងរបស់ជាតិដើម្បីនាំមកនូវចំណេះដឹង និងបទពិសោធន៍របស់ពួកគេដល់សហគមន៍អន្តរជាតិ។ ពេលត្រឡប់មកប្រទេសកំណើតវិញ បន្ទាប់ពីបានចូលរួមក្នុងវគ្គមុនសម័យប្រជុំ វាគ្មិនសង្គមស៊ីវិលមានអារម្មណ៍ថាជាម្ចាស់កម្មសិទ្ធិ និងចាប់អារម្មណ៍លើដំណើរការការត្រួតពិនិត្យជាសកលតាមកាលកំណត់។ ពួកគេក៏មានទំនោរចង់ចែករំលែកបទពិសោធរបស់ពួកគេជាមួយសហសេវិក (អ្នកធ្វើការជាមួយគ្នា) និងសហគមន៍របស់ពួកគេ ដែលជួយធ្វើឱ្យប្រជាប្រិយភាពរបស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងបង្កើនការយល់ដឹងអំពីផលប៉ះពាល់ ដែលអាចមានសម្រាប់អ្នកកាន់កាប់សិទ្ធិទាំងអស់។

- **ការផ្តល់ឲ្យបេសកកម្មអចិន្ត្រៃយ៍ជាមួយប្រភពព័ត៌មានផ្ទាល់**

វគ្គមុននេះតំណាងឱ្យឱកាសសំខាន់សម្រាប់បេសកកម្មអចិន្ត្រៃយ៍ដើម្បីសន្សំសំចៃពេលវេលាដោយការចូលរួមជាមួយទាំងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិនៅក្នុងវេទិកាតែមួយ។ បើប្រៀបធៀបជាមួយនឹងការអានបរិមាណដ៏ច្រើននៃការដាក់ឲ្យពិនិត្យសម្រេចជាលាយលក្ខណ៍អក្សររបស់ការត្រួតពិនិត្យជាសកលតាមកាល

[27] បកប្រែចេញពីគេហទំព័រដែលមានដំណ https://www.upr-info.org/sites/default/files/general-document/pdf/2016_pre-sessions_empowering_human_rights_voices_from_the_ground.pdf ស្តីពីការឲ្យអំណាចសំឡេងសិទ្ធិមនុស្សតាំងពីថ្នាក់ក្រោម "Empowering human rights voice from the ground" របស់ UPR Info ២០១២-២០១៦ ទំព័រ ១១-១២ (ចូលមើល០១/កញ្ញា/២០)

កំណត់។ វគ្គមុនសម័យប្រជុំ មុនក៏ធ្វើឱ្យព័ត៌មានមានភាពរស់រវើក ដោយធ្វើឱ្យរដ្ឋដែលផ្តល់អនុសាសន៍ (Recommending State) មានឱកាសស្តាប់សក្ខីកម្មអំពីសិទ្ធិមនុស្ស។ បេសកកម្មអចិន្ត្រៃយ៍ក៏អាចផ្ញើសំណួរជាមុនទៅកាន់ក្រុមការងារការត្រួតពិនិត្យជាសកលតាមកាលកំណត់ ព័ត៌មានដែលអ្នកសម្របសម្រួលនឹងអង្វរទៅកាន់វាគ្មិនសង្គមស៊ីវិលក្នុងពេលមានវគ្គមាន។ សំណួរផ្តល់នូវឱកាសដើម្បីទទួលបានព័ត៌មានស្តីពីកម្រិតនៃការអនុវត្តអនុសាសន៍ពីមុនក៏ដូចជាបរិបទសិទ្ធិមនុស្សកាន់តែទូលំទូលាយ។[28]

### ៣.១.៣. ការត្រួតពិនិត្យសិទ្ធិមនុស្សនៅវគ្គមុនសម័យប្រជុំ

វគ្គមុនសម័យប្រជុំនីមួយៗ ឆ្លុះបញ្ចាំងពីសម័យប្រជុំផ្លូវការរបស់ការត្រួតពិនិត្យជាសកលតាមកាល កំណត់ ពោលគឺប្រទេសចំនួន ១៤ (ដប់បួន) ដូចគ្នា ដែលត្រូវបានត្រួតពិនិត្យនៅវគ្គមុនសម័យប្រជុំនីមួយៗ។ វគ្គមុនសម័យប្រជុំត្រូវបានរៀបចំឡើងចំនួន ០១ (មួយ) ខែមុនសម័យប្រជុំផ្លូវការរបស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់(ធ្វើការត្រួតពិនិត្យក្រុមការងារ( Working Group) របស់យន្តការនេះ)។ ខណៈពេលដែលអាចមានរហូតដល់ទៅ ១៤ (ដប់) ប្រទេសដែលត្រូវបានត្រួតពិនិត្យនៅឯវគ្គមុនសម័យប្រជុំនីមួយៗ ជាទូទៅមានប្រទេសចំនួន ១០/១១ (ដប់ក្នុងចំណោមដប់មួយ) បានពិនិត្យនៅក្នុងវគ្គនីមួយៗនៃវគ្គមុនសម័យប្រជុំ។ ការកំណត់ចំនួនប្រទេសនេះ ក៏ព្រោះតែតម្រូវការចាំបាច់ ដែលត្រូវដឹងចំនួនអប្បបរមានៃការដាក់ពាក្យសុំពីសង្គមស៊ីវិល ដើម្បីអ្នករៀបចំកម្មវិធីវគ្គមុនសម័យប្រជុំមានការត្រៀមរៀបចំជាមុន។ ក្នុងករណី ប្រទេសដែលមានភូមិសាស្ត្រដាច់ឆ្ងាយពីទីក្រុងហ្សឺណែវ អង្គការសង្គមស៊ីវិលខ្លះមិនតែងតែអាចធ្វើដំណើរចូលរួមបាននោះទេ។[29]

ក្រៅពីនេះមានការបណ្តុះបណ្តាលសម្រាប់ការត្រួតពិនិត្យជាសកលតាមកាលកំណត់។ អង្គភាពព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់រៀបចំវគ្គបណ្តុះបណ្តាលទូទៅមួយស្តីពី ការត្រួតពិនិត្យជាសកលតាមកាលកំណត់មួយថ្ងៃមុនពេលចាប់ផ្តើមវគ្គមុន។ វគ្គបណ្តុះបណ្តាលនេះអនុញ្ញាតឱ្យអ្នកចូលរួមត្រូវបានដឹកនាំតាមរយៈប្រធានបទការត្រួតពិនិត្យជាសកលតាមកាលកំណត់ យ៉ាងពេញលេញក្នុងការរៀបចំវគ្គមុនសម័យប្រជុំ

[28] បកប្រែចេញពីគេហទំព័រដែលមានដំណ https://www.upr-info.org/sites/default/files/general-document/pdf/2016_pre-sessions_empowering_human_rights_voices_from_the_ground.pdf ស្តីពី ការឲ្យអំណាចសំឡេងសិទ្ធិមនុស្សតាំងពីថ្នាក់ក្រោម "Empowering human rights voice from the ground" របស់ UPR Info ឆ្នាំ២០១២-២០១៦ ទំព័រ ១៤ (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

[29] ដកស្រង់ចេញពី https://www.upr-info.org/en/upr-process/pre-sessions/frequently-asked-questions ស្តីពីសំណួរដែលមានគេសួរជាញឹកញាប់អំពីវគ្គមុនសម័យប្រជុំ (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

និងយុទ្ធសាស្ត្រតស៊ូមតិទូលំទូលាយ ដែលអង្គការសង្គមស៊ីវិលគួរតែទទួលយកនៅដំណាក់កាលផ្សេងៗគ្នានៃដំណើរការ។ ការចូលរួម គឺបើកចំហសម្រាប់ទាំងសង្គមស៊ីវិលនិង NHRI រួមទាំងវាគ្មិន និងទស្សនិកជន។[30]

### ៣.១.៤. ការចូលរួមជាមួយវគ្គមុនសម័យប្រជុំ

ប្រទេសនៅលើពិភពលោកចំនួន ១៤៩ ត្រូវបានត្រួតពិនិត្យតាមកាលបរិច្ឆេទនៅឯវគ្គមុនសម័យប្រជុំនៅឆ្នាំ ២០១២-២០១៦ ជាមធ្យមនៅ ១០/១១ វគ្គមុនសម័យប្រជុំបន្តបន្ទាប់។ សមាសភាព និងចំនួនវាគ្មិនបង្ហាញពីវិសាលភាពដែលព្រឹត្តិការណ៍នេះគឺជាលំហាត់សមារហនកម្មពហុភាគីនៃអ្នកពាក់ព័ន្ធ។ រហូតមកដល់បច្ចុប្បន្ននេះមានអង្គការជាង ៧០០ បាននិយាយក្នុងវគ្គមុនសម័យប្រជុំ ដែលជាអ្នកតំណាងឱ្យ៖

- អង្គការសង្គមស៊ីវិលជាតិចំនួន ៤៦៧
- អង្គការសង្គមស៊ីវិលអន្តរជាតិចំនួន ២០៦
- និងស្ថាប័នសិទ្ធិមនុស្សជាតិចំនួន ៣៣ នាក់។

បន្ថែមលើការតំណាង នៃវាគ្មិនយ៉ាងទូលំទូលាយនេះ ចំនួននៃបេសកកម្មអចិន្ត្រៃយ៍[31] (Permanent Mission) ដែលបានចូលរួមវគ្គមុននេះ គឺជាសញ្ញាប្រាកដនៃភាពជោគជ័យនៃព្រឹត្តិការណ៍វគ្គមុនសម័យប្រជុំ។ ចាប់តាំងពីឆ្នាំ ២០១២ មកមានបេសកម្មអចិន្ត្រៃយ៍ចំនួន ១៥០ បានចូលរួមវគ្គមុនសម័យប្រជុំ ដើម្បីស្តាប់អំពីសក្ខីកម្មរបស់អ្នកតស៊ូមតិផ្នែកសិទ្ធិមនុស្សមកពីគ្រប់ទិសទី នៃពិភពលោក។

#### ៣.១.៤.១. ចំណាប់អារម្មណ៍ នៃការការចូលរួម

អង្គភាពព័ត៌មាន នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR Info) នឹងចាប់ផ្តើមការផ្សព្វផ្សាយឱ្យដាក់ពាក្យសុំតាមរយៈគេហទំព័រ និងបណ្តាញសង្គមរបស់ខ្លួនប្រមាណជា ០៣ខែមុនពេលបន្តវគ្គមុនសម័យប្រជុំបន្ទាប់ទៀត។ ភាគីដែលពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍គួរតែបំពេញ និងបញ្ជូនទម្រង់ពាក្យសុំដែលពាក់ព័ន្ធក៏ដូចជាច្បាប់ចម្លង នៃការដាក់ឲ្យពិនិត្យសម្រេចនៅពេលត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR

[30] ដូចគ្នានឹង Footnote២៩

[31] បេសកកម្មអចិន្ត្រៃយ៍ (Permanent Mission) គឺជាបេសសកម្មការទូត ដែលរដ្ឋជាសមាជិកទាំងអស់ប្រគល់អំណាចឲ្យអង្គការសហប្រជាជាតិ និងត្រូវបានដឹកនាំដោយតំណាងអចិន្ត្រៃយ៍ (Permanent Representative) ហើយបេសសកម្មការទូតក៏ជួយដល់ការសម្រេចបាននូវគោលបំណង និងគោលការណ៍ នៃអង្គការសហប្រជាជាតិ ជាពិសេសរក្សាទំនាក់ទំនងចាំបាច់រវាងរដ្ឋជាសមាជិក និងរដ្ឋលេខាអង្គការសហប្រជាជាតិក្នុងកំឡុងពេលសម័យប្រជុំនៃផ្នែកផ្សេងៗ នៃអង្គការសហប្រជាជាតិ។ (ដកស្រង់ចេញពីសេចក្តីសម្រេចលេខ ២៥៧ (III) ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៤៨)

Submissions) តាមរយៈអ៊ីម៉ែល (E-mail) ទៅ អង្គភាពព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ តាមរយៈ presessions@upr-info.org។

ជាអកុសល គ្រប់អ្នកដាក់ពាក្យសុំទាំងអស់មិនជានាបានធ្វើជាវាគ្មិនទាំងអស់នោះទេ ដូចជាពេលវេលាសម្រាប់វគ្គមុនសម័យប្រជុំនីមួយៗត្រូវបានកំណត់ត្រឹម ០១ ម៉ោងមានតែអ្នកនិយាយជាវាគ្មិន ០៥ នាក់ប៉ុណ្ណោះដែលអាចអង្គុយសម្រុះសម្រួលនៅលើតុវេទិកាបាន។ ដូច្នេះ គឺមិនអាចទៅរួចទេ ដែលអាចជ្រើសរើសអង្គការដែលដាក់ពាក្យសុំទាំងអស់ក្លាយជាវាគ្មិន (Panellist Speaker[32]) បានទេ។

### ៣.១.៤.២. ការជ្រើសរើសអ្នកដាក់ពាក្យសុំដើម្បីធ្វើជាវាគ្មិន

វាគ្មិនត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យគោលបំណងដែលអាទិភាពត្រូវបានផ្តល់ជូនផ្អែកលើមូលដ្ឋានខាងក្រោម៖

- **មូលដ្ឋានគ្រឹះ និងអង្គការសង្គមស៊ីវិលជាតិ** ៖ ពីព្រោះពួកគេជានាបាននូវវិធីសាស្ត្រគាំទ្រពីថ្នាក់ក្រោមដល់ការតស៊ូមតិ ដោយដាក់សំលេងសិទ្ធិមនុស្សរបស់ប្រជាជនជាមូលដ្ឋាននៅជួរមុខ នៃកិច្ចពិភាក្សាសិទ្ធិមនុស្សអន្តរជាតិ។
- **សម្ព័ន្ធភាពជាតិ** ៖ អង្គការសង្គមស៊ីវិលដែលធ្វើការក្នុងក្រុមចម្រុះទទួលបានអត្ថប្រយោជន៍ចំណេះដឹងយ៉ាងច្រើនសន្ធឹកសន្ធាប់ពីសមូហភាពរបស់សមាជិកនីមួយៗ ដោយសារពួកគេច្រើនតែតំណាងឱ្យសិទ្ធិមនុស្សដ៏ច្រើន ហើយការចូលរួមរបស់ពួកគេហាក់ដូចជាមាននិរន្តរភាពជាងមុន។

[32] Panellist Speaker គឺជាវាគ្មិននៅក្នុង ការពិភាក្សាជាក្រុម (Panel Discussion) ដែលជាទំរង់ជាក់លាក់មួយដែលត្រូវបានប្រើនៅក្នុងការប្រជុំសន្និសីទ ឬ សន្និបាត។ កិច្ចពិភាក្សានេះ ជាកិច្ចពិភាក្សាផ្ទាល់ ឬ ជាក់ស្តែងអំពីប្រធានបទជាក់លាក់មួយក្នុងចំណោមក្រុមវាគ្មិនដែលជ្រើសរើសចេញពីអ្នកដែលចែករំលែកទស្សនៈខុសគ្នានៅចំពោះមុខទស្សនិកជនដ៏ច្រើន។

- ជាធម្មតាការពិភាក្សាជាក្រុម ត្រូវបានសម្របសម្រួលដោយ "អ្នកសម្របសម្រួល (Moderator)" ដែលដឹកនាំការពិភាក្សាជាក្រុម និងអង្គពិធីទាំងមូលឆ្លងកាត់ព្រឹត្តិការណ៍នេះ
- ក្រុមនេះជាធម្មតាអ្នកជំនាញ ឬ អ្នកអនុវត្តជាក់ស្តែង ៣-៤ (បី ទៅ បួន) នាក់ នៅក្នុងវិស័យនេះ ដែលចែករំលែកព័ត៌មានពិតប្រាកដ ផ្តល់នូវមតិយោបល់ និងការឆ្លើយតបចំពោះសំណួររបស់ទស្សនិកជន តាមរយៈសំណួរដែលសម្របសម្រួលដោយអ្នកសម្របសម្រួល ឬ យកពីទស្សនិកជនដោយផ្ទាល់
- សម័យប្រជុំការពិភាក្សាជាក្រុម មានរយៈពេលពី ៦០-៩០ នាទី។

(ចំណុចនេះបកប្រែដោយដកស្រង់ចេញពីគេហទំព័រ https://powerfulpanels.com/definition-panel-discussion/)(ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

- អង្គការសង្គមស៊ីវិលដែលបានបញ្ជូនរបាយការណ៍ដាក់ឲ្យពិនិត្យ សម្រេចទៅ UPR ហើយប្តេជ្ញាចូលរួមក្នុងដំណើរការនេះជាពិសេសនៅក្នុងដំណាក់កាលអនុវត្តន៍
- ការតំណាងដ៏ទូលំទូលាយ នៃបញ្ហាសិទ្ធិមនុស្សផ្សេងៗគ្នា ដែលតំណាងឱ្យកង្វល់របស់ប្រជាជនក្នុងតំបន់។ ជាពិសេស តុល្យភាពមួយត្រូវបានស្វែងរកក្នុងចំណោមសិទ្ធិពលរដ្ឋ និងនយោបាយ ព្រមទាំងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌
- និងធានាបាននូវទស្សនៈយេនឌ័រសម្រាប់វគ្គមុនសម័យប្រជុំនីមួយៗ។ ក្នុងករណីដែលអាចធ្វើទៅបាន សមភាពយេនឌ័រក្នុងចំណោមវាគ្មិនទាំងអស់ត្រូវបានស្វែងរកផងដែរ។

ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនត្រូវបានជ្រើសរើសជាវាគ្មិនទេ អ្នកដាក់ពាក្យសុំអាចសុំការទទួលស្គាល់ ដើម្បីចូលរួមវគ្គមុនសម័យប្រជុំទស្សនិកជន។ តាមរយៈការមានវត្តមាននៅវគ្គមុនសម័យប្រជុំ អាចពង្រីកឱកាសច្រើនបំផុតដើម្បីរៀបចំជួបជាមួយបេសកកម្មអចិន្ត្រៃយ៍ដែលមានវត្តមាននៅឯវគ្គនេះ ហើយក៏អាចនាំយកឯកសារតស៊ូមតិ / សេចក្តីថ្លែងការណ៍នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដែលអង្គភាពព័ត៌មាន នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ នឹងបង្ហាញនៅទីកន្លែងនោះ។

អង្គការសង្គមស៊ីវិលដែលបានជ្រើសរើសនិងស្ថាប័នសិទ្ធិមនុស្សជាតិ (NHRIs) ចូលរួមក្នុងក្រុមមួយដែលពួកគេនីមួយៗបង្ហាញប្រធានបទសិទ្ធិមនុស្សខុសៗគ្នា ដែលជះឥទ្ធិពលដល់រដ្ឋក្រោមការត្រួតពិនិត្យ។ បន្ទាប់មកពួកគេបានផ្តល់នូវអនុសាសន៍ ដែលពួកគេចង់អោយរដ្ឋផ្តល់អនុសាសន៍ធ្វើនៅសម័យប្រជុំនៃការត្រួតពិនិត្យជាសកល។ បន្ទាប់ពីវាគ្មិនទាំងអស់បានធ្វើបទបង្ហាញរបស់ពួកគេអ្នកសម្របសម្រួលនៃវេទិកាបានសួរសំណួរទៅវាគ្មិន ហើយបន្ទាប់មកបើកការជជែកសួរដេញដោលទៅសំណួរ ដែលសួរពីបេសកកម្មអចិន្ត្រៃយ៍នៅក្នុងទស្សនិកជន។

ជាទូទៅនៅកន្លែង ដែលមានវាគ្មិនចំនួន ០៥ នៅលើវេទិកា អ្នកចូលរួមម្នាក់ៗនឹងមានរយៈពេលពី ៥ ទៅ ៧ នាទីដើម្បីធ្វើបទបង្ហាញរបស់ខ្លួនទៅកាន់អង្គពិធីទាំងមូល។ នេះអនុញ្ញាតឱ្យមានពេលវេលាសម្រាប់ការសន្ទនាជាមួយគ្នាទៅវិញទៅមករវាងអ្នកជំនាញអ្នកសម្របសម្រួល និងបេសកកម្មអចិន្ត្រៃយ៍ បន្ទាប់ពីបទបង្ហាញរបស់វាគ្មិនត្រូវបានថ្លែង។ ការកំណត់ពេលវេលាត្រូវបានអង្កេតយ៉ាងតឹងរ៉ឹងដោយអ្នកសម្របសម្រួលដើម្បីផលប្រយោជន៍យុត្តិធម៌ ដូច្នេះវាគ្មិននីមួយៗមានឱកាសដូចគ្នា។ អង្គការសង្គមស៊ីវិល និងស្ថាប័នសិទ្ធិមនុស្សជាតិត្រូវបានកំណត់ពេលវេលាដូចគ្នា បើទោះបីជាស្ថាប័នសិទ្ធិមនុស្សជាតិជាទូទៅថ្លែងសន្ទរកថាដំបូងក៏ដោយព្រោះពួកគេមាននិន្នាការផ្តល់នូវទិដ្ឋភាពទូទៅទូលំទូលាយ នៃបញ្ហាសិទ្ធិមនុស្ស។ និយាយជាទូទៅនៅពេលមានការរួមបញ្ចូលគ្នា នៃអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ នៅលើវេទិកា ក្រុមសង្គមស៊ីវិលជាតិនិយាយមុនគេ។ នៅកន្លែងដែលអង្គការសង្គមស៊ីវិលបានចូលរួមធ្វើបទបង្ហាញ ដែលត្រូវអានតាមលំដាប់ជាក់លាក់ អង្គភាព

ព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់រីករាយនឹងជួយសម្រួលដល់ការនិយាយទាំងនោះ។ ការផ្តល់ពេលវេលាត្រូវបានប្រកាន់ខ្ជាប់ ជាទូទៅមានរយៈពេលពីរ បីនាទីនៅចុងបញ្ចប់នៃបទបង្ហាញមុនពេលមានសំណួរចេញពីការជជែកវែកញែក ដែលអ្នកនិយាយមានឱកាសបន្ថែមដើម្បីធ្វើសេចក្តីសន្និដ្ឋាន។

វាគ្មិននីមួយៗនឹងទទួលបាននូវគំរូសេចក្តីថ្លែងការណ៍ ពី អង្គភាពព័ត៌មាន នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដែលអាចដើរតួជាចំណុចចាប់ផ្តើមដ៏ល្អក្នុងការរៀបចំសម្រុះសម្រួល ជាទូទៅធាតុខាងក្រោមគួរតែត្រូវបានរាប់បញ្ចូលៈ

ក) បទបង្ហាញរបស់អង្គការ (សូមសង្ខេបពីក្រុមដែលអ្នកកំពុងតំណាង។ ប្រសិនបើរដ្ឋជាផ្នែកនៃចូលរួមនោះត្រូវនិយាយអំពីការចូលរួមរបស់រដ្ឋនោះ នៅក្នុងដំណើរការត្រួតពិនិត្យជាសកាលតាមកាលកំណត់រហូតមកដល់ពេលនេះ)

ខ) ការពន្យល់ដោយសង្ខេបថាតើការពិគ្រោះយោបល់ថ្នាក់ជាតិបានធ្វើឡើងសម្រាប់ការធ្វើសេចក្តីព្រាងរបាយការណ៍ជាតិដែរ ឬទេ

គ) បទបង្ហាញសង្ខេប នៃផែនការនៃសេចក្តីថ្លែងការណ៍របស់អ្នក។ ចង្អុលបង្ហាញចំនួនបញ្ហាដែលអ្នកនឹងលើកឡើងហើយតាមលំដាប់លំដោយ

ឃ) ការជ្រើសរើសបញ្ហាៈ វាចាំបាច់ក្នុងការបំបែកបញ្ហារបស់អ្នក។ ស្ត្រីកុមារជនជាតិដើមភាគតិចជាដើមអាចមានបញ្ហាតូចៗជាច្រើន ដូចជាអំពើហិង្សាការរើសអើង ការជួញដូរ ការអប់រំ និងបញ្ហាជាច្រើនទៀត។ ជ្រើសរើសចំនួនបញ្ហាដែលមានកំណត់ ហើយចំពោះបញ្ហានីមួយៗសូមធ្វើជំហានទី ១ ដល់លេខ ៣ ដូចបានរៀបរាប់ខាងក្រោម។

ជំហានទី ១ៈ សូមធ្វើបច្ចុប្បន្នភាពលើអនុសាសន៍ពីការត្រួតពិនិត្យមុនៗ ដែលទាក់ទងនឹងបញ្ហានេះ (កុំស្ទាក់ស្ទើរក្នុងការដកស្រង់ឈ្មោះប្រទេសដែលបានផ្តល់អនុសាសន៍ទាំងនោះ)។ ចងចាំថាត្រូវប្រើមូលដ្ឋានទិន្នន័យរបស់ អង្គភាពព័ត៌មាន នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ដើម្បីរកបញ្ជី នៃអនុសាសន៍ពីមុនទាំងអស់ដែលបានធ្វើចំពោះរដ្ឋដែលកំពុងត្រូវបានពិនិត្យ។

ជំហានទី ២ៈ រៀបរាប់ពីស្ថានភាព នៃបញ្ហាទាំងនោះ ដែលបានវិវឌ្ឍន៍នៅក្នុងប្រទេសចាប់តាំងពីការត្រួតពិនិត្យចុងក្រោយ ហើយបង្ហាញពីសមិទ្ធិផល និងគម្លាតដែលនៅសល់។ ភស្តុតាងជាក់ស្តែងពីធនធានដែលអាចទុកចិត្តបានគឺជាព័ត៌មានគួរឱ្យទាក់ទាញអារម្មណ៍សម្រាប់រដ្ឋ។

ជំហានទី ៣ៈ ផ្តល់យោបល់ជាក់លាក់ ពីរ ឬបី និងសំណួរពីរ ឬបីជាមុន។ ទោះបីជាដំណើរការមិនដំណើរការនៅក្នុងដំណើរការ UPR ក៏ដោយ សំណួរដែលបានលើកឡើងជាមុនមានសក្តានុពលគួរឱ្យចាប់អារម្មណ៍លើរដ្ឋដែលកំពុងស្វែងរកដើម្បីទទួលយកទំនួលខុសត្រូវសិទ្ធិមនុស្សអន្តរជាតិរបស់ពួកគេ។

### ៣.១.៤.៣. ភាសា ដែលត្រូវប្រើក្នុងកិច្ចពិភាក្សា នៃវគ្គមុនសម័យប្រជុំ

ជាទូទៅដើម្បីឆ្លុះបញ្ចាំងពីភាសាសំខាន់ៗ នៃការទូតនៅទីក្រុងហ្សឺណែវ គឺភាសាអង់គ្លេស និងភាសាបារាំងគឺជាបណ្ដាញទំនាក់ទំនងដំបូងនៅវគ្គមុនសម័យប្រជុំ។ អង្គភាពព័ត៌មាន នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ជាធម្មតាអាចផ្ដល់ការបកស្រាយជាភាសាបារាំងទៅអង់គ្លេសនៅពេលចាំបាច់។ ក្នុងករណីដែលភាគច្រើន នៃអង្គការសង្គមស៊ីវិល និងស្ថាប័នសិទ្ធិមនុស្សជាតិ នៃប្រទេសជាក់លាក់មួយមិនអាចបង្ហាញជាភាសាអង់គ្លេស ឬបារាំងបាននោះ អង្គភាពព័ត៌មាន នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់នឹងខិតខំផ្ដល់ការបកស្រាយដំណាលគ្នាពីភាសាមួយទៀតប្រសិនបើអាច។

### ៣.១.៤.៤. ការចូលរួមពីសំណាក់បេសកម្មអចិន្ត្រៃយ៍

អង្គភាពព័ត៌មាន នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់អញ្ជើញរាល់បេសកកម្មអចិន្ត្រៃយ៍ទៅអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវដើម្បីចូលរួមវគ្គមុន ៗ។ រហូតមកដល់បច្ចុប្បន្ននេះ ១៥៦ ក្នុងចំណោមបេសកកម្មអចិន្ត្រៃយ៍ចំនួន ១៧៨ ដែលមានទីតាំងនៅទីក្រុងហ្សឺណែវបានចូលរួមវគ្គមុននេះ។

ចំនួនសំនួរដែលបេសកម្មអចិន្ត្រៃយ៍លើកយកមកអាស្រ័យលើវិសាលភាពដ៏ស្មុគស្មាញនៃបញ្ហាសិទ្ធិមនុស្សនៅក្នុងរដ្ឋក្រោមការត្រួតពិនិត្យ (State under Review)។[33]

### ៣.១.៤.៥. ការចូលរួមរបស់រដ្ឋស្ថិតក្រោមការត្រួតពិនិត្យ

ក្នុងស្មារតីនៃកិច្ចសហប្រតិបត្តិការ និងតម្លាភាពអង្គភាពព័ត៌មាននៃការត្រួតពិនិត្យជាសកលតាមកាលកំណត់តែងតែអញ្ជើញរដ្ឋក្រោមការត្រួតពិនិត្យដើម្បីចូលរួមក្នុងវគ្គមុនសម័យប្រជុំរបស់ខ្លួន។ ភាគច្រើននៃរដ្ឋក្រោមការត្រួតពិនិត្យ គឺមានវត្តមាននៅក្នុងវគ្គមុនសម័យរបស់ពួកគេដែលផ្ដល់នូវឱកាសសម្រាប់ការសន្ទនារវាងរដ្ឋ និងសង្គមស៊ីវិលជាតិរបស់ខ្លួន។[34]

### ៣.១.៤.៦. សុវត្ថិភាពក្នុងការចូលរួមនៅវគ្គមុនសម័យប្រជុំ

ជាទូទៅវគ្គមុនសម័យប្រជុំ ត្រូវបានធ្វើឡើងក្នុងស្មារតីតម្លាភាព និងការពិភាក្សាបើកចំហ ដែលរដ្ឋទាំងអស់ រួមទាំងរដ្ឋស្ថិតក្រោមការត្រួតពិនិត្យចូលរួមជាមួយឆន្ទៈពិតប្រាកដ ដើម្បីស្ដាប់ការព្រួយបារម្ភរបស់សង្គម

---

[33] ដកស្រង់ចេញពី https://www.upr-info.org/en/upr-process/pre-sessions/frequently-asked-questions ស្ដីពីសំណួរដែលមានគេសួរជាញឹកញាប់អំពីវគ្គមុនសម័យប្រជុំ (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

[34] ដកស្រង់ចេញពី https://www.upr-info.org/en/upr-process/pre-sessions/frequently-asked-questions ស្ដីពីសំណួរដែលមានគេសួរជាញឹកញាប់អំពីវគ្គមុនសម័យប្រជុំ (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

ស៊ីវិល។ ទោះយ៉ាងណាក៏ដោយ ខណៈពេល ដែលមានករណីបំភិតបំភ័យតឹកម្រកើតមាននៅវគ្គមុនសម័យប្រជុំ ប៉ុន្តែ មានស្ថានភាពដែលអ្នកចូលរួមជាសង្គមស៊ីវិលមួយចំនួនត្រូវបានរារាំងដោយអាជ្ញាធរ ឬដោយការពារប្រកបដោយប្រសិទ្ធភាពពីសំណាក់អាជ្ញាធររដ្ឋក្នុងការមកទីក្រុងហ្សឺណែវ ដើម្បីនិយាយនៅឯវគ្គមុនសម័យប្រជុំ។ ដោយសារវគ្គមុនសម័យប្រជុំ គឺជាព្រឹត្តិការណ៍សាធារណៈអ្នកចូលរួមដែលមានសក្តានុពលត្រូវបានលើកទឹកចិត្តឱ្យវាយតម្លៃដោយប្រយ័ត្នប្រយែងនូវរាល់ផលវិបាក ដែលអាចកើតមានក្នុងការចូលរួមរបស់ពួកគេ និងចែករំលែកនូវរាល់កង្វល់ ដែលពួកគេមានជាមួយអង្គភាពព័ត៌មាន នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ លើសពីនេះ អង្គភាពនេះ ណែនាំឱ្យអ្នកចូលរួមវគ្គមុនសម័យប្រជុំទាំងអស់ពិគ្រោះយោបល់លើគោលការណ៍ណែនាំស្តីពីការឧបត្ថម្ភការពារពីការសងសឹក ដោយហេតុមកពីការបរិយាយអំពើអាក្រក់របស់អ្នករំលោភសិទ្ធិមនុស្ស។[35]

### ៣.១.៥. ហិរញ្ញវត្ថុ

អង្គភាពព័ត៌មាន នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់មានថវិកាមានកំណត់ដើម្បីទ្រទ្រង់អង្គការសង្គមស៊ីវិលមួយចំនួនតូចពីប្រទេសដែលបានជ្រើសរើស។ អង្គការដែលត្រូវការជំនួយផ្នែកហិរញ្ញវត្ថុគួរតែពិចារណាឈានដល់ស្ថានទូត / កម្មវិធីអភិវឌ្ឍន៍ក្រៅប្រទេសនៃប្រទេសទាំងនោះដែលបានផ្តល់អនុសាសន៍ដល់រដ្ឋក្រោមការត្រួតពិនិត្យ ដើម្បីជួយកំណត់នូវអ្វីដែលរដ្ឋបានផ្តល់អនុសាសន៍ដល់រដ្ឋស្ថិតក្រោមការត្រួតពិនិត្យរបស់ខ្លួន។

ចំណែកផ្នែកលើមតិយោបល់របស់អ្នកចូលរួមកន្លងមក CSOs និង NHRI គួរតែមានគម្រោងស្នាក់នៅក្នុងទីក្រុងហ្សឺណែវប្រហែល ៣ ទៅ ៤ យប់ប្រសិនបើធនធានហិរញ្ញវត្ថុរបស់ពួកគេមាន។ រយៈពេលពិតប្រាកដនៃការស្នាក់នៅគួរតែអាស្រ័យលើកាលបរិច្ឆេទ នៃវគ្គមុនសម័យប្រជុំមុនរបស់ប្រទេស និងថាតើអ្នកទាំងនោះមានគម្រោងចូលរួមទាំងការបណ្តុះបណ្តាលសម្រាប់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងការទទួលការធ្វើបដិសណ្ឋារកិច្ចជាបណ្តាញ ឬអត់?[36]

## ៣.២. សម័យប្រជុំរបស់យន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR Session)

ការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៦០/២៥១ ចុះថ្ងៃទី ១៥ ខែមីនាឆ្នាំ ២០០៦ ដូចដែលបានបញ្ជាក់ខាងលើ។ ឆ្លងកាត់ដំណាក់

[35] ដកស្រង់បន្តពី Footnote លេខ៣៤

[36] ដកស្រង់បន្តពី Footnote លេខ៣៥

កាលត្រៀម ពោលគឺត្រៀមមុនសម័យប្រជុំពេញអង្គរបស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដែលហៅថា វគ្គមុនសម័យប្រជុំ (Pre-session) ពេលនេះនឹងឈានដល់ដំណើរការនៃសម័យប្រជុំ នៃយន្តការនោះ ដែលជាដំណាក់កាលនិយាយអំពី ការពង្រាងអនុសាសន៍ និងក្រុមការងារ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់។ ដើម្បីឆ្លុះបញ្ចាំងពីដំណាក់ នៃដំណើរការនេះមានលក្ខណៈដូចម្ដេច ដូចនេះ សូមធ្វើការបែងចែកជា៖ មុនពេលត្រួតពិនិត្យ **(២.១) ពេលត្រួតពិនិត្យ (២.២)** និង**ក្រោយការត្រួតពិនិត្យ (២.៣)**។

### ៣.២.១. មុនពេលត្រួតពិនិត្យ

ឯកសារព័ត៌មានជាមូលដ្ឋានរបស់រដ្ឋក្រោមការត្រួតពិនិត្យ ដែលត្រូវរៀបចំសម្រាប់ការវាយតម្លៃ មាន៖

- ឯកសារព័ត៌មានជាលាយលក្ខណ៍អក្សររៀបចំដោយរដ្ឋស្ថិតនៅក្រោមការត្រួតពិនិត្យ ដែលមានទម្រង់ជារបាយការណ៍ជាតិ មិនលើសពី ២០ទំព័រ។ ដើម្បីធានាការប្រព្រឹត្តទៅនៃរដ្ឋមានភាពដូចគ្នាសម្រាប់រដ្ឋទាំងអស់ និងមិនធ្វើឲ្យយន្តការមានការលំបាក រដ្ឋស្ថិតនៅក្រោមការត្រួតពិនិត្យ ត្រូវបានលើកទឹកចិត្តក្នុង ការរៀបចំឯកសារព័ត៌មានទាំងនេះ ដោយឆ្លងកាត់ការពិភាក្សាយ៉ាងទូលំទូលាយនៅក្នុងកម្រិតថ្នាក់ជាតិជាមួយនឹងភាគីពាក់ព័ន្ធ
- ឯកសារដែលរៀបចំចងក្រងឡើងដោយ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលព័ត៌មានទាំងនេះត្រូវដាក់បញ្ជូនដោយស្ថាប័នសន្ធិសញ្ញា [37] នីតិវិធីពិសេស[38] រួមទាំងការរាយការណ៍ និងមតិយោបល់ដោយផ្តល់ដោយរដ្ឋក្រមការត្រួតពិនិត្យ និងស្ថាប័នដទៃទៀត ហើយឯកសារព័ត៌មាននេះមិនលើសពី ១០ទំព័រ
- ឯកសារព័ត៌មានដែលគួរឲ្យជឿជាក់បាន និងសមហេតុផល ដែលត្រូវផ្តល់ឲ្យដោយភាគីពាក់ព័ន្ធ (Stakeholder) ដើម្បីធ្វើការត្រួតពិនិត្យជាសកល ដែលរៀបចំឡើង។

---

[37] ស្ថាប័នសន្ធិសញ្ញា ជាស្ថាប័នឃ្លាំមើលការអនុវត្តសិន្ធិសញ្ញាសិទ្ធិមនុស្សស្នូល (មានសិទ្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់៩ និង ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម។ ស្ថាប័នសន្ធិសញ្ញា គឺជាគណៈកម្មការនៃអ្នកជំនាញឯករាជ្យ និងមានសមត្ថភាពឃ្លាំមើលសិទ្ធិមនុស្ស ដែលត្រូវបានគេទទួលស្គាល់ ដែលត្រូវបានតែងតាំង និងបោះឆ្នោតជ្រើសរើសដោយរដ្ឋជាភាគីនៃសិទ្ធិសញ្ញាសម្រាប់អាណត្តិ ០៤ (បួន) ឆ្នាំ។

[38] នីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស គឺជាអ្នកជំនាញការសិទ្ធិមនុស្សឯករាជ្យ ឬ ក្រុមនៃអ្នកជំនាញដែលរាយការណ៍ និងប្រឹក្សាយោបល់អំពីសិទ្ធិមនុស្សតាមទស្សនៈវិស័យប្រធានបទ ឬ ទស្សនៈវិស័យតាមប្រទេសជាក់លាក់។ អ្នកជំនាញការទាំងនេះមានអ្នករាយការណ៍ពិសេស តំណាងពិសេស ក្រុមការងារ និងអ្នកជំនាញឯករាជ្យ។

ឯកសារទាំងអស់ខាងលើដែលរៀបចំឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) គួរតែធ្វើតាមគោលការណ៍ណែនាំទូទៅដែលអនុម័តឡើងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សចំពោះព័ត៌មានដែលធ្វើដោយរដ្ឋក្រោមការត្រួតពិនិត្យមុនបញ្ជូនទៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)។[39]

ទាំងការប្រគល់ និងការធ្វើសេចក្តីសង្ខេបព័ត៌មានដែលរៀបចំឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ត្រូវរៀបចំឲ្យរួចរាល់យ៉ាងហោចណាស់មុន ៦សប្តាហ៍ ដើម្បីឲ្យក្រុមការងារ UPR ធានាបាននូវបែងចែកដំណាលគ្នាទៅជាភាសាផ្លូវការទាំងប្រាំមួយ របស់អង្គការសហប្រជាជាតិ។

### ៣.២.២. ពេលត្រួតពិនិត្យ

នាពេលត្រួតពិនិត្យជាសកលតាមកាលបរិច្ឆេទ មូលដ្ឋាននៃបទដ្ឋានសិទ្ធិមនុស្ស ដែលក្រុមការងារត្រួតពិនិត្យជាសកលតាមកាលកំណត់នឹងវាយតម្លៃពីវិសាលភាពដែលរដ្ឋត្រូវគោរពកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួនតាមនោះ មានដូចជា៖

- ធម្មនុញ្ញអង្គការសហប្រជាជាតិ
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
- លិខិតុបករណ៍សិទ្ធិមនុស្ស ដែលរដ្ឋនៅក្រោមការត្រួតពិនិត្យរបស់ UPR ស្ថិតក្រោមការត្រួតពិនិត្យ
- ការសន្យា និងការតាំងចិត្តដោយស្ម័គ្រចិត្តដោយរដ្ឋជាភាគីនោះបានបង្កើតឡើង (ឧទាហរណ៍៖ គោលនយោបាយសិទ្ធិមនុស្ស ឬកម្មវិធីនានាដែលត្រូវអនុវត្ត) រួមបញ្ចូលទាំងការសន្យាដែលបេក្ខជនតំណាងឲ្យរដ្ឋទាំងឡាយធ្វើការសន្យា មុនពេលបោះឆ្នោតក្នុងការក្លាយជាសមាជិកនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស
- នីតិមនុស្សធម៌អន្តរជាតិដែលនៅជាធរមានក៏រដ្ឋត្រូវគោរពផងដែរ ដើម្បីបន្ថែមពីលើ និងបង្គ្រប់ឲ្យបានពេញបរិបូរណ៍ ព្រមទាំងឲ្យមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកនឹងចរិកនៃនីតិសិទ្ធិមនុស្សអន្តរជាតិ និងនីតិមនុស្សធម៌អន្តរជាតិ។[40]

---

[39] បកប្រែពីគេហទំព័រ http://hrlibrary.umn.edu/iwraw/Inst-building-UN.pdf ជាសេចក្តីសម្រេចលេខ៥/១ បង្កើតស្ថាប័ននៃក្រុមប្រឹក្សាសិទ្ធិមនុស្សប្រជាជាតិ (Institution-building of the United Nations Human Right Council) ទំព័រ៣-៤ (ចូលមើល០១ /កញ្ញា/២០)

[40] បកប្រែពីគេហទំព័រ http://hrlibrary.umn.edu/iwraw/Inst-building-UN.pdf ជាសេចក្តីសម្រេចលេខ៥/១ បង្កើតស្ថាប័ននៃក្រុមប្រឹក្សាសិទ្ធិមនុស្សប្រជាជាតិ (Institution-building of the United Nations Human Right Council) ទំព័រ១-២ ចូលមើល០១ /កញ្ញា/២០)

ការប្រព្រឹត្តទៅនៅពេលត្រួតពិនិត្យត្រូវធ្វើឡើងដោយ**ក្រុមការងារ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ (២.២.១) និង ដោយកិច្ចសសន្ទនា/ពិភាក្សាជាអន្តរកម្ម (២.២.២) រវាងរដ្ឋស្ថិតក្រោមការត្រួតពិនិត្យ និងសមាជិក នៃអង្គការសហប្រជាជាតិ។ បន្ទាប់មក ត្រូវអនុម័តឯកសារផ្លូវការ ដែលជារបាយការណ៍បានមកពីកិច្ចសន្ទនា/ពិភាក្សាជាអន្តរកម្មនោះ (២.២.៣)។**

### ៣.២.២.១. ក្រុមការងារ នៃការត្រួតពិនិត្យជាសកលតាមការកំណត់ (Working Group)

ការត្រួតពិនិត្យធ្វើឡើងនៅទីក្រុងហ្សឺណែវដោយក្រុមការងារ នៃការត្រួតពិនិត្យជាសកលតាមការកំណត់ ដែលមានសមាជិក ៤៧ ប្រទេសជាសមាជិកក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ទោះបីជារដ្ឋជាសមាជិកណាមួយចូលរួម ក្នុងកិច្ចពិភាក្សា/សន្ទនាជាអន្តរកម្មជាមួយរដ្ឋស្ថិតនៅក្រោមការត្រួតពិនិត្យក៏ដោយ។ រដ្ឋជាសមាជិកទាំង ៤៧ បង្កើតជាទម្រង់នៃកិច្ចសន្ទនាជាអន្តរកម្ម ដែលត្រូវបានធ្វើឡើងដោយរដ្ឋដែលកំពុងស្ថិតក្រោមការពិនិត្យ និងរដ្ឋសមាជិក ព្រមទាំងអ្នកសង្កេតការណ៍នៃ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ ក្រុមការងារនេះជួបប្រជុំគ្នារយៈពេល ០២សប្តាហ៍ ទៅ០៣សប្តាហ៍ជារៀងរាល់ឆ្នាំនិងពិនិត្យ ១៦ រដ្ឋនៅវគ្គនីមួយៗ - សរុបចំនួន ៤៨ រដ្ឋក្នុងមួយឆ្នាំ។[41]

បន្ទាប់ពីដល់ការបរិច្ឆេទ នៃវេនរបស់រដ្ឋសម្រាប់ធ្វើការត្រួតពិនិត្យ និងមានឯកសារព័ត៌មាន នៃរដ្ឋរួចរាល់អស់ ការត្រួតពិនិត្យនឹងប្រព្រឹត្តទៅតាមរយៈកិច្ចសន្ទនា/ពិភាក្សាជាអន្តរកម្មរវាងរដ្ឋស្ថិតនៅក្រោមការត្រួតពិនិត្យ និងសមាជិកដទៃទៀតនៃអង្គការសហប្រជាជាតិ។ កិច្ចនេះត្រូវប្រព្រឹត្តនៅក្នុងកំឡុងពេលកិច្ចប្រជុំរបស់ក្រុមការងារ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់។ មិនត្រឹមតែប៉ុណ្ណោះ ក្រុមការងារនៃការត្រួតពិនិត្យនឹងធ្វើការត្រួតពិនិត្យ វាយតម្លៃ និងធ្វើការអនុម័តលើឯកសារដែលទាក់ទងទៅនឹងស្ថានភាពសិទ្ធិមនុស្សរបស់រដ្ឋក្រោមការត្រួតពិនិត្យ។ ក្នុងកំឡុងពេលពិភាក្សាគ្នានេះ សមាជិកណាក៏ដោយរបស់អង្គការសហប្រជាជាតិអាចតាំងជាសំណួរ យោបល់ និង/ឬធ្វើជាអនុសាសន៍ដល់រដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យ។[42]

---

[41] បកប្រែចេញពីគេហទំព័រ https://www.ohchr.org/en/hrbodies/upr/pages/basicfacts.aspx ស្តីអំពីការពិតអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ (Basic facts about the UPR) ត្រង់សំណួរទី៤ (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

[42] https://cambodia.ohchr.org/sites/default/files/book/UPR%20Chart_KH.pdf កម្រងអនុសាសន៍របស់យន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សចំពោះកម្ពុជា រៀបរៀងដោយការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ខែធ្នូ ឆ្នាំ២០១៤ ទំព័រទី៦ (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

### ៣.២.២.២. កិច្ចសន្ទនា/ពិភាក្សាជាអន្តរកម្ម

ក្នុងកិច្ចសន្ទនា/ពិភាក្សាជាអន្តរកម្ម រវាងរដ្ឋស្ថិតនៅក្រោមការត្រួតពិនិត្យ និងរដ្ឋផ្សេងទៀតជាសមាជិក នៃអង្គការសហប្រជាជាតិ មានរយៈពេលចំនួន ០៣ម៉ោង[43] ដោយ ០១ម៉ោង រដ្ឋស្ថិតក្រោមការត្រួតពិនិត្យត្រូវ ៖

- ធ្វើបទបង្ហាញណែនាំអំពីរបាយការណ៍ជាតិរបស់ខ្លួន រដ្ឋស្ថិតក្រោមការត្រួតពិនិត្យប្រើពេលវេលានេះ ជាដំបូង សម្រាប់ណែនាំរបាយការណ៍ជាតិរបស់ខ្លួន។ ជាធម្មតា អ្នកតំណាងជាន់ខ្ពស់របស់រដ្ឋនោះ ជាអ្នកដែលត្រូវធ្វើបទបង្ហាញរបាយការណ៍នោះ
- ឆ្លើយតបនឹងសំណួរ និងអនុសាសន៍ រដ្ឋស្ថិតក្រោមការត្រួតពិនិត្យដដែល ឆ្លើយតបទៅនឹងសំណួរ និងអនុសាសន៍ដែលបានលើកឡើងក្នុងអំឡុងពេល នៃកិច្ចសន្ទនា/ពិភាក្សាអន្តរកម្មដោយប្រទេស ឬ រដ្ឋដទៃ។ រដ្ឋស្ថិតក្រោមការត្រួតពិនិត្យឆ្លើយតបប្រមាណ ១៥ ទៅ ៣០ មតិយោបល់ ដែលធ្វើឡើងដោយប្រទេសទាំងនោះ។ ជាធម្មតា រដ្ឋស្ថិតក្រោមការត្រួតពិនិត្យឆ្លើយចំនួន ០៣ (បី) ដងក្នុងអំឡុងពេលត្រួតពិនិត្យ
- និងសរុបសេចក្តីទៅនឹងមតិយោបល់ដែលបាន នៅពេលចុងបញ្ចប់។

និង០២ម៉ោងទៀត សម្រាប់រដ្ឋជាសមាជិក នៃអង្គការសហប្រជាជាតិសួរសំណួរ និងផ្តល់នូវអនុសាសន៍ ដោយកំឡុងពេលនេះ ត្រូវបានបែងចែកសម្រាប់រដ្ឋ ដើម្បីសួរសំណួរ និងផ្តល់យោបល់ឬអនុសាសន៍ដល់រដ្ឋស្ថិតក្រោមការត្រួតពិនិត្យ។ រដ្ឋដែលជាផ្នែកនៃក្រុមប្រឹក្សាសិទ្ធិមនុស្សអាចនិយាយបាន ០៣នាទី និងរដ្ឋអ្នកសង្កេតការណ៍ នាទី។ ទោះយ៉ាងណាប្រទេសខ្លះប្រើរយៈពេល ១ នាទីនៃពេលវេលាដែលបានបែងចែកដើម្បីធ្វើការផ្តល់យោបល់ឬអនុសាសន៍។ ការផ្តល់យោបល់ផ្ទាល់មាត់ប្រហែលជា ២០ ទៅ ៤០ ត្រូវបានធ្វើឡើងក្នុងការត្រួតពិនិត្យ។ ចំនួនអនុសាសន៍ជាទូទៅពឹងផ្អែកលើកម្រិតចំណាប់អារម្មណ៍ការត្រៀមរៀបចំ និងការចូលរួមរបស់បណ្តារដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀតរបស់អង្គការសហប្រជាជាតិទាក់ទងនឹងរដ្ឋស្ថិតក្រោមការត្រួតពិនិត្យ។[44]

---

[43] បកប្រែចេញពីគេហទំព័រ http://hrlibrary.umn.edu/iwraw/Inst-building-UN.pdf អំពី សេចក្តីសម្រេចលេខ៥/១ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការកសាងស្ថាប័នក្រុមប្រឹក្សាសិទ្ធិមនុស្ស របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (Institution-building of the United Nations Human Rights Council) ចំណុចD២ Modalities លេខ២២

[44] បកប្រែចេញពីគេហទំព័រ https://www.upr-info.org/sites/default/files/general-document/pdf/uprtoolkit.pdf របស់កម្មវិធីគាំពារសិទ្ធិមនុស្ស (Human Right Project) មជ្ឈមណ្ឌលទីក្រុងយុត្តិធម៌ (at the Urban Justice Center) ២០១០ ទំព័រទី១១ ស្តីអំពី

### ៣.២.២.៣. ការអនុម័តជាផ្លូវការ នៃរបាយការណ៍លទ្ធផល

បន្ទាប់ពីបានធ្វើកិច្ចសន្ទនា/ពិភាក្សា ក្រុមការងារនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់សរសេររបាយការណ៍ ជាទូទៅក្នុងរយៈពេល ៤៨ ម៉ោងបន្ទាប់ពីបញ្ចប់សម័យប្រជុំ ដោយសង្ខេបជាបញ្ជីនៃសំណួរ និងអនុសាសន៍ដែលបានលើកឡើងក្នុងកំឡុងពេលត្រួតពិនិត្យក៏ដូចជា ការសន្យាដោយស្ម័គ្រចិត្តណាមួយដែលធ្វើឡើងដោយរដ្ឋស្ថិតក្រោមការត្រួតពិនិត្យ។ Troika ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ដោយមានការចូលរួមពីរដ្ឋស្ថិតក្រោមការត្រួតពិនិត្យ និងជំនួយពីការិយាល័យ OHCHR។[45]

#### ក. ដំណាក់កាលនៃការរៀបចំរបាយការណ៍ដោយ Troika

##### ក.១. អ្វីជាTroika?[46]

Troika គឺជាបណ្តុំដែលកើតឡើងពីបីរដ្ឋដែលរដ្ឋទាំងនោះ ជាសមាជិកនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស (HRC) មកពីក្រុមនៃតំបន់ខុសៗគ្នា។ នៅពេលដល់កាលបរិច្ឆេទនៃការត្រួតពិនិត្យរដ្ឋនីមួយៗ Troika ត្រូវបានកើតឡើងពីការជ្រើសរើសក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (HRC) ដែលប្រព្រឹត្តទៅនៅដើមឆ្នាំ។ រដ្ឋដែលត្រូវបានជ្រើសរើសអាចបញ្ជូនសមាជិកគណៈប្រតិភូ ឬ អ្នកជំនាញឲ្យមានអំណាចធ្វើជា Troika។ រដ្ឋក្រោមការត្រួតពិនិត្យអាចធ្វើសំណើថារដ្ឋមួយក្នុងចំណោមរដ្ឋទាំងបីអាចត្រូវបានជ្រើសរើសមកពីក្រុមនៃរដ្ឋក្នុងតំបន់ដូចគ្នា ឬ រដ្ឋមួយនៃសមាជិក Troika អាចត្រូវបានជំនួស ហើយទោះបីតែក្នុងពេលណាក៏ដោយ រដ្ឋជាសមាជិកនៃ Troika ណាមួយអាចស្នើសុំដកចេញពីការចូលរួមយ៉ាងជាក់លាក់។

##### ក.២. ដំណើរការនៃតួនាទី Troika

ក្រោយពីការត្រួតពិនិត្យរបស់ក្រុមការងារនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់រួចមក Troika នឹងរៀបចំរបាយការណ៍មួយ ដោយមានការចូលរួមពីរដ្ឋស្ថិតក្រោមការត្រួតពិនិត្យ និងជំនួយពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)។ របាយការណ៍នេះ ត្រូវចាត់ទុកជា

---

កិច្ចសន្ទនា/ពិភាក្សាជាអន្តរកម្ម រវាងរដ្ឋស្ថិតនៅក្រោមការត្រួតពិនិត្យ និងរដ្ឋផ្សេងទៀតជាសមាជិកនៃអង្គការសហប្រជាជាតិ (Interactive dialogue between the country under review and other UN countries)

[45] បកប្រែចេញពីគេហទំព័រ https://www.upr-info.org/sites/default/files/general-document/pdf/uprtoolkit.pdf របស់កម្មវិធីគាំពារសិទ្ធិមនុស្ស (Human Right Project) មជ្ឈមណ្ឌលទីក្រុងយុត្តិធម៌ (at the Urban Justice Center) ២០១០ ទំព័រទី១២ ស្តីអំពីការអនុម័តជាផ្លូវការនៃរបាយការណ៍លទ្ធផល (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

[46] បកប្រែចំណុចស្តីពី **Troika** ពី https://www.upr-info.org/en/upr-process/what-is-it/qa-on-the-modalities-of-the-upr-process#5 (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

**របាយការណ៍លទ្ធផល** រៀបរាប់យ៉ាងសង្ខេបអំពីកិច្ចសន្ទនា/ពិភាក្សាជាអន្តរកម្មនេះ។ ហេតុដូចនេះហើយ របាយការណ៍នេះ រួមមាន សំណួរ យោបល់ និងអនុសាសន៍ ដែលដាក់ដោយរដ្ឋនានា ដល់រដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យ ព្រមទាំងការឆ្លើយតបរបស់រដ្ឋដែលស្ថិតនៅក្រោមការត្រួតពិនិត្យ។

ពេលវេលាត្រូវបានផ្តល់ឲ្យក្រុមការងារដើម្បីអនុម័ត **របាយការណ៍លទ្ធផល** នីមួយៗរបស់រដ្ឋដែលស្ថិតក្រោមការត្រួតពិនិត្យ គឺនៅក្នុងកំឡុងសម័យប្រជុំនោះ។ រដ្ឋស្ថិតនៅក្រោមការត្រួតពិនិត្យមានឱកាសផ្តល់យោបល់ជាបឋម នៅលើអនុសាសន៍នានា ដោយជ្រើសរើសថាព្រមទទួលយក ឬ គ្រាន់តែធ្វើការកត់សម្គាល់លើអនុសាសន៍ទាំងនោះ។ ទាំងអនុសាសន៍ដែលបានទទួលយក និងអនុសាសន៍ដែលគ្រាន់តែធ្វើការកត់សម្គាល់ ត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍នេះដែរ។

### ៣.២.៣. ក្រោយការត្រួតពិនិត្យ

បន្ទាប់មកទៀត របាយការណ៍នេះ ត្រូវដាក់ជូនសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិ[47]មនុស្សដើម្បីទទួលការអនុម័ត នៅក្នុងសម័យប្រជុំបន្ទាប់របស់ខ្លួន (ប្រហែលបួនខែបន្ទាប់ពីពេលត្រួតពិនិត្យ)។ នៅពេលនោះ រដ្ឋដែលស្ថិតក្រោមការត្រួតពិនិត្យអាចឆ្លើយនឹងសំណួរ និងបញ្ហានានាដែលមិនទាន់បានឆ្លើយនៅក្នុងកំឡុងពេលក្រុមការងារនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ព្រមទាំងឆ្លើយតបចំពោះអនុសាសន៍ដែលត្រូវលើកឡើងដោយរដ្ឋនានាក្នុងកំឡុងពេលនៃការត្រួតពិនិត្យ។ ពេលវេលាក៏មានផ្តល់ជូនរដ្ឋជាសមាជិក និងរដ្ឋ

[47] ក្រុមប្រឹក្សាសិទ្ធិមនុស្សមានការប្រជុំសាមញ្ញតិចជាង ០៣ (បី) ដងក្នុងមួយឆ្នាំសម្រាប់រយៈពេលយ៉ាងតិច ១០ (ដប់) សប្តាហ៍។ ពួកគេប្រព្រឹត្តទៅនៅខែមីនា (បួនសប្តាហ៍) ខែមិថុនា (បីសប្តាហ៍) និងខែកញ្ញា (បីសប្តាហ៍)។ ប្រសិនបើប្រទេស១/៣ (មួយភាគបី)នៃរដ្ឋជាសមាជិកស្នើសុំ ដូច្នេះក្រុមប្រឹក្សាសិទ្ធិមនុស្សអាចសម្រេចចិត្តក្នុងពេលណាមួយដើម្បីបើកការប្រជុំវិសាមញ្ញពិសេសមួយដើម្បីដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្ស និងភាពអាសន្ននានា (https://www.ohchr.org/en/hrbodies/hrc/pages/sessions.aspx) ពេលសម័យប្រជុំសាមញ្ញនីមួយៗមានលក្ខណៈទៀងទាត់តាមលំដាប់លំដោយ និងមានធាតុរបៀបវារៈចំនួន១០ (ដប់) ក្នុងនោះគឺមានរបៀបវារៈទី៦ ស្តីអំពី ការត្រួតពិនិត្យជាសកលតាមកាលកំណត់ ជាពេលដែលត្រូវអនុម័តជាផ្លូវការនូវរបាយការណ៍លទ្ធផល ដែលធ្វើឡើងដោយក្រុមការងារត្រួតពិនិត្យជាសកលតាមកាលលកំណត់ដោយការត្រួតពិនិត្យរដ្ឋនីមួយៗ ព្រមទាំងអាចចូលមើលបន្ថែមតាមរយៈគេហទំព័រ https://www.eda.admin.ch/dam/eda/en/documents/publications/InternationaleOrganisationen/Uno/Human-rights-Council-practical-guide_en ស្តីអំពី The Human Rights Council A practical guide ទំព័រទី៦ (គេហទំព័រទាំងពីនេះ(ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០)

សង្កេតការណ៍ ដែលចង់សម្តែងមតិរបស់ខ្លួន អំពីលទ្ធផលនៃការត្រួតពិនិត្យនេះ និងក៏មានផ្តល់ជូនស្ថាប័នសិទ្ធិមនុស្សជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូដទៃទៀត ដើម្បីផ្តល់យោបល់ជាទូទៅដែរ។[48]

### ៣.៣. ការតាមដានការអនុវត្តអនុសាសន៍

រដ្ឋដែលស្ថិតក្រោមការត្រួតពិនិត្យ តែងតែមានការទទួលខុសត្រូវជាបឋម ដើម្បីអនុវត្តអនុសាសន៍នានាដែលមានក្នុងរបាយការណ៍លទ្ធផលចុងក្រោយ។ ការត្រួតពិនិត្យជាសកលធានាថា គ្រប់ប្រទេស ត្រូវទទួលខុសត្រូវចំពោះការរីកចម្រើន ឬ ការខកខានក្នុងការអនុវត្តអនុសាសន៍ទាំងនេះ។ ក្នុងកំឡុងពេល នៃការត្រួតពិនិត្យចុងក្រោយ រដ្ឋត្រូវបានរំពឹងថា នឹងផ្តល់ព័ត៌មានអំពីវិធានការនានាដែលខ្លួនបានចាត់ឡើងដើម្បីអនុវត្ត អនុសាសន៍ផ្សេងៗដែលបានផ្តល់ពីលើកមុន ព្រមទាំងអំពីការវិវត្តន៍ណាមួយនៅក្នុងវិស័យសិទ្ធិមនុស្ស។ សហគមន៍អន្តរជាតិ មានតួនាទីជួយអនុវត្តន៍អនុសាសន៍ទាំងនេះតាមរយៈជំនួយបច្ចេកទេស និងកសាងសមត្ថភាព និងពិគ្រោះយោបល់ជាមួយរដ្ឋសាមី។[49]

#### ៣.៣.១. យន្តការដើម្បីត្រួតពិនិត្យ និងធានាការអនុវត្ត

ដើម្បីឲ្យមានការកែលម្អនូវស្ថានភាពសិទ្ធិមនុស្សទៅតាមអនុសាសន៍ទាំងឡាយ ដែលមាននៅក្នុងរបាយការណ៍លទ្ធផលរបស់រដ្ឋស្ថិតក្រោមការត្រួតពិនិត្យ គឺមានយន្តការដើម្បីពិនិត្យ និងធានាការអនុវត្តក្នុងកម្រិតជាអន្តរជាតិ (៣.១.១)និងកម្រិតជាតិ(៣.១.២)។

##### ៣.៣.១.១. ក្នុងកម្រិតអន្តរជាតិ

តាមដានការអនុវត្ត ដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ៥/១

ក. របាយការណ៍លទ្ធផលគួរតែត្រូវបានអនុវត្តដោយរដ្ឋាភិបាលដោយមានការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗ។

ខ. ការត្រួតពិនិត្យនៅវដ្តបន្ទាប់គួរតែផ្តោតលើការអនុវត្តលទ្ធផលមុន។

---

[48] https://cambodia.ohchr.org/sites/default/files/book/UPR%20Chart_KH.pdf កម្រងអនុសាសន៍របស់យន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សចំពោះកម្ពុជា រៀបរៀងដោយការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ខែធ្នូ ឆ្នាំ២០១៤ ទំព័រទី៧

[49] ដូចគ្នានឹង Footnote៤៨

គ. ការពង្រឹងសមត្ថភាព និងជំនួយបច្ចេកទេសអាចរកបានសម្រាប់ប្រទេសនានា ដើម្បីប្រើប្រាស់ក្នុងអំឡុងពេលអនុវត្តផ្នែកនៃដំណើរការការត្រួតពិនិត្យជាសកលតាមកាលកំណត់។

ឃ. ក្រុមប្រឹក្សាសិទ្ធិមនុស្សក៏អាចមើលករណីផ្សេងៗដែលប្រទេសនានាមិនសហការ។ ប្រសិនបើប្រទេសមួយមិនបង្ហាញកិច្ចសហប្រតិបត្តិការជាមួយការត្រួតពិនិត្យជាសកលតាមកាលកំណត់ ក្រុមប្រឹក្សាសិទ្ធិមនុស្សអាចសម្រេចថាតើវិធានការអ្វីនឹងឆ្លើយតបទៅនឹងប្រទេសនោះ

### ៣.៣.១.២. ក្នុងកម្រិតប្រទេស[50]

របាយការណ៍លទ្ធផលរបស់ការត្រួតពិនិត្យជាឧបករណ៍សិទ្ធិមនុស្ស ដែលនឹងត្រូវអនុវត្តៈ

ក. របាយការណ៍លទ្ធផលរបស់ការត្រួតពិនិត្យផ្តល់នូវផ្លូវថ្មីសម្រាប់អង្គការក្នុងតំបន់ដើម្បីចូលរួមក្នុងដំណើរការអនុវត្តន៍ និងធ្វើការជាមួយរដ្ឋាភិបាល។

ខ. អង្គការមិនមែនរដ្ឋាភិបាលអាចឃ្លាំមើលការអនុវត្តរបស់រដ្ឋាភិបាលក្នុងការផ្តល់អនុសាសន៍នៅក្នុងឯកសារលទ្ធផល។

គ. របាយការណ៍លទ្ធផលអាចជាឧបករណ៍មានប្រយោជន៍ដើម្បីជំរុញគោលនយោបាយ ដែលដោះស្រាយបញ្ហាសំខាន់ៗរបស់សិទ្ធិមនុស្ស។

ឃ. របាយការណ៍លទ្ធផលក៏អាចជាផ្នែកមួយនៃរបាយការណ៍ស្រមោលដល់ស្ថាប័នសន្ធិសញ្ញា។

### ៣.៣.២. របាយការណ៍ពាក់កណ្តាលវដ្ត ( Mid-term Report )

រដ្ឋនានាត្រូវបានលើកទឹកចិត្តឱ្យផ្តល់ជូនដល់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (HRC) នូវការធ្វើបច្ចុប្បន្នភាពបណ្តោះអាសន្នស្តីពីការតាមដាន ដើម្បីទទួលយកអនុសាសន៍ក្នុងទម្រង់របាយការណ៍ពាក់កណ្តាលវដ្ត (Mid-term Report)។ ទោះបីនីតិវិធីនេះជាការស្ម័គ្រចិត្តសុទ្ធសាធក៏ដោយក៏មានរដ្ឋជាច្រើនដែលកំពុងអនុវត្តផងដែរ។ ការធ្វើរបាយការណ៍ពាក់កណ្តាលវដ្ត ជាជោគជ័យនៃដំណាក់កាលតាមដាន ដែលកំណត់ប្រសិទ្ធភាព និងភាពជឿជាក់នៃយន្តការការត្រួតតពិនិត្យជាសកលតាមកាលកំណត់។ ការធ្វើរបាយការណ៍ពាក់

[50] បកប្រែចេញពីគេហទំព័រ https://www.upr-info.org/sites/default/files/general-document/pdf/uprtoolkit.pdf របស់កម្មវិធីគាំពារសិទ្ធិមនុស្ស (Human Right Project) មជ្ឈមណ្ឌលទីក្រុងយុត្តិធម៌ (at the Urban Justice Center) ២០១០ ទំព័រទី១៤ ស្តីអំពីការតាមដាន និងការអនុវត្តអនុសាសន៍ (Follow-up and implementation of recommendations)

កណ្ដាលរដ្ឋ ក៏បង្ហាញពីការប្ដេជ្ញាចិត្តរបស់រដ្ឋក្នុងការលើកកម្ពស់ និងពង្រឹងសិទ្ធិមនុស្ស។ ការត្រួតពិនិត្យនៅវគ្គទី ២ មានគោលបំណងវាយតម្លៃកំរិតនៃការអនុវត្ត។[51]

[51] https://www.eda.admin.ch/dam/eda/en/documents/publications/InternationaleOrganisationen/Uno/Human-rights-Council-practical-guide_en ស្ដីអំពី The Human Rights Council A practical guide ទំព័រទី១២

# ជំពូកទី៤ តួអង្គដែលចូលរួមក្នុង
# យន្តការត្រួតពិនិត្យជាសកលតាមកាល
# កំណត់

## ជំពូកទី៤ តួអង្គដែលចូលរួមក្នុងយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់[52]

អ្នកចូលរួមជាមួយយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ក្នុងនោះ មានអ្នកដែលជាតួអង្គស្នូលក្នុងការត្រួតពិនិត្យ **គឺរដ្ឋ** (១) មានរដ្ឋក្រោមការត្រួតពិនិត្យ និងរដ្ឋផ្តល់អនុសាសន៍។ ចំណែកតួអង្គដែលចូលរួមក្នុងការឃ្លាំមើលសិទ្ធិមនុស្ស និងរាយការណ៍ព័ត៌មានទាំងនោះទៅកាន់សម័យប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សពេលដំណើរត្រួតពិនិត្យជាសកលតាមកាលកំណត់ ក្រៅពីការិយាល័យឧត្តមក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិប្រចាំប្រទេស ឬ តំបន់ជាដើមនោះ គឺមាន **ភាគីពាក់ព័ន្ធ** (២) ដែលជាអ្នកចូលរួមក្នុងដំណើរមួយនេះទៀតផង។ ភាគីទាំងនោះ មានដូចជា អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នសិទ្ធិមនុស្សជាតិ អ្នកការពារសិទ្ធិមនុស្ស (Human Right Defenders) ស្ថាប័នសិក្សា (Academic Institution) និងវិទ្យាស្ថានស្រាវជ្រាវ ព្រមទាំងអង្គការក្នុងតំបន់ ក៏ដូចជាតំណាងសង្គមស៊ីវិលជាដើម។ មិនតែប៉ុណ្ណោះ ភាគីដែលពាក់ព័ន្ធផ្សេងទៀត ក៏ត្រូវបានផ្តល់នូវឱកាសក្នុងការផ្ញើរបាយការណ៍ឲ្យក្រុមការងារត្រួតពិនិត្យ ដើម្បីពិនិត្យផងដែរ[53] ដូចមានបញ្ជាក់ក្នុងសេចក្តីសម្រេចលេខ៥/១ ចំណុច B លេខ1 អក្សរ(m) ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧។[54]

### ៤.១. រដ្ឋ

និយាយជារួម រដ្ឋចាត់ទុកការត្រួតពិនិត្យជាសកលតាមកាលកំណត់ជាយន្តការដែលមិនអាចខ្វះបាន និងជាសមិទ្ធិផលដ៏លេចធ្លោរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ យន្តការនេះគឺជាយន្តការថ្មីសម្រាប់ស្វាគមន៍ចំពោះការចាកចេញពីឱនភាព នៃគណៈកម្មការសិទ្ធិមនុស្ស និងជាយន្តការដែលត្រូវបានគេមើលឃើញថា ដូចជាមធ្យោបាយដែលមិនមែនជាសត្រូវជាមួយនឹងអនុសាសន៍ដែលត្រូវបានផ្តល់ក្នុងសេចក្តីស្មោះត្រង់ល្អនោះទេ ព្រមទាំងរួមចំណែកដល់ការចូលរួមរបស់រដ្ឋាភិបាលពិតប្រាកដក្នុងដំណើរនៃការអនុវត្ត។ នីតិវិធី នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ជំរុញការចូលរួមក្នុងន័យស្ថាបនាជាមួយយន្តការ និងទំនាក់ទំនងប្រកបដោយផ្លែផ្ការវាងភាគីពាក់ព័ន្ធទាំងអស់។ ជំពូកនេះត្រូវបានបែងចែករវាងការចូលរួមរបស់រដ្ឋជាមួយនឹងការត្រួតពិនិត្យជាសកលតាមកាលកំណត់ក្នុងតួនាទីរៀងៗខ្លួនក្នុងនាមជារដ្ឋក្រោមការត្រួតពិនិត្យ និងផ្តល់អនុសាសន៍។

---

[52] បកប្រែពីគេហទំព័រ https://www.upr-info.org/sites/default/files/general-document/pdf/2016_the_butterfly_effect.pdf ត្រង់ចំណុច A checklist for successful UPR engagement ទំព័រ៣៩

[53] បកប្រែចេញពី " Universal Periodic Review: information and guidelines for relevant stakeholders' written submission ទំព័រទី២ អាចស្វែងរកបានតាមរយៈ https://www.ohchr.org/Documents/HRBodies/UPR/TechnicalGuideEN.pdf

[54] អាចស្វែងរកបានតាមរយៈ http://hrlibrary.umn.edu/iwraw/Inst-building-UN.pdf

### ៤.១.១. រដ្ឋក្រោមការត្រួតពិនិត្យ (State Under Review (SUR))

រដ្ឋនានាពិចារណាលើអនុសាសន៍ក្នុងការត្រួតពិនិត្យជាសកលតាមកាលកំណត់ណា ដែលមានប្រយោជន៍ទាំងក្នុងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេស និងទាំងក្នុងលក្ខខណ្ឌនៃការជំរុញកិច្ចពិភាក្សាមួយក្នុងក្របខណ្ឌរដ្ឋាភិបាលអំពីវិធីអនុវត្តអនុសាសន៍ល្អបំផុត។

#### ៤.១.១.១. ការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល

ទោះបីជារដ្ឋទាំងឡាយត្រូវបានលើកទឹកចិត្តឲ្យរៀបចំរបាយការណ៍សម្រាប់ការត្រួតពិនិត្យជាកំណត់នៅថ្នាក់ជាតិរបស់ពួកគេតាមរយៈ " ដំណើរការពិគ្រោះយោបល់យ៉ាងទូលំទូលាយ (Broad Consultation) នៅថ្នាក់ជាតិជាមួយភាគីពាក់ព័ន្ធទាំងអស់" ក៏ដោយ ក៏នៅក្នុងការអនុវត្តជាក់ស្តែងជាញឹយៗ ការរៀបចំរាបយការណ៍ ការពិគ្រោះយោបល់ត្រូវបានដាក់ឲ្យអាចធ្វើទៅបាន ដោយមាននូវមូលនិធិ និងសមត្ថភាពរបស់រដ្ឋាភិបាល។ ម៉្យាងទៀត គឺកង្វះនៃការឲ្យនិយមន័យច្បាស់លាស់ នៃអ្វីដែលជាដំណើរការពិគ្រោះយោបល់ទូលំទូលាយ ដែលគួរតែមាន។ ចន្លោះខ្វះខាតនេះ អាចបង្កើតការរំពឹងទុកផ្ទុយគ្នារវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល។ សម្រាប់ចៀសវាងការយល់ច្រឡំ ការសំខាន់ជាខ្លាំង ដែលរដ្ឋត្រូវប្រកាន់ខ្ជាប់នូវកិច្ចពិភាក្សាប្រកបដោយតម្លាភាព និងស្ថាបនាគ្នា នៅគ្រប់ដំណាក់កាលនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដោយរួមទាំងការពិភាក្សាអំពីវិធីអនុវត្តការពិគ្រោះយោបល់ក្នុងដំណើរការរៀបចំសេចក្តីព្រាងរបាយការណ៍ជាតិ និងក្នុងដំណាក់កាលតាមដាន។ ដើម្បីឱ្យកាន់តែទូលំទូលាយ និងមានអត្ថន័យ រដ្ឋជាធម្មតាទទួលបានអត្ថប្រយោជន៍ពីការសហការជាមួយស្ថាប័នសិទ្ធិមនុស្សជាតិ (National Human Right Institution) ប្រសិនបើមានស្ថាប័នសិទ្ធិមនុស្សជាតិក្នុងការពិគ្រោះយោបល់ទាំងក្នុង និងក្រៅរដ្ឋធានី។ វាចាំបាច់ណាស់ដែលរដ្ឋក្រោមការត្រួតពិនិត្យពិគ្រោះយោបល់ត្រូវអនុលោមជាមួយនឹងសាកលភាវូបនីយកម្មនៃសិទ្ធិមនុស្ស[55] គឺមានសមភាពយេនឌ័រ និងអង្គការសង្គមស៊ីវិលមិនត្រូវបានគេដកចេញដោយផ្អែកលើសិទ្ធិដែលពួកគេកំពុងជ្រោមជ្រែងនោះទេ។ ការអញ្ជើញអ្នកចូលរួមផ្សេងៗគួរតែត្រូវមានជាមុនទើបល្អ ដោយរបៀបវារៈត្រូវបានបង្កើតឡើងដោយសហការជាមួយ ស្ថាប័នសិទ្ធិមនុស្សជាតិ (NHRI) និងអង្គការសង្គមស៊ីវិល (CSOs)។ ឧបសគ្គដែលបន្ថែមអាចលេចឡើងដោយសារតែការសម្របសម្រួលផ្ទៃក្នុងរបស់រដ្ឋាភិបាលខ្សោយបង្កើតឲ្យមានភាពមិនច្បាស់អំពីអ្វីដែលក្រសួងពាក់ព័ន្ធគួរតែនាំយកមកក្នុងការរៀបចំការពិគ្រោះយោបល់។

[55] មានន័យថា សិទ្ធិមនុស្សមានវត្តមាន និងត្រូវផ្តល់នៅគ្រប់ទីកន្លែង និងគ្រប់មនុស្សទូទៅ

ដូចអ្វីដែលបានបញ្ជាក់រួចមកហើយនូវ យន្តការជាតិសម្រាប់ការធ្វើរបាយការណ៍ និងការតាមដាន (National Mechanism for Reporting and Follow-up (NMRF)) ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពគឺជាក្របខ័ណ្ឌមានប្រយោជន៍សម្រាប់លើកកម្ពស់ការពិគ្រោះយោបល់។ ភាគីពាក់ព័ន្ធគួរតែប្រកាន់នូវគោលបំណងដើម្បីបង្កើតស្តង់ដារក្នុងការកសាងទាំងបរិមាណ និងគុណភាពនៃការពិគ្រោះយោបល់ទូទាំងវដ្តរបស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់។

### ៤.១.១.២. សកម្មភាពលើអនុសាសន៍ដែលបានកត់សម្គាល់

ប្រទេសមួយចំនួនមិនច្រានចោលសកម្មភាព ដែលត្រូវបានអនុវត្តលើអនុសាសន៍ និងត្រូវបានកត់សម្គាល់ដោយរដ្ឋនោះទេ។ កាលពីមុនអនុសាសន៍មួយចំនួនត្រូវបានគេកត់សម្គាល់ថា អនុសាសន៍ទាំងនោះត្រូវបានគេចាត់ទុកជាការចាំបាច់ដើម្បីបង្កើតការជជែកដេញដោលជាសាធារណៈ ដើម្បីឱ្យមេដឹកនាំនយោបាយធ្វើការសម្រេចចិត្តចុងក្រោយ ដោយតើត្រូវទទួលយក ឬ កត់សម្គាល់អនុសាសន៍ទាំងនោះ។

### ៤.១.១.៣. ការសម្រេចចិត្តលើស្ថានភាពអនុសាសន៍

ខណៈពេលដែលកត្តាសម្រាប់ធ្វើការសម្រេចចិត្តលើស្ថានភាពអនុសាសន៍ខុសគ្នាភាគច្រើន រដ្ឋក្រោមការត្រួតពិនិត្យនានាពិចារណាលើអនុសាសន៍ ដែលមានអត្ថប្រយោជន៍ក្នុងគោលបំណងកែលម្អកំណត់ត្រាសិទ្ធិមនុស្សរបស់ពួកគេ។

ប្រទេសមួយចំនួនបានសម្រេចចិត្តលើអនុសាសន៍ជាច្រើនតាមដែលអាចធ្វើទៅបាន ក្នុងកំឡុងពេលត្រួតពិនិត្យ ខណៈពេលដែលប្រទេសផ្សេងទៀតត្រូវការការពិគ្រោះយោបល់ និងការឆ្លុះបញ្ចាំងបន្ថែមទៀត ហើយត្រូវបានទុកអនុសាសន៍ទាំងអស់នោះឲ្យរងចាំការទទួលយក។ អនុសាសន៍មួយចំនួនដែលត្រូវបានកត់សម្គាល់ឃើញថា មិនចាំបាច់ជាមួយនឹងសេចក្តីប៉ងប្រាថ្នាអំពីសិទ្ធិមនុស្សរបស់រដ្ឋទេ តែនិងអាចត្រូវបានទទួលយកប្រសិនបើអនុសាសន៍ទាំងនោះត្រូវបានគេបកស្រាយខុសគ្នា ប៉ុន្តែជាឧទាហរណ៍ប្រសិនបើការសម្រេចចិត្តទទួលយកអនុសាសន៍ត្រូវការការយល់ព្រមពីសភានោះ រដ្ឋាភិបាលមិនអាចទទួលយកការផ្តល់យោបល់មុនការសម្រេចចិត្តរបស់សភាបាននោះទេ។

រដ្ឋដែលបានទុកអនុសាសន៍ទាំងអស់ដែលកំពុងរង់ចាំដល់ដំណាក់កាលអនុម័តបានរកឃើញថានេះគឺជាការអនុវត្តមានប្រយោជន៍។ ជាទូទៅ គឺជាគំនិតល្អរបស់រដ្ឋស្ថិតក្រោមការត្រួតពិនិត្យក្នុងការទុកអនុសាសន៍ទាំងអស់ដែលមិនទាន់បានសំរេចរហូតដល់ដំណាក់កាលអនុម័ត ដើម្បីសម្របសម្រួលកិច្ចពិភាក្សាអន្តរក្រសួង

និងការពិភាក្សាជាមួយនឹងសង្គមស៊ីវិលលើស្ថានភាពអនុសាសន៍បង្កើនលទ្ធភាពសម្រាប់ការអនុវត្តប្រកបដោយចីរភាព។

ការធ្វើរបាយការណ៍ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សរយៈពេល ០១ ឆ្នាំបន្ទាប់ពីការត្រួតពិនិត្យជាសាកលតាមកាលកំណត់ស្តីពីស្ថានភាពអនុវត្តនៃអនុសាសន៍ចំនួន ០៥ ហើយបញ្ជូនរបាយការណ៍ពាក់កណ្តាលវដ្តទៅក្រុមប្រឹក្សាសិទ្ធិមនុស្សដើម្បីរាយការណ៍អំពីការទទួលនូវវឌ្ឍនភាព ព្រមទាំងរបាយការណ៍ស្តីពីអនុសាសន៍ដែលត្រូវបានទទួលទាំងអស់ ទាំងការទទួលយកទាំងការកត់សំគាល់នៅក្នុងរបាយការណ៍ជាតិ។

ការបង្កើតយន្តការជាតិអចិន្ត្រៃយ៍សម្រាប់ការធ្វើរបាយការណ៍ និងតាមដាន (NMRFs) ដែលមានបញ្ចូលនូវចំណុចប្រសព្វនៃរដ្ឋមន្ត្រីដែលមានអាណត្តិច្បាស់លាស់ ដើម្បីពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់របស់ការត្រួតពិនិត្យជាសាកលតាមកាលកំណត់។ យន្តការជាតិសម្រាប់ការធ្វើរបាយការណ៍ និងតាមដានមានការមូលមតិគ្នាដ៏លើសលប់ក្នុងចំណោមរដ្ឋដែលថា យន្តការជាតិសម្រាប់ការធ្វើរបាយការណ៍ និងតាមដាន (NMRFs) ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ដើម្បីជំនួសរចនាសម្ព័ន្ធអង្គការអាដហុក (ad hoc) ក្នុងគោលបំណងសម្រាប់ធានាឱ្យមានការអនុវត្តប្រកបដោយចីរភាព នៃអនុសាសន៍ការត្រួតពិនិត្យជាសាកលតាមកាលកំណត់។ សម្រាប់ការធ្វើឱ្យមានប្រសិទ្ធិភាព យន្តការជាតិសម្រាប់ការធ្វើរបាយការណ៍ និងតាមដាន (NMRFs) ចាំបាច់ត្រូវមានមូលដ្ឋានទិន្នន័យ (Database[56]) ដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់ និងបញ្ចូលនូវរាល់អនុសាសន៍ស្តីពីសិទ្ធិមនុស្សដែលទទួលបានពីយន្តការក្នុងតំបន់ និងអន្តរជាតិ រួមមានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងគោលដៅគោលដៅពាក់ព័ន្ធ ព្រមទាំងការកម្រិតទុកជាមុន។ មូលដ្ឋានទិន្នន័យសាធារណៈគួរតែមានសូចនាករ S.M.A.R.T [57] ប្រឆាំងនឹងវឌ្ឍនភាពដែលបានបង្កើតឡើងក្នុងការអនុវត្តអនុសាសន៍ត្រូវបានវាយតម្លៃ។

---

[56] មូលដ្ឋានទិន្នន័យនៃអនុសាសន៍របស់ការត្រួតពិនិត្យជាសាកលតាមកាលកំណត់ និងការសន្យាស្ម័គ្រចិត្តអនុញ្ញាតឲ្យមានការចូលមើល និងស្វែងរករាល់អនុសាសន៍របស់ការត្រួតពិនិត្យជាសាកលតាមកាលកំណត់ និងការសន្យាស្ម័គ្រចិត្ត ដែលមានប្រភេទជាច្រើន ៖ រដ្ឋស្ថិតក្រោមការត្រួតពិនិត្យ រដ្ឋផ្តល់អនុសាសន៍រដ្ឋ ក្រុមតំបន់ អង្គការ ការឆ្លើយតបវដ្តការត្រួតពិនិត្យជាសាកលតាមកាលកំណត់ បញ្ហា និងប្រភេទសកម្មភាពផ្សេងទៀត។ អាចចូលមើលបានក្នុងគេហទំព័រ https://upr-info-database.uwazi.io (ចូលមើល០១/កញ្ញា/២០)

[57] វិធីសាស្ត្រ S.M.A.R.T បានអនុវត្តទៅលើការត្រួតពិនិត្យជាសាកលតាមកាលកំណត់ ដោយបន្ថែមលក្ខណៈវិនិច្ឆ័យមានប្រយោជន៍សម្រាប់ការសរសេរអនុសាសន៍ដែលជាក់លាក់ និងតម្រង់ទិសដៅអនុវត្តសកម្មភាពអនុសាសន៍ (Precise and action-oriented recommendation) ) ដែលរដ្ឋនានាត្រូវបានលើកទឹកចិត្ត ឲ្យគាំទ្រដល់។ ទាំងនេះមានអក្សរកាត់មកពីពាក្យ៖

- S=Specific ជាក់លាក់ គឺត្រូវកំណត់ឲ្យល្អនូវសកម្មភាពអនុវត្តឲ្យទាក់ទងនឹងសិទ្ធិ ឬ ការរំលោភជាក់លាក់
- M=Measurable ៖ ដែលធ្វើការវាស់ស្ទង់ ពោលគឺតើអនុសាសន៍អាចត្រូវបានត្រួតពិនិត្យ និងអនុវត្តបានដែរឬទេ? តើរដ្ឋយល់ពីអនុសាសន៍ទាំងអស់នោះបានកម្រិតណា?

ធ្វើការពិគ្រោះយោបល់រៀងរាល់ ៦ (ប្រាំមួយ) ខែម្តងដោយមានវិសាលភាពទូលំទូលាយ និងចម្រុះនៃអង្គការសង្គមស៊ីវិល ដើម្បីអនុញ្ញាតឱ្យមានកន្លែងសម្រាប់ការណែនាំរបស់សង្គមស៊ីវិលលើការអនុវត្តអនុសាសន៍ដោយរួមមានការធ្វើបច្ចុប្បន្នភាពលើវឌ្ឍនភាព និងដោះស្រាយកង្វល់របស់ពួកគេ។ សម្រាប់ការធានាថាអង្គការសង្គមស៊ីវិលត្រូវបាននាំយកមកធ្វើជាដៃគូអនុវត្តសំខាន់ ហើយព័ត៌មាន និងកង្វល់របស់ពួកគេត្រូវបានបញ្ចូលក្នុងការរាយការណ៍រដ្ឋាភិបាលនិង / ឬ យន្តការជាតិសម្រាប់ការធ្វើរបាយការណ៍ និងតាមដាន គួរតែចាប់ផ្តើមពិគ្រោះយោបល់។

អភិវឌ្ឍន៍ផែនការសកម្មភាពជាតិស្តីពីសិទ្ធិមនុស្សដើម្បីកំណត់ក្រសួងដែលទទួលខុសត្រូវក្នុងការអនុវត្ត (Develop a National Human Right Action Plan) និងបង្កើតសូចនាករ SMART ដើម្បីវាស់វែងការអនុវត្ត។ ផែនការរួមទាំងអនុសាសន៍ដែលទទួលបានពីយន្តការសិទ្ធិមនុស្សក្នុងតំបន់ និងអន្តរជាតិ រួមទាំងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Develop Goal (SDGs)) គួរតែត្រូវបានបង្កើតឡើង ដោយរដ្ឋាភិបាល និង យន្តការជាតិសម្រាប់ការធ្វើរបាយការណ៍ (NMRF) ដោយសហការជាមួយស្ថាប័នសិទ្ធិមនុស្សជាតិ (NHRI) និងសង្គមស៊ីវិល។

#### ៤.១.២ រដ្ឋផ្តល់អនុសាសន៍ ( Recommending State )

សកម្មភាពរបស់រដ្ឋដែលផ្តល់អនុសាសន៍ក្នុងការចូលរួមជាមួយយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់មានចំណួន០២ (ពីរ)កន្លែងធំៗ ពោលគឺ នៅទីក្រុងហ្សឺណែវ និងនៅកម្រិតថ្នាក់ជាតិ។

---

(បន្តមកពី Footnote 57)

- A=Achievable ៖ ដែលជោគជ័យ សម្តៅដល់ភាពជោគជ័យត្រូវបានកំណត់ដោយសមត្ថភាពរបស់រដ្ឋដែលកំពុងត្រូវបានពិនិត្យអនុវត្តតាមអនុសាសន៍ និងយោងទៅលើសមត្ថភាពជាសម្ភារៈ មិនមែនប្រើឆន្ទៈនយោបាយទេ
- R=Relevant ៖ ដែលជាប់ទាក់ទង ពោលគឺ តើអនុសាសន៍ទាំងនោះជាប់ទាក់ទងទៅនឹងស្ថានភាពក្នុងប្រទេស និងភ្ជាប់ទៅនឹងការធ្វើឲ្យប្រសើឡើងនូវស្ថានភាពសិទ្ធិមនុស្សដែលឬទេ?
- T=Time-Bond ៖ ពេលវេលាកំណត់ មានន័យថាក្របខណ្ឌពេលវេលាសម្រាប់ការអនុវត្តអនុសាសន៍សម្រាប់ពេលខាងមុខ ឬក៏ពេលឆាប់ៗនេះ។

បកប្រែដកស្រង់ចេញពីសៀវភៅនៃគេហទំព័រដែលមានឈ្មោះ https://www.upr-info.org/sites/default/files/general-document/pdf/upr_info_cso_compendium_en.pdf (ចូលមើលថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០) ស្តីអំពី The Civil Society Compendium A comprehensive guide for Civil Society Organizations engaging in the Universal Periodic Review ទំព័រទី២១

#### ៤.១.២.១ នៅទីក្រុងហ្សឺណែវ

រដ្ឋផ្តល់អនុសាសន៍ចូលរួមផ្តល់អនុសាសន៍ច្បាស់លាស់ និងផ្តោតលើសកម្មភាពដោយប្រើវិធីសាស្រ្ត SMART ដែលបានចងភ្ជាប់ នៅពេលណាដែលអាចធ្វើទៅបានចំពោះការគំនិតផ្តួចផ្តើមរបស់ទ្វេភាគីដែលកំពុងតែដំណើរការទៅមុខ។ រដ្ឋផ្តល់អនុសាសន៍ដាក់ជូនសំណួរជាមុនស្តីពីវឌ្ឍនភាពនៃការអនុវត្តទៅរដ្ឋស្ថិតក្រោមការត្រួតពិនិត្យ។ ការណ៍ធ្វើដូចនេះ ដូចជាវាបង្កើនលទ្ធភាពរបស់រដ្ឋក្រោមការពិនិត្យក្នុងការជួយគាំទ្រការអភិវឌ្ឍចាប់តាំងពីការត្រួតពិនិត្យនៅវគ្គមុន។

យោងតាមអនុសាសន៍ដែលបានធ្វើការពីវគ្គមុន ប្រសិនបើមិនមានសកម្មភាពណាមួយបានកើតឡើងដោយការកែច្នៃអនុសាសន៍នោះទេ នោះត្រូវបន្ថែមពាក្យថា "ដូចដែលបានណែនាំពីមុន (as previously recommendation) "។

ការប្រើប្រាស់ក្រុមប្រឹក្សាសិទ្ធិមនុស្សតាមរយៈរបៀបវារៈទី៦ (ការត្រួតពិនិត្យជាសកលតាមកាលកំណត់) ពេលមានកិច្ចពិភាក្សាទូទៅសម្រាប់សួរអំពីជំហានដែលត្រូវអនុវត្តដើម្បីអនុវត្តអនុសាសន៍ ពីព្រោះទីនោះផ្តល់នូវវេទិកាសម្រាប់តាមដាន។ ការប្រើដំណាក់កាលអនុម័តដើម្បីទទួលបានចម្លើយច្បាស់លាស់ចំពោះអនុសាសន៍ព័ត៌មានលម្អិតស្តីពីផែនការអនុវត្ត និងដើម្បីផ្តល់ជំនួយបច្ចេកទេស និងកិច្ចសហប្រតិបត្តិការភាគខាងត្បូង-ខាងត្បូង (South-South Cooperation)។[58]

#### ៤.១.២.២ នៅកម្រិតថ្នាក់ជាតិ

រដ្ឋផ្តល់អនុសាសន៍បន្តការពិភាក្សាទ្វេភាគីជាមួយការត្រួតពិនិត្យរដ្ឋនៅថ្នាក់ជាតិ ក្នុងការធានាបាននូវការអនុវត្តអនុសាសន៍ប្រកបដោយប្រសិទ្ធភាពរាប់បញ្ចូល និងប្រកបដោយនិរន្តរភាព។ បន្ថែមលើនេះ រដ្ឋផ្តល់អនុសាសន៍គាំទ្រផ្នែកសង្គមស៊ីវិលផ្នែកហិរញ្ញវត្ថុដើម្បីធានាថា ពួកគេមានមធ្យោបាយសម្រាប់ធ្វើសកម្មភាពចូលរួមជាមួយការត្រួតពិនិត្យជាសកលតាមកាលកំណត់របស់ពួកគេ ព្រមទាំងគាំទ្រសង្គមស៊ីវិលផ្នែកនយោបាយ

[58] កិច្ចសហប្រតិបត្តិការភាគខាងត្បូង-ខាងត្បូង "South-South cooperation (SSC)" គឺសម្តៅទៅលើទៅលើកិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅតំបន់ Global South ដែលធ្វើការជាមួយគ្នាដើម្បីរកដំណោះស្រាយចំពោះបញ្ហាប្រឈមនៃការអភិវឌ្ឍន៍រួម។ កិច្ចសហប្រតិបត្តិការនេះ ជាឧបករណ៍ប្រើប្រាស់ដោយរដ្ឋ អង្គការអន្តរជាតិអ្នកសិក្សាសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីសហការចែករំលែកចំណេះដឹង ជំនាញ និងគំនិតផ្តួចផ្តើមសម្រាប់ជោគជ័យក្នុងវិស័យជាក់លាក់ ដូចជា ការអភិវឌ្ឍន៍កសិកម្ម សិទ្ធិមនុស្ស នគរូបនីយកម្ម សុខភាព ការប្រែប្រួលអាកាសធាតុជាអាទិ៍។

ដើម្បីធានាថា ពួកគេមានសេរីភាពក្នុងការធ្វើការនៅក្នុងយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ ហើយត្រូវបានពិគ្រោះយោបល់ជាទៀងទាត់ពីរដ្ឋាភិបាល។

## ៤.២. អង្គការសង្គមស៊ីវិល

អង្គការសង្គមស៊ីវិលធ្វើការក្នុងក្រុមចម្រុះដើម្បីបង្កើនឥទ្ធិពលចំណេះដឹង និងធនធាន។ ការនិយាយដោយមានសម្លេងឯកសណ្ឋានតែមួយ បង្កើនលទ្ធភាពជាដៃគូជាមួយរដ្ឋាភិបាល។ អង្គការសង្គមស៊ីវិលភ្ជាប់ទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធទាំងអស់របស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ រួមមានរដ្ឋជាសមាជិកសភា ស្ថាប័នសិទ្ធិមនុស្សជាតិ (NHRI) ប្រព័ន្ធផ្សព្វផ្សាយ និងទីភ្នាក់ងារអង្គការសហប្រជាជាតិ។ យោងទៅលើព័ត៌មានដំបូងក្នុងការអន្តរាគមន៍ការសរសេរជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ទាំងអស់ទៅកាន់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដែលភស្តុតាងបែបនេះបង្ហាញពីការចូលរួមវិភាគទានដ៏មានតម្លៃរបស់អង្គការសង្គមស៊ីវិលចំពោះយន្តការ និងជាមធ្យោបាយមួយក្នុងការសន្ទនាជាមួយគ្នាជាមួយភាគីពាក់ព័ន្ធក្នុងពេលត្រួតពិនិត្យជាសកលតាមកាលកំណត់។ មិនតែប៉ុណ្ណោះ អង្គការសង្គមស៊ីវិលរៀបចំឯកសារយុទ្ធសាស្ត្រ SMART នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដែលបញ្ជាក់ពីការរំពឹងទុករបស់រដ្ឋ និងរបៀបដែលអង្គការសង្គមស៊ីវិលអាចគាំទ្រដល់រដ្ឋាភិបាលក្នុងដំណើរការអនុវត្តន៍។ វិធីនេះអង្គការសង្គមស៊ីវិលអាចដើរហួសពីតួនាទីឃ្លាំមើលរបស់ខ្លួនក្នុងការប្រើប្រាស់ជំនាញរបស់ខ្លួនជាដៃគូអនុវត្ត។ លើសពីនេះសង្គមស៊ីវិលចូលរួមលើកកម្ពស់ការយល់ដឹងអំពីអនុសាសន៍របស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលនៅថ្នាក់ជាតិដើម្បីបិទគំលាតព័ត៌មានរវាងដំណាក់កាលហ្សឺណែវនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងដំណាក់កាលអនុវត្តក្នុងស្រុក។ ម្យ៉ាងទៀត អង្គការសង្គមស៊ីវិលបញ្ជូនរបាយការណ៍ពាក់កណ្ដាលវដ្ដជារួម និងជាលក្ខណៈបុគ្គលដើម្បីធានាថា សំឡេង និងកង្វល់របស់សង្គមស៊ីវិលត្រូវបាននាំយកមកយកចិត្តទុកដាក់ជាអន្តរជាតិ។ អង្គការសង្គមស៊ីវិលក៏ចូលរួមបកប្រែអនុសាសន៍ទៅជាភាសាក្នុងរបស់ប្រទេសមួយ រួមទាំងរៀបចំវគ្គមុនសម័យប្រជុំនៅក្នុងប្រទេស ២ ខែមុនការត្រួតពិនិត្យនៅហ្សឺណែវ។

## ៤.៣. ស្ថាប័នសិទ្ធិមនុស្សជាតិ

ស្ថាប័នសិទ្ធិមនុស្សជាតិ (NHRI) គឺជាស្ថាប័នស្វយ័ត និងឯករាជ្យ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ និងមានភារកិច្ចលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ ស្ថាប័ននេះគឺជាស្ថាប័នដែលបំពេញបន្ថែមសកម្មភាពរបស់សង្គមស៊ីវិលស្ថាប័នស្រាវជ្រាវសិទ្ធិមនុស្ស និងរដ្ឋាភិបាល។ ស្ថាប័ននេះ ស្វែងរកការចូលរួមចំណែកក្នុងការការពារការអនុវត្តសិទ្ធិមនុស្សដោយការត្រួតពិនិត្យ និងវាយតម្លៃនៅពេលចាំបាច់ចាំបាច់ផងដែរ នូវសកម្មភាព

នានាដែលបានលើកឡើងខាងលើដោយជួយពួកគេក្នុងការអនុវត្តសិទ្ធិមនុស្សអោយកាន់តែប្រសើរឡើងនិងធ្វើឱ្យសង្គមកាន់តែមានការយល់ដឹង និងមានភាពងាយស្រួលចំពោះសិទ្ធិមនុស្ស។ ស្ថាប័នសិទ្ធិមនុស្សជាតិ ក៏ជាតួអង្គមួយយ៉ាងសំខាន់ដោយហេតុថាមានសកម្មភាពដូចតទៅ ៖

- ចូលរួមក្នុងពេល ឬ នៅពេលមានការតស៊ូមតិចាំបាច់សម្រាប់ការពិគ្រោះយោបល់ថ្នាក់ជាតិមុនពេល ក្នុងអំឡុងពេល និងក្រោយពេលការត្រួតពិនិត្យជាសកលតាមកាលកំណត់ ព្រមទាំងលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធជាច្រើនទូទាំងមួយរដ្ឋ ចូលរួមជាអ្នករៀបចំរួមគ្នាដើម្បីធានានូវការអញ្ជើញរបស់អង្គការសង្គមស៊ីវិលក្នុងការពិគ្រោះយោបល់នៅទីតាំងផ្សេងៗ ក្រៅពីរដ្ឋធានី/រាជធានី ហើយការព្រួយបារម្ភរបស់អង្គការសង្គមស៊ីវិលត្រូវបានគេយកមកពិចារណាយ៉ាងទូលំទូលាយនៅក្នុងរបាយការណ៍របស់រដ្ឋាភិបាល
- លើកកម្ពស់ការយល់ដឹងអំពីអនុសាសន៍របស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលនៅថ្នាក់ជាតិដើម្បីបិទគំលាតព័ត៌មានរវាងដំណាក់កាលហ្សឺណែ វនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់និងនិងដំណាក់កាលអនុវត្តក្នុងស្រុក។
- គាំទ្រដល់ដំណើរការ ឬ ការបង្កើតឱ្យមានប្រសិទ្ធិភាពនៃយន្តការជាតិសម្រាប់ធ្វើរបាយការណ៍ និងតាមដាន។ តាមដាន និងរាយការណ៍ស្តីពីការអនុវត្តការត្រួតពិនិត្យជាសកលតាមកាលកំណត់នោះ គឺត្រូវធ្វើតាមរយៈការបញ្ជូនរបាយការណ៍ពាក់កណ្តាលវដ្តនីមួយៗ ក្នុងការធានាឱ្យមានការវាយតម្លៃឯករាជ្យដោយផ្អែកលើភស្តុតាងជាក់ស្តែង នៃការអនុវត្តអនុសាសន៍របស់ការត្រួតពិនិត្យជាសកលតាមកាលកំណត់។

## ៤.៤. សមាជិកសភា

សមាជិកសភាចូលរួម ឬ បង្កើតប្រសិនបើមិនមានគណៈកម្មាធិការសិទ្ធិមនុស្សនៃគណបក្សទាំងអស់ដើម្បីលើកកម្ពស់ការយល់ដឹងទាំងនៅក្នុងសភា និងជាមួយមណ្ឌលបោះឆ្នោតអំពីកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋ និងវឌ្ឍនភាពនៃការសំរេចបាននូវអនុសាសន៍ការត្រួតពិនិត្យជាសកលតាមកាលកំណត់។ សមាជិកសភាស្នើសុំព័ត៌មានថ្មីៗស្តីពីការអនុវត្តអនុសាសន៍ការត្រួតពិនិត្យជាសកលតាមកាលកំណត់ ក្នុងអំឡុងពេលជជែកដេញដោលដោយសភាក្នុងការរក្សាការត្រួតពិនិត្យជាសកលតាមកាលកំណត់លើរបៀបវារៈរបស់រដ្ឋាភិបាលនៅទូទាំង និងរវាងវដ្តនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ព្រមទាំងចូលរួមនៅក្នុងដំណើរការរៀបចំរបាយការណ៍ជាតិ និងធានានូវការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល។ លើសពីនេះ សមាជិកសភាទទូចឱ្យមានការដាក់បញ្ចូលសមាជិកសភានៅក្នុងគណៈប្រតិភូរដ្ឋ ដែលចូលរួមក្នុងដំណាក់កាលប្រជុំនៅទីក្រុងហ្សឺណែវនៃការត្រួត

ពិនិត្យជាសកលតាមកាលកំណត់ ក៏ដូចជា ដំណើរការនៃការសម្រេចចិត្តលើស្ថានភាពនៃអនុសាសន៍ដែលទទួលបាន។ សមាជិកសភាក៏ចូលរួមក្នុងការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលជាតិ និងអន្តរជាតិសម្រាប់ដោះស្រាយកង្វល់សិទ្ធិមនុស្សរបស់ពួកគេ។ មិនតែប៉ុណ្ណោះ ចូលរួមក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សជាសកលតាមរយៈអង្គការនានាផងដែរ ដូចជា សហភាពអន្តរសភា និងសមាជិកសភាសម្រាប់សកម្មភាពសកល។

## ៤.៥. ទីភ្នាក់ងារអង្គការសហប្រជាជាតិ ( UN Agencies )

ក្នុងដំណើរការនៃយន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ ទីភ្នាក់ងារអង្គការសហប្រជាជាតិបានចូលរួម ដោយបានបញ្ចូលអនុសាសន៍ការត្រួតពិនិត្យជាសកលតាមកាលកំណត់ ទៅក្នុងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDAF) និងកម្មវិធីប្រទេសទូទៅដើម្បីធានាថាការអនុវត្តត្រូវបានបញ្ជ្រាបនៅទូទាំងក្រុមប្រទេសរបស់អង្គការសហប្រជាជាតិទាំងមូល។ ចូលរួមវិភាគទានដល់ការបញ្ចប់គម្លាតរវាងរបៀបវារៈឆ្នាំ២០៣០ និងគោលលទ្ធិសិទ្ធិមនុស្សដោយធានាថា វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សត្រូវបានប្រើប្រាស់ក្នុងគ្រប់សកម្មភាពអភិវឌ្ឍន៍ ព្រមទាំងគាំទ្រដល់រដ្ឋាភិបាលក្នុងការបង្កើត យន្តការណ៍សម្រាប់ការធ្វើរបាយការណ៍ និងតាមដាន និងផែនការសកម្មភាពជាតិស្តីពីសិទ្ធិមនុស្សយោងតាមលក្ខណៈវិនិច្ឆ័យ។ មួយវិញទៀត ធានាថាសង្គមស៊ីវិលត្រូវបានពិគ្រោះយោបល់ជាញឹកញាប់ការព្រួយបារម្ភរបស់ពួកគេ ដែលបានកើតឡើង ហើយពួកគេមានសេរីភាពក្នុងការអនុវត្តសកម្មភាពត្រួតពិនិត្យ និងអនុវត្តដោយគ្មានការភ័យខ្លាចនៃការសងសឹកតាមរយៈការផ្តល់ការគាំទ្រផ្នែកនយោបាយ និងហិរញ្ញវត្ថុដល់អង្គការសង្គមស៊ីវិល និងសម្ព័ន្ធសង្គមស៊ីវិល។

## ៤.៦. អ្នកសារព័ត៌មាន

ការចូលរួមរបស់អ្នកសារព័ត៌មានក្នុងការបង្កើតបណ្តាញសិទ្ធិមនុស្សជាតិសម្រាប់អ្នកសារព័ត៌មាន ដើម្បីពង្រីកវិសាលភាពចំណេះដឹង និងធនធាននៃការរាយការណ៍អំពីសិទ្ធិមនុស្សឱ្យបានច្រើនបំផុត។ ការធ្វើការងារនៅគ្រប់វេទិការបស់អ្នកសារព័ត៌មាន ដោយទាំងនោះរួមមានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចជា ទូរទស្សន៍ វិទ្យុ សាលប្រជុំសាលាក្រុង និងប្រព័ន្ធផ្សព្វផ្សាយសង្គម ជាអាទិ៍។ ការផ្តល់ព័ត៌មានឱ្យបានទាន់ពេលវេលាដល់សាធារណជនអំពី ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ដែលបានធ្វើឡើងក្នុងដំណាក់កាលនៅទីក្រុងហ្សឺណែវនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដែលត្រូវបានផ្សាយផ្ទាល់តាមអ៊ិនធើណេត។ ចូលរួមតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តក៏ដូចជាការដាក់រួមបញ្ចូលប្រកបដោយអត្ថន័យនៃសង្គមស៊ីវិលនៅក្នុងដំណើរការត្រួតពិនិត្យជាសកលតាមកាលកំណត់។ ការធ្វើរបាយការណ៍ទាំងរឿងជោគជ័យ និងការខ្វះខាតរបស់អ្នកពាក់ព័ន្ធ

ការត្រួតពិនិត្យជាសកលតាមកាលកំណត់ទាំងអស់។ មិនតែប៉ុណ្ណោះ ចូលរួមទទួលខុសត្រូវចំពោះរដ្ឋាភិបាលនូវការអនុវត្តតាមកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន និងចូលរួមជាមួយសម្ព័ន្ធអង្គការសង្គមស៊ីវិលដើម្បីគាំទ្រដល់ការអនុវត្តអនុសាសន៍ស្តីពីសេរីភាពសារព័ត៌មាន។

### ៤.៧. អ្នកសិក្សាស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវចូលរួមចំណែកក្នុងការធ្វើការស្រាវជ្រាវលើការកែលំអសិទ្ធិមនុស្ស បណ្ដាលមកពីអនុសាសន៍ការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដែលបានអនុវត្តដើម្បីបង្ហាញពីភាពជោគជ័យនៃយន្តការនិងកំណត់កង្វះខាត។ ធានាថាការរកឃើញត្រូវបានចែករំលែកជាមួយមធ្យោបាយផ្សេងៗគ្នា ដើម្បីបង្កើនចំណេះដឹងជាសាធារណៈអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់។ លើសពីនេះ បង្កើតក្រុមសិទ្ធិមនុស្សដែលធ្វើការវិភាគលើការត្រួតពិនិត្យជាសកលតាមកាលកំណត់ ដែលត្រូវបានសិក្សាដោយអ្នកមានចំណេះដឹងទូលំទូលាយ។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើយើងឃើញថា ក្រោយពីដួលរលំគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (CHR) ដោយជំនួសមកវិញនូវក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (HRC) មក ជាហេតុធ្វើឲ្យមានការបង្កើតនូវយន្តការសិទ្ធិមនុស្សថ្មីតែមួយគត់ ដែលមិនចម្លងពីគេ នោះគឺការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR) មកដល់ពេលនេះ យន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ត្រូវបានធ្វើចំនួន ០៣ វដ្តមកហើយ។ តាំងពីការបង្កើតយន្តការនេះឡើងមក លើលោកនេះគ្មានពាក្យថា ភាពសមាជិកមិនអាចត្រូវបានប្រើជាខែលប្រឆាំងនឹងការត្រួតពិនិត្យបញ្ជាក់អំពីស្ថានភាពសិទ្ធិមនុស្សនោះទេ ពីព្រោះដំណើរការនៃការត្រួតពិនិត្យគឺត្រួតពិនិត្យពីគ្នាម្នាក់ម្តង ម្តងរដ្ឋនោះដើរតួជារដ្ឋស្ថិតក្រោមការត្រួតពិនិត្យ ម្តងរដ្ឋនោះ ដើរតួជារដ្ឋផ្តល់ជាអនុសាសន៍ អាស្រ័យទៅតាមកាលបរិច្ឆេទសម្រាប់ការត្រួតពិនិត្យ ហើយមិនមែនមានតែតួអង្គតែពីរនេះនោះទេ ក្នុងនោះ មានតួអង្គផ្សេងទៀតផងដែរ ដូចជាអង្គការសង្គមស៊ីវិល ស្ថាប័នសិទ្ធិមនុស្សជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ អ្នកសារព័ត៌មាន អ្នកសិក្សាស្រាវជ្រាវជាដើម។ ក្នុងសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥/១ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ "បង្កើនស្ថាប័នរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស" បានកំណត់អំពីគោលការណ៍ និងគោលដៅ នៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ សម្តៅលើកកម្ពស់សិទ្ធិមនុស្សដោយប្រើមធ្យោបាយត្រួតពិនិត្យ ដូចជាពឹងពាក់អាស្រ័យគ្នាទៅវិញទៅ មិនអាចបំបែកចេញពីគ្នាបាន ធានាឲ្យនៅលើសកលលោកទាំងមូលមានភាពស្មើគ្នា មានន័យថា រដ្ឋដែលរំលោភបំពានសិទ្ធិមនុស្សមិនត្រូវបានមើលរំលងនោះទេទោះបីជាប្រព្រឹត្តដោយប្រទេសមហាអំណាចក៏ដោយ។ ម្យ៉ាងទៀត គ្មានសេចក្តីលំអៀងចំពោះកាតព្វកិច្ចសិទ្ធមនុស្ស ដែលមាននៅក្នុងធាតុផ្សំ ដែលត្រូវបានផ្តល់ជាមូលដ្ឋាននៃការត្រួតពិនិត្យ ដែលនឹងយកមកគិតពិចារណាក្នុងកម្រិតនៃការអភិវឌ្ឍ និងភាពពិសេសនៃប្រទេសនោះទេ។ ពង្រឹងសមត្ថភាពរបស់រដ្ឋ និងផ្តល់ជំនួយបច្ចេកទេសក្នុងការពិគ្រោះយោបល់ជាមួយរដ្ឋពាក់ព័ន្ធ ដោយមានការយល់ព្រមពីរដ្ឋនោះទេ។

ការត្រួតពិនិត្យជាសកលតាមកាលកំណត់ត្រូវបានគ្របដណ្តប់ដោយស្ថាប័នជំនាញចំនួន ០៣ គឺ **ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ** និងអង្គការមិនមែនរដ្ឋាភិបាលឈ្មោះ **អង្គការព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់** (UPR Info)។ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានដាក់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ នៅក្នុងរបៀបវារៈទី៦ នៅសម័យប្រជុំពេញអង្គរបស់ខ្លួន ដើម្បីកំណត់ថា អនុសាសន៍ដែលត្រូវបានលើឡើងទាំងនោះ រដ្ឋស្ថិតក្រោមការត្រួតពិនិត្យទទួលយក ឬ គ្រាន់តែកត់សម្គាល់។ ក្នុងនោះអមទៅដោយការពិភាក្សាជាមួយយន្តការជំនាញនានារបស់ខ្លួន។ ចំពោះការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (OHCHR) ជាលេខាធិការដ្ឋាន នៃអង្គការសហប្រជាជាតិផង និងជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សផង។

ក្នុងនោះ ការិយាល័យនេះចូលរួមឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សប្រចាំតំបន់ដែលខ្លួនតាំងនៅ ផ្តល់ជំនួយបច្ចេកទេស ព្រមទាំងជួយរៀបចំឯកសារសម្រាប់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ សម្រាប់សម័យប្រជុំផងដែរ។ ចំណែកឯ អង្គភាពព័ត៌មានអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ជួយធ្វើយ៉ាងណាឲ្យសម្លេងនៃការពារសិទ្ធិមនុស្សត្រូវបានឮនៅឯសម័យប្រជុំពេញអង្គតាមរយៈការចូលរួមពីភាគីពាក់ព័ន្ធ ពិសេសពីថ្នាក់ក្រោមជាតិ ព្រមទាំងជួយតម្រង់ទិសមុនពេលសម័ប្រជុំពេញអង្គមែនទែនរបស់ការត្រួតពិនិត្យ។

ក្នុងដំណើរការត្រួតពិនិត្យជាសកលតាមកាលកំណត់ត្រូវបានចែកជា វគ្គមុនសម័យប្រជុំ (Pre-session) សម័យប្រជុំ និងការតាមដានកាអនុវត្តអនុសាសន៍ (Implementation)។ វគ្គមុនសម័យប្រជុំ ជាទូទៅគេធ្វើឡើងមុនមួយខែនៃកាលបរិច្ឆេទ នៃសម័យប្រជុំពេញអង្គរបស់ការត្រួតពិនិត្យជាសកល ក្នុងនោះភាគីពាក់ព័ន្ធអាចចូលរួមជាក្រុមជាវាគ្មិននៅក្នុងការពិភាក្សាជាក្រុម (Panel Discussion) និងបើមិនត្រូវបានគេជ្រើសរើសទេអាចដាក់ពាក្យសុំធ្វើជាទស្សនិកជនបាន។ វគ្គបណ្តុះបណ្តាលនេះអនុញ្ញាតឱ្យអ្នកចូលរួមត្រូវបានដឹកនាំតាមរយៈប្រធានបទការត្រួតពិនិត្យជាសកលតាមកាលកំណត់យ៉ាងពេញលេញ ក្នុងការរៀបចំវគ្គមុនសម័យប្រជុំ និងយុទ្ធសាស្ត្រតស៊ូមតិទូលំទូលាយ ដែលអង្គការសង្គមស៊ីវិលគួរតែទទួលយកនៅដំណាក់កាលផ្សេងៗគ្នានៃដំណើរការ។ ការចូលរួម គឺបើកចំហសម្រាប់ទាំងសង្គមស៊ីវិលនិង NHRI រួមទាំងវាគ្មិន និងទស្សនិកជន។ ចំពោះសម័យប្រជុំវិញ ចែកជាបីផ្នែក គឺទី១៖ ដំបូងជាដំណាក់ការរៀបចំឯកសារ និងបញ្ជូនឯកសារទាំងអស់នោះទៅកាន់សម័យប្រជុំ។ ទី២ បន្ទាប់មកក្រុមការងារកាត្រួតពិនិត្យជាសកលតាមកាលកំណត់ពិនិត្យលើរបាយការណ៍ទាំងនោះដោយផ្ទៀងផ្ទាត់ទៅនឹងបទដ្ឋានសិទ្ធិមនុស្ស រួចធ្វើរបាយការណ៍លទ្ធផល បញ្ជូនទៅកាន់សម័យប្រជុំសមញ្ញរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដើម្បីសម្រេចជាមួយរដ្ឋស្ថិតក្រោមការត្រួតពិនិត្យ សមជិកទាំងអស់។ ទី៣ ក្រោយពីទទួលយកអនុសាសន៍រដ្ឋស្ថិតក្រោមការត្រួតពិនិត្យមានតួនាទីចម្បងគឺអនុវត្តអនុសាសន៍ទាំងនោះ ដោយមានការចូលរួមឃ្លាំមើលពីភាគីពាក់ព័ន្ធទាំងអស់។ ក្នុងដំណាក់កាលនេះ ដោយសារគំលាតនៃរយៈពេលរបស់វដ្តមានការឆ្ងាយគ្នាពេក គេមានយន្តការតាមដានការអនុវត្តមួយទៀត គឺរបាយការពាក់កណ្តាលវដ្ត។

# អនុសាសន៍

ក្រោយពីបានសិក្សា និងស្រាវជ្រាវអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់រួចមក យើងអាចទទួលបាននូវមតិយោបល់សំខាន់ៗ សម្រាប់ជាប្រយោជន៍ដូចតទៅ ៖

- វាជាការល្អណាស់ ដែលរដ្ឋទាំងអស់មានបំណងចង់អភិវឌ្ឍន៍ស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសខ្លួន និងប្រទេសដទៃ តាមរយៈយន្តការការត្រួតពិនិត្យជាសកលតាមកាលកំណត់ដោយធ្វើតាមការអនុវត្តល្អដែលមានរៀបរាប់ក្នុងសារណានេះ ប៉ុន្តែជាក្តីបារម្ភនោះ គឺត្រង់ថា រដ្ឋមួយចំនួនបានតែទទួលយកអនុសាសន៍តែមិនគិតធ្វើវាឲ្យខ្លាចជាប្រយោជន៍សម្រាប់ស្ថានភាពសិទ្ធិមនុស្សនោះទេ
- ចំពោះរដ្ឋស្ថិតក្រោមការត្រួតពិនិត្យ នៅពេលធ្វើរបាយការណ៍ជាតិរបស់ខ្លួន ត្រូវរៀបរាប់ឲ្យបានច្បាស់លាស់ និងពិតប្រាកដនូវស្ថានភាពសិទ្ធិមនុស្សដែលកំពុងកើតមានក្នុងប្រទេសរបស់ខ្លួន ដើម្បីជាផលប្រយោជន៍ពេលរដ្ឋផ្តល់អនុសាសន៍ដើម្បីឲ្យចំគោលដៅ ចំចំណុច
- រដ្ឋក្រោមការត្រួតពិនិត្យ មិនត្រូវរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិផ្តល់ជាអនុសាសន៍ និងការតាមដានការអនុវត្តអនុសាសន៍ឡើយ ពោលគឺត្រូវបង្កលក្ខណៈងាយស្រួលដល់អ្នកដែលមានតួនាទីត្រួតពិនិត្យទាំងនោះ
- ដូចគ្នានេះដែរ ក្រុមភាគីពាក់ព័ន្ធដែលធ្វើរបាយការណ៍សម្រាប់ការត្រួតពិនិត្យជាសកល ក៏ត្រូវតែច្បាស់លាស់ ប្រាកដប្រជា និងសម្តែងនូវភាពពិតប្រាកដទាំងអស់ផងដែរ គ្មានទំនោរទៅកាន់ផលប្រយោជន៍បុគ្គល ឬ ស្ថាប័នរបស់ខ្លួន
- ចំណែកឯរដ្ឋផ្តល់អនុសាសន៍វិញ ត្រូវផ្តល់អនុសាសន៍ និងតាមដានការអនុវត្តអនុសាសន៍ទាំងនោះ ដោយគ្មានចរិតជាលក្ខណៈនៃការធ្វើនយោបាយ ដើម្បីគាបសង្កត់រដ្ឋក្រោមការត្រួតពិនិត្យក្នុងគោលបំណងដើម្បីទទួលបាននូវផលប្រយោជន៍អ្វីមួយ
- មិនត្រូវមានគំនិតសងសឹងនឹងការផ្តល់អនុសាសន៍ ការតាមដានការអនុវត្តអនុសាសន៍ ឬ ការដាក់គំនាបផ្នែកសេដ្ឋកិច្ច ឬ ផ្នែកផ្សេងៗដោយហេតុនៃការមិនអនុវត្តអនុសាសន៍
- បង្កើតមូលនិធិ ឬ វិធានការណ៍ផ្សេង ដើម្បីជាជំនួយជួយដល់រដ្ឋស្ថិតក្រោមការត្រួតពិនិត្យ ដើម្បីអាចមានលទ្ធភាពសម្តៅអនុវត្តអនុសាសន៍ឲ្យទទួលបាននូចភាពជោគជ័យ មិនមែនអោបដៃឈរមើល ឬ ទិទៀន ឬ បណ្តោយឲ្យការអនុវត្តអនុសាសន៍មិនទទួលបានជោគជ័យ រួចនឹងអាលដាក់វិធានការដោយហេតុមិនអនុវត្តអនុសាសន៍ដែលបានផ្តល់ឲ្យនោះទេ

- ស្ថាប័នដែលពាក់ព័ន្ធទាំងអស់មិនត្រូវរើសអើង ឬ ប្រកាន់ភាពលំអៀងដោយហេតុនៃគំនិតផ្ទាល់ខ្លួន ឬ គំនិតនយោបាយនោះទេ ទាំងការចូលរួមក្នុងដំណើរការនៃកិច្ចប្រជុំនានាពាក់ព័ន្ធនឹងការត្រួតពិនិត្យជាសកលតាមការកំណត់ប្រព្រឹត្តទៅ និងទាំងការដាក់វិធានការជាទណ្ឌកម្មនៃការមិនអនុវត្តអនុសាសន៍
- រដ្ឋដែលផ្តល់អនុសាសន៍ត្រូវធ្វើយ៉ាងណាផ្តល់ជាអនុសាសន៍ជាគុណភាព មិនមែនមានតែបរិមាណ តែអត់ប្រយោជន៍នោះទេ

# ឯកសារយោង


- មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥/១ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ "បង្កើនស្ថាប័នរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (Institution-building of the United Nations Human Rights Council)") អាចស្វែងរកបានតាមរយៈ http://hrlibrary.umn.edu/iwraw/Inst-building-UN.pdf
- សៀវភៅដែលមានអ្នកនិពន្ធឈ្មោះ Maximilian Spohr "United Nations Human Rights Council Between Institution-Building Phase and Review of Status របស់ Max Plank Yearbook of United Nations Law ទំព័រទី ១៦៩-២១៨ (ហូឡង់ ឆ្នាំ២០១០)" អាចស្វែងរកបានតាមរយៈគេហទំព័រ https://www.mpil.de/files/pdf3/mpunyb_05_spohr_14.pdf
- Congressional Research Service សៀវភៅ The United Nations Human Rights Council: Background and Policy Issues Updated April 20 2020 ព្រមទាំងអាចស្វែងរកបានតាមរយៈ https://fas.org/sgp/crs/row/RL33608.pdf
- សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៥/១ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ "បង្កើនស្ថាប័នរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (Institution-building of the United Nations Human Rights Council)" http://hrlibrary.umn.edu/iwraw/Inst-building-UN.pdf
- សេចក្តីសម្រេចរបស់មហាសន្និបាតលេខA/RES/60/251 ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ "ស្តីពីការបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (Human Rights Council)" អាចស្វែងតាមរយៈ https://www2.ohchr.org/english/bodies/hrcouncil/docs/A.RES.60.251_En.pdf
- https://cambodia.ohchr.org/sites/default/files/book/UPR%20Chart_KH.pdf កម្រងអនុសាសន៍របស់យន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សចំពោះកម្ពុជា រៀបរៀងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ខែធ្នូ ឆ្នាំ២០១៤
- គេហទំព័រ http://hrlibrary.umn.edu/iwraw/Inst-building-UN.pdf អំពី សេចក្តីសម្រេចលេខ៥/១ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការកសាងស្ថាប័នក្រុមប្រឹក្សាសិទ្ធិមនុស្ស របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (Institution-building of the United Nations Human Rights Council

- គេហទំព័រ https://www.upr-info.org/sites/default/files/general-document/pdf/uprtoolkit.pdf របស់កម្មវិធីគំពារសិទ្ធិមនុស្ស (Human Right Project) មជ្ឈមណ្ឌលទីក្រុងយុត្តិធម៌ (at the Urban Justice Center) ឆ្នាំ២០១០
- គេហទំព័រ https://www.upr-info.org/sites/default/files/general-document/pdf/2016_pre-sessions_empowering_human_rights_voices_from_the_ground.pdf ស្ដីពី ការឲ្យអំណាចសំឡេងសិទ្ធិមនុស្សតាំងពីថ្នាក់ក្រោម "Empowering human rights voice from the ground" របស់ UPR Info
- https://www.eda.admin.ch/dam/eda/en/documents/publications/InternationaleOrganisationen/Uno/Human-rights-Council-practical-guide_en ស្ដីអំពី The Human Rights Council A practical guide
- https://www.upr-info.org/sites/default/files/general-document/pdf/upr_info_cso_compendium_en.pdf ស្ដីអំពី The Civil Society Compendium A comprehensive guide for Civil Society Organizations engaging in the Universal Periodic Review
- ចំណុចស្ដីពី **Troika** ពី https://www.upr-info.org/en/upr-process/what-is-it/qa-on-the-modalities-of-the-upr-process#5
- https://www.ohchr.org/EN/AboutUs/Pages/WhoWeAre.aspx ស្ដីពីយើងជាអ្នកណារបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ
- https://www.ohchr.org/en/hrbodies/hrc/pages/sessions.aspx
- https://www.ohchr.org/EN/HRBodies/UPR/Pages/CyclesUPR.aspx
- គេហទំព័រ https://cambodia.ohchr.org/kh/about-us/who-we-are "យើងជាអ្នកណា" របស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិប្រចាំកម្ពុជា
- គេហទំព័រ https://www.upr-info.org/sites/default/files/uprinfo-geneva_statutes_en.pdf របស់អង្គការព័ត៌មានការត្រួតពិនិត្យជាសកលតាមកាលកំណត់ "ស្ដីពីលក្ខន្តិកៈUPR info" ឆ្នាំ២០១៧
- https://www.upr-info.org/en/upr-process/pre-sessions/frequently-asked-questions ស្ដីពីសំណួរដែលមានគេសួរជាញឹកញាប់អំពីវគ្គមុនសម័យប្រជុំ

- https://powerfulpanels.com/definition-panel-discussion/ ស្តីអំពី Panellist Speaker គឺជាវាគ្មិននៅក្នុង ការពិភាក្សាជាក្រុម (Panel Discussion)
- គេហទំព័រ https://upr-info-database.uwazi.io មូលដ្ឋានទិន្នន័យនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់
- គេហទំព័រ https://www.upr-info.org/en ស្ដីពីអង្គការអំពីការត្រួតពិនិត្យជាសកលតាមកាលកំណត់

# ឧបសម្ព័ន្ធ